ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៨ លេខ ៤ ខែធ្នូ ២០១៤ តម្លៃ ១.៥០០៛

# ឥរិយាបថស្វែងរកសេវាថែទាំសុខភាពមាតា៖ វិធីសាស្ត្រផ្អែកលើប្រវត្តិជីវិត

## សេចក្ដីផ្ដើម

នៅដើមទសវត្សរ៍១៩៩០ កម្ពុជាត្រូវប្រឈមនឹងប្រព័ន្ធសុខាភិបាលខ្ទេចខ្ទាំមួយ បន្ទាប់ពីបានឆ្លងកាត់សង្គ្រាមជិត ៣០ឆ្នាំ ចាប់តាំងពីចុងទសវត្សរ៍១៩៦០ មក។ សង្គ្រាមបានផ្ទុះឡើងដោយសារ សង្គ្រាមនៅវៀតណាមរីករាលដាលចូលមកក្នុងប្រទេសកម្ពុជា ហើយបន្តដោយសង្គ្រាមស៊ីវិល និងរបបប្រល័យពូជសាសន៍ក្រោមការត្រួតត្រារបស់ខ្មែរក្រហម ចាប់ពីឆ្នាំ១៩៧០ ដល់ ១៩៧៩។ រចនាសម្ព័ន្ធសុខាភិបាលភាគច្រើនមានទាំង អាគារ សម្ភារ និងបុគ្គលិកសុខាភិបាលបានរងការបំផ្លិចបំផ្លាញធ្ងន់ធ្ងរ។ នៅឆ្នាំ១៩៧៩ មាននៅសល់វេជ្ជបណ្ឌិតប្រហែល ៤០នាក់ប៉ុណ្ណោះ សម្រាប់បម្រើតម្រូវការរបស់ប្រជាជន (Payne 2000)។ ការកសាងប្រព័ន្ធសុខាភិបាលឡើងវិញ បានចាប់ផ្ដើមជាមួយនឹងកំណែទម្រង់វិស័យសុខាភិបាលដែលអនុវត្តជាបីដំណាក់កាល គឺនៅឆ្នាំ១៩៩១-៩៤, ១៩៩៥-៩៧ និង ១៩៩៨-២០០០ ហើយបន្តដោយផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ដែលមានពីរដំណាក់កាល គឺនៅឆ្នាំ២០០៣-០៧ និង ២០០៨-១៥។



សេវាសុខភាពមាតាភាគច្រើន ផ្ដល់ឲ្យដោយឥតគិតថ្លៃសម្រាប់ស្ត្រីអាចបំពេញបានតាមលក្ខណៈវិនិច្ឆ័យនៃសិទ្ធិទទួលបានសេវា (បាត់ដំបង ខែតុលា ឆ្នាំ២០១៤)

ការថែទាំសុខភាពមាតា ជាអាទិភាពដ៏សំខាន់មានចែងនៅក្នុងដំណាក់កាលទី១ និងទី២ នៃផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល និងបង្ហាញពីចក្ខុវិស័យរបស់រដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យសុខាភិបាល ដើម្បីលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជនកម្ពុជាគ្រប់រូប ជាពិសេសជនក្រីក្រ ស្ត្រី និងកុមារ ហើយជួយរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ច។ ផែនការសកម្មភាពនេះ សំដៅដោះស្រាយអត្រាមរណៈមាតាយ៉ាងខ្ពស់ ក្នុងទូទាំងប្រទេសដោយសារបញ្ហាចម្បងៗបី គឺ ការធ្លាក់ឈាមច្រើនពេក ការក្លាយមុខរបួស និងសំពាធឈាមឡើងខ្ពស់ (Yanakisawa 2004)។ កត្តាសំខាន់ៗដែលរួមចំណែកបង្កគ្រោះថ្នាក់ដល់ជីវិតមាតា គឺ (១) ការយឺតយ៉ាវក្នុងការស្វែងរកជំនួយសង្គ្រោះផ្អែកវេជ្ជសាស្ត្រ, (២) ការយឺតយ៉ាវក្នុងការបញ្ជូនអ្នកជំងឺ និង (៣) ការយឺតយ៉ាវក្នុងការទទួលបានសេវាសុខភាព (UNFPA 2013)។

ការសិក្សាជាតិពន្ធុសាស្ត្រ (សិក្សាពីជនជាតិ និងវប្បធម៌) មួយ (Ovesen and Trankell 2010) បង្ហាញថា មុនសម័យអាណានិគមបារាំង ប្រជាជនកម្ពុជាពឹងផ្អែកយ៉ាងខ្លាំងលើឆ្មបបុរាណនៅពេលសម្រាលកូន ហើយការអនុវត្តបែបនេះមានបន្ត

---

រៀបចំឡើងដោយ រស់ បណ្ដែត អ្នកស្រាវជ្រាវផ្នែកសុខភាព នៃវិទ្យាស្ថាន CDRI។ សូមយោងឯកសារនេះថា៖ Ros Bandeth. 2014. “Maternal Healthcare Seeking Behaviour: A Life History Approach”, *Cambodia Development Review* 18(4): 1-5។

## មាតិកា

ឥរិយាបថស្វែងរកសេវាថែទាំសុខភាពមាតា៖ វិធីសាស្ត្រផ្អែកលើប្រវត្តិជីវិត ........ ១
សន្តិសុខទឹកប្រសើរ ជួយបង្កើនសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ ........ ៦
ការងារ ១០ឆ្នាំ នៅវិទ្យស្ថាន CDRI នៅកម្ពុជា – ការពិចារណាផ្ទាល់ខ្លួនលើបទពិសោធន៍នេះ ........ ១២
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........ ១៧
— ស្ថានភាពក្នុងប្រទេស ........ ១៩
— សូចនាករ ........ ២១
ផ្នែកស្រាវជ្រាវ ........ ២៥
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ........ ២៨

រហូតមកដល់សព្វថ្ងៃ (Yanakisawa, Oum and Wakai 2006; Wang and Hong 2013)។បើធៀបនឹងអ្នកមានជំនាញផ្នែកសម្ភព ដូចជា ឆ្មប វេជ្ជបណ្ឌិត និងគិលានុប្បដ្ឋាក ជាដើម ឆ្មបបុរាណជាទូទៅមិនមានការបណ្ដុះបណ្ដាលជាផ្លូវការទេ ជាពិសេសក្នុងការចៀសវាង និងគ្រប់គ្រងស្ថានភាពស្មុគស្មាញក្នុងអំឡុងពេលមានផ្ទៃពោះ និងសម្រាលកូន។

ក្នុង ១៥ឆ្នាំកន្លងទៅនេះ កម្ពុជាបានជឿនលឿនទៅមុខក្នុងការកាត់បន្ថយអត្រាមរណៈមាតា។ អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា បានបង្ហាញពីការថយចុះជាបណ្ដើរៗនៃអត្រាមរណៈមាតា គិតក្នុង ១០០.០០០កំណើតរស់ គឺពី ៤៣៧ ក្នុងឆ្នាំ២០០០ មកត្រឹម ២០៦ ក្នុងឆ្នាំ២០១០ (NIS 2011)។ ការថយចុះនេះបណ្ដាលពីកត្តាជាច្រើន ក្នុងនោះមានទាំងការផ្លាស់ប្ដូរឥរិយាបថក្នុងការស្វែងរកសេវាថែទាំសុខភាព ដោយសារសេវានេះកាន់តែសម្បូរឡើង, និង កំណើនលទ្ធភាពប្រើប្រាស់សេវាថែទាំសុខភាពមាតាដ៏ចាំបាច់នានា ដូចជា ការថែទាំសុខភាពស្ត្រីមុនពេលសម្រាលកូន ការសម្រាលកូនដោយមានបុគ្គលិកជំនាញជួយសម្រួល និងការថែទាំសុខភាពក្រោយពេលសម្រាលកូន (Wang and Hong 2013)។

ការផ្លាស់ប្ដូរឥរិយាបថក្នុងការស្វែងរកសេវាសុខភាព ពីការពឹងផ្អែកលើឆ្មបបុរាណ និងការសម្រាលកូននៅតាមផ្ទះ ទៅជាការសម្រាលកូនដោយមានបុគ្គលិកជំនាញជួយសម្រួល និងការទៅសម្រាលនៅក្នុងគ្រឹះស្ថានសុខាភិបាល (ឧ. សូមមើល Yanakisawa, Oum and Wakai 2006; Ir et al. 2008; Wang and Hong 2013) គឺមានស្ថិតិបញ្ជាក់យ៉ាងច្បាស់។ ប៉ុន្តែនៅមានការសិក្សាតិចតួចពេកដែលផ្ដោតលើ ដំណើរផ្លាស់ប្ដូរឥរិយាបថ និងឥទ្ធិពលនៃមនោគមន៍វិជ្ជាខាងនយោបាយ។ អត្ថបទនេះវែកញែកថា ប្រវត្តិសង្គ្រាមស៊ីវិល និងទំនាស់តាមផ្លូវយោធានាពេលថ្មីៗនៅកម្ពុជា បានរួមចំណែកដល់ការផ្លាស់ប្ដូរឥរិយាបថ និងជម្រើសសេវាសម្ភព។

ការសិក្សានេះ ពិនិត្យពីឥរិយាបថស្វែងរកសេវាសុខភាពក្នុងពេលសម្រាលកូននៅកម្ពុជា ចាប់ពីទសវត្សរ៍១៩៦០ មកទល់បច្ចុប្បន្ន និងវិភាគពីកត្តាដែលជះឥទ្ធិពលទៅលើការសម្រេចចិត្តប្រើប្រាស់សេវាសម្រាលកូន។ លទ្ធផលរកឃើញនឹងបានជាព័ត៌មានដល់អ្នកកសាងគោលនយោបាយ អំពីមូលហេតុនាំឲ្យមានការផ្លាស់ប្ដូរឥរិយាបថ និងបែបបទដែលកត្តាផ្សេងៗជះឥទ្ធិពលទៅលើជម្រើសសេវាសម្រាលកូន និងការរីកចម្រើនសេវាសម្ភពនៅកម្ពុជា។

## វិធីសាស្ត្រស្រាវជ្រាវ

វិធីសាស្ត្រផ្អែកលើប្រវត្តិជីវិត បានយកមកប្រើប្រាស់ដើម្បីធ្វើសម្ភាសន៍អ្នកចូលរួម ២៤នាក់ នៅក្រុងភ្នំពេញ និងខេត្តតាកែវ ស្ដីពី សេវាសម្រាលកូនដែលគាត់បានស្វែងរក។ ការសិក្សាបានជ្រើសរើស ស្ត្រី និងបុរសអាយុចាប់ពី ៤០ឆ្នាំឡើង ឲ្យចូលរួមក្នុងបទសម្ភាសន៍ ដោយផ្អែកលើស្ថានភាពក្រីក្ររបស់ពួកគាត់តាមការកំណត់របស់អាជ្ញាធរមូលដ្ឋាន។ ក្រុមស្រាវជ្រាវបានគូរនូវខ្សែបន្ទាត់ជីវិត ដើម្បីបង្ហាញពីព្រឹត្តិការណ៍សម្រាលកូនជាបន្តបន្ទាប់ក្នុងមួយជីវិតរបស់អ្នកចូលរួមក្នុងសម្ភាសន៍។ ប្រវត្តិជីវិតដោយមានទាំងគំនូរខ្សែបន្ទាត់ជីវិតផង វាជួយពន្យល់ពីមូលហេតុដែលបុគ្គលម្នាក់ៗដើរលើគន្លងជីវិតខុសៗគ្នា និងជួយកំណត់ពីផ្លូវដើរដែលជះឥទ្ធិពលទៅលើគន្លងជីវិតទាំងនោះ។ វិធីសាស្ត្រនេះសមស្របណាស់ សម្រាប់ការស្រាវជ្រាវពីគោលនយោបាយសុខាភិបាល ជាពិសេស ការស្រាវជ្រាវលើបទពិសោធន៍ពីអតីតកាល ដើម្បីផ្ដល់ព័ត៌មានសម្រួលដល់ការអនុវត្តនាពេលអនាគត (Gramling and Carr 2004)។ សម្រាប់ការសិក្សារបស់យើង បច្ចេកទេសទាំងនេះជួយផ្ដល់ការយល់ដឹងកាន់តែស៊ីជម្រៅពីការផ្លាស់ប្ដូរជម្រើសសេវាសម្រាលកូន និងកត្តាជំរុញការផ្លាស់ប្ដូរទាំងនោះ។ ការសិក្សានេះប្រើប្រាស់វិធីដាក់លេខកូដដើម្បីវិភាគលើទិន្នន័យប្រមូលបាន។ ក្នុងអំឡុងពេលវិភាគទិន្នន័យត្រូវបានដាក់លេខកូដនិងបែងចែកជាកញ្ចុំៗ ទៅតាមសាច់រឿងរួមគ្នាមួយចំនួន ដែលផុសឡើងពីការវិភាគ។ បន្ទាប់មកក្រុមស្រាវជ្រាវបង្កើតនូវតារាងម៉ាទ្រីសដើម្បីបង្ហាញពីលំនាំនៃឥរិយាបថស្វែងរកសេវាថែទាំសុខភាពមាតានៅតាម របបនយោបាយផ្សេងៗនៅកម្ពុជាចាប់ពីឆ្នាំ១៩៦០ រហូតមកដល់សព្វថ្ងៃ។

តារាង ១៖ គន្លងឥរិយាបថក្នុងការសម្រាលកូន



## លទ្ធផលសិក្សា

ការសិក្សានេះ រកឃើញថា អ្នកចូលរួមសម្ភាសន៍ មានប្រើវិធីទាំង ៥ នៃសេវាសុខភាពនៅពេលសម្រាលកូន គឺមានការសម្រាលនៅផ្ទះ ដោយមាន

ជំនួយពីឆ្មបបុរាណ, នៅផ្ទះដោយមានជំនួយពីឆ្មបឆ្លងកាត់ការបណ្តុះបណ្តាលត្រឹមត្រូវ, នៅគ្រឹះស្ថានសុខភាពសាធារណៈ, នៅគ្លីនិកឯកជន, និង នៅមន្ទីរពេទ្យឯក្រៅប្រទេស។ ការវិភាគប្រវត្តិជីវិត ដូចមានបង្ហាញក្នុង តារាង ១ ផ្តល់គំនិតថា មានការផ្លាស់ប្តូរជាបណ្តើរៗ ពីការសម្រាលកូននៅផ្ទះដោយមានជំនួយពីឆ្មបបុរាណ ទៅជាការទទួលសេវានៅគ្រឹះស្ថានសុខភាព។ គេបានពឹងផ្អែកលើឆ្មបបុរាណរហូតមក តាំងពីសម័យមុនសង្គ្រាម, ក្នុងពេលមានសង្គ្រាម និងក្រោយសង្គ្រាម។ ក្នុងអំឡុងពេលអន្តរកាលក្រោយបញ្ចប់ទំនាស់ ក្នុងពេលកំពុងកសាងឡើងវិញនូវប្រព័ន្ធសុខាភិបាល ហើយគ្រឹះស្ថានសុខភាពសាធារណៈនៅលំបាករកបាននោះ តម្រូវការឆ្មបមានការបណ្តុះបណ្តាលសម្រាប់ជួយដល់ការសម្រាលកូននៅផ្ទះ វាកាន់តែលេចធ្លោឡើង។ នៅពេលការដឹកជញ្ជូនតាមផ្លូវថ្នល់កាន់តែសម្បូរឡើង ប្រជាជនរស់នៅជិតព្រំដែន ក៏ចាប់ផ្តើមស្វែងរកសេវាសុខភាពប្រសើរឡើងនៅឯប្រទេសជិតខាង ជាពិសេស សម្រាប់ករណីស្ត្រីមានផ្ទៃពោះដែលមានស្ថានភាពស្មុគស្មាញ។ ការសម្រាលកូននៅគ្រឹះស្ថានសុខភាពសាធារណៈក៏ចាប់កើនឡើង នៅពេលដំណើរការកសាងវិស័យសុខាភិបាលឡើងវិញ បានបង្កើនល្បឿន ហើយគ្លីនិកឯកជនទើបផុសថ្មីក៏មានផ្តល់សេវាថែទាំសុខភាពមាតា សម្រាប់អ្នកណាដែលមានលទ្ធភាពរ៉ាប់រងចំណាយបែបនេះ។

## ទសវត្សរ៍១៩៦០ ដល់ពាក់កណ្តាលទសវត្សរ៍ ១៩៧០

ចាប់ពីទសវត្សរ៍១៩៦០ ដល់ពាក់កណ្តាលទសវត្សរ៍១៩៧០ ស្ត្រី និងគ្រួសារ ដែលស្វែងរកសេវាជួយសម្រួលការសម្រាលកូនតែងពឹងផ្អែកលើជំនួយពីសំណាក់ឆ្មបបុរាណ។ មានមនុស្សតិចនាក់ណាស់ដែលជ្រើសប្រើគ្រឹះស្ថានសុខភាពសាធារណៈ ហើយភាគច្រើនជាអ្នករស់នៅតំបន់ទីក្រុង។ ហេតុផលមានលើកឡើងជារឿយៗនៃការប្រើប្រាស់ឆ្មបបុរាណ គឺ ការពិបាករកបានគ្រឹះស្ថានសុខភាពសាធារណៈ ដោយសារបញ្ហាគួបផ្សំគ្នានៃកង្វះមន្ទីរពេទ្យ ចម្ងាយផ្លូវទៅពេទ្យ និងកង្វះការដឹកជញ្ជូន។ អ្នកខ្លះនៅចាំបានថា កាលនោះមន្ទីរពេទ្យមិនដឹងមាននៅឯណាឲ្យច្បាស់ទេ ហើយមានផ្តល់សេវាសម្រាលកូនដែរឬក៏អត់។ សូម្បីអ្នករស់នៅក្បែរមន្ទីរពេទ្យ ក៏ពឹងផ្អែកលើឆ្មបបុរាណដែរ ព្រោះមានអារម្មណ៍ថា ការប្រើប្រាស់សេវាឆ្មបបុរាណមានសុវត្ថិភាពល្អ បើសិនការសម្រាលកូនហាក់ដូចគ្មានអ្វីស្មុគស្មាញ ដូចជា គ្មានធ្លាក់ឈាមច្រើនខុសប្រក្រតី ឬការសម្រាលកូនយូរពេក។

ការលំបាក ដើម្បីបានប្រើប្រាស់សេវាសុខភាពសាធារណៈ មានន័យថា ប្រជាជនត្រូវពឹងផ្អែកលើសេវាអាចរកបាននៅក្នុងសហគមន៍ ពោលគឺ ឆ្មបបុរាណ។ របៀបអនុវត្តបែបបុរាណ និងជំនឿលើសមត្ថភាពឆ្មបបុរាណ ក្នុងការផ្តល់សេវាសម្រាលកូនប្រកបដោយសុវត្ថិភាព បានបន្តពីមួយជំនាន់ទៅមួយជំនាន់។ អ្នកចូលរួមបានឆ្លើយសម្ភាសន៍ប្រាប់ថា ទម្លាប់របស់ឪពុកម្តាយគាត់ និងអ្នកភូមិឯទៀត បានក្លាយជាឧទាហរណ៍សម្រាប់ឲ្យគាត់អនុវត្តតាម ហើយវាជះឥទ្ធិពលលើការជ្រើសរើសសេវាសម្រាលកូនរបស់គាត់។ សង្គ្រាមនៅវៀតណាម និងភាពតានតឹងផ្នែកយោធា ជាហេតុផលមួយទៀតជំរុញឲ្យប្រជាជនជ្រើសរើសការសម្រាលកូននៅផ្ទះជាមួយឆ្មបបុរាណ។ បន្ទាប់ពីរដ្ឋប្រហារដោយសេនាប្រមុខ លន់ នុល នៅឆ្នាំ១៩៧០ ភាពជ្រួលច្របល់ និងការបំផ្លិចបំផ្លាញ ដោយសារការទម្លាក់គ្រាប់បែករបស់កងទ័ពសហរដ្ឋអាមេរិក និងសង្គ្រាមស៊ីវិលតទល់ជាមួយខ្មែរក្រហម នាំឲ្យមានការជម្លៀសប្រជាជនដ៏សន្ធឹកសន្ធាប់ នៅតាមតំបន់មួយចំនួននៃប្រទេសកម្ពុជា។ ការប្រើប្រាស់សេវាសុខភាពសាធារណៈនៅពេលនោះ គឺសឹងតែមិនអាចធ្វើទៅបាន។

អ្នកចូលរួមសម្ភាសន៍ខ្លះ បានប្រាប់ពីភាពស្រដៀងគ្នានៃសេវាសុខភាពមាតានៅទសវត្សរ៍១៩៦០ និង ១៩៧០ ទៅនឹងសេវានាពេលបច្ចុប្បន្ន ដោយអះអាងថា កង្វះការចែកចាយព័ត៌មានអំពីកន្លែងត្រូវទៅទទួលសេវាសម្រាលកូន គឺជាហេតុផលមួយដែលប្រជាជនមួយចំនួន នៅតែជ្រើសរើសការសម្រាលកូននៅផ្ទះជាមួយឆ្មបបុរាណ។ ដោយសារមិនបានដឹងពីគ្រោះថ្នាក់ដែលអាចកើតមានពីការសម្រាលកូននៅផ្ទះ និងសារៈសំខាន់នៃការសម្រាលកូននៅមន្ទីរពេទ្យ ប្រជាជននៅតែអនុវត្តតាមរបៀបបុរាណ។

## ពីឆ្នាំ១៩៧៥ ដល់ ១៩៧៩

ឆ្មបបុរាណ ជាប្រភពតែមួយគត់នៃជំនួយដល់ការសម្រាលកូនក្នុងអំឡុងពេលកាន់កាប់របស់ខ្មែរក្រហម។ មិនមានរបាយការណ៍ពីការសម្រាលកូននៅមន្ទីរពេទ្យទេ។ អវត្តមាននៃគ្រឹះស្ថានសុខភាព ឬសេវាសម្រាលកូនសាធារណៈ មានន័យថា ស្ត្រី និងគ្រួសារគាត់ ត្រូវពឹងផ្អែកលើឆ្មបបុរាណ។ អ្នកចូលរួមសម្ភាសន៍ខ្លះបានពន្យល់ថា សូម្បីសេវាឆ្មបបុរាណ ក៏ពិបាករកបានដែរ ព្រោះឆ្មបបុរាណជារឿយៗ ត្រូវគេចាត់ឲ្យទៅធ្វើការនៅកន្លែងឆ្ងាយៗ។ អ្នកខ្លះទៀតប្រាប់ថា ដោយសារគាត់ត្រូវគេបញ្ជូនជាញឹកញាប់ឲ្យទៅធ្វើការនៅកន្លែងថ្មី ឬក៏ត្រូវធ្វើការរហូតដល់ពេលសម្រាលកូនតែម្តង ដូច្នេះមិនអាចរកឆ្មបបុរាណមកទាន់ទេ ហើយត្រូវសម្រាលកូនដោយគ្មានជំនួយ។

## ទសវត្សរ៍១៩៨០ និង ១៩៩០

ប្រវត្តិជីវិតរបស់អ្នកចូលរួមឆ្លើយសម្ភាសន៍ បង្ហាញនូវលំនាំបួនយ៉ាងនៃសេវាសម្រាលកូន៖ នៅផ្ទះជាមួយឆ្មបបុរាណ, នៅផ្ទះជាមួយឆ្មបមានការបណ្តុះបណ្តាល, នៅគ្រឹះស្ថានសុខភាពនៅបរទេស, និង នៅគ្រឹះស្ថានសុខភាពសាធារណៈក្នុងស្រុក។ ទោះយ៉ាងនេះក្តី ប្រជាជននៅតែពឹងផ្អែកខ្លាំងលើឆ្មបបុរាណបន្ទាប់ពីការដួលរលំរបបប៉ុលពត រហូតដល់ចុងទសវត្សរ៍១៩៩០។ ការប្រើប្រាស់ឆ្មបបុរាណនៅពេលនោះ ជាប់ទាក់ទងនឹងកត្តាជាច្រើន។ អ្នកចូលរួមសម្ភាសន៍ បានលើកពីកង្វះ ឬការបំផ្លិចបំផ្លាញរចនាសម្ព័ន្ធសុខាភិបាលនៅក្នុងមូលដ្ឋាន។ អ្នកខ្លះបានប្រាប់ពីការបើកឡើងវិញនូវមណ្ឌលសុខភាព ឬមន្ទីរពេទ្យសាធារណៈ នៅក្នុងស្រុក ឬខេត្តមួយចំនួនក្នុងទសវត្សរ៍១៩៨០ ប៉ុន្តែបានលើកផងដែរពីអវត្តមាននៃសេវាសម្រាលកូន ឬភាពមិនឆ្លើយតបនឹងតម្រូវការនៃប្រព័ន្ធសុខាភិបាល ដោយសារគ្រឿងសម្រួលការនៅអន់ខ្សោយ, កង្វះការគ្រប់គ្រង, កង្វះការផ្គត់ផ្គង់សម្ភារបរិក្ខារពេទ្យ, និងកង្វះឆ្មប។ នៅតាមតំបន់ខ្លះ មន្ទីរពេទ្យ

នៅតែគ្មានផ្ដល់សេវាសម្រាលកូន រហូតដល់ពាក់កណ្ដាលទសវត្សរ៍១៩៩០ ដូច្នេះហើយអ្នកចូលរួមសម្ភាសន៍ក៏មិនបានគិតគូរពីការសម្រាលកូននៅមន្ទីរពេទ្យ។ កត្តាមួយទៀតដែលអាចពន្យល់ពីការប្រើសេវាសុខភាពកម្រិតទាប គឺ កង្វះការចែករំលែកព័ត៌មានពីសំណាក់អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់ នៃការសម្រាលកូននៅមន្ទីរពេទ្យ។

សន្តិសុខមិនសូវល្អ និងកន្លែងពិបាកទៅដល់ ក៏មានលើកឡើងដែរថា បានប៉ះពាល់ដល់ លទ្ធភាពរបស់ប្រជាជនក្នុងការទទួលសេវានាពេលនោះ។ នៅតាមតំបន់ខ្លះ កងទ័ពរដ្ឋាភិបាលបន្តប្រយុទ្ធជាមួយទ័ពខ្មែរក្រហម រហូតដល់ឆ្នាំ១៩៩៨។ អ្នកចូលរួមសម្ភាសន៍ បាននិយាយពីការពង្រាយទ័ពវៀតណាមនៅតាមព្រំដែនដែលមានយុទ្ធជនខ្មែរក្រហមនៅទីនោះ ដោយពន្យល់ថាប្រជាជនមិនហ៊ានធ្វើដំណើរចេញពីភូមិស្រុកខ្លួន ដើម្បីទៅទទួលសេវាសុខភាពសាធារណៈឡើយ។ គ្រាប់មីនមានកប់យ៉ាងច្រើន និងគ្មានរើសកន្លែង ក្នុងអំឡុងពេលសង្គ្រាម ហើយនៅតែបង្កគ្រោះថ្នាក់ជាច្រើនទសវត្សរ៍បន្តមកទៀត។ ក្រៅពីនាំឲ្យមានការបាត់បង់ជីវិត របួស និងពិការភាព គ្រាប់មីនទាំងនោះមានផលប៉ះពាល់ដោយប្រយោលយ៉ាងច្រើន ទៅលើសុខភាពសាធារណៈ ដោយរារាំងការរីកចម្រើននៃហេដ្ឋារចនាសម្ព័ន្ធ និងកាត់បន្ថយធ្ងន់ធ្ងរនូវលទ្ធភាពប្រើប្រាស់មន្ទីរពេទ្យសាធារណៈ។

ទោះបីសេវាឆ្មបបុរាណនៅតែមានប្រជាប្រិយភាព ប៉ុន្តែការជួលឆ្មបឯករាជ្យមានការបណ្ដុះបណ្ដាលត្រឹមត្រូវ ឲ្យជួយសម្រួលដល់ការសម្រាលកូន បានចាប់ផុសឡើងហើយ។ អ្នកចូលរួមសម្ភាសន៍ខ្លះ ប្រាប់ថា នៅចុងទសវត្សរ៍១៩៩០ គាត់បានហៅរកឆ្មបពីមុនដែលនៅរស់រានជីវិតពីរបបប៉ុលពត ឲ្យជួយសម្រួលការសម្រាលកូននៅផ្ទះ ឯអ្នកខ្លះទៀតប្រាប់ថា បានជួលឆ្មបទើបទទួលបានការបណ្ដុះបណ្ដាលថ្មីៗឲ្យជួយ។ ការប្រើឆ្មបឯករាជ្យចាប់កើនឡើង នៅពេលប្រជាជនបានយល់ដឹងកាន់តែច្រើនពីគ្រោះថ្នាក់ក្នុងពេលសម្រាលកូន និងចង់បានសេវាជាទីទុកចិត្ត ក្នុងពេលដែល លទ្ធភាពប្រើប្រាស់គ្រឹះស្ថានសុខភាពសាធារណៈនៅមិនទាន់មានគ្រប់កន្លែង។

ចាប់ពីពាក់កណ្ដាលទសវត្សរ៍១៩៩០ នៅពេលស្ថានភាពសេដ្ឋកិច្ចបានល្អប្រសើរឡើង ហើយការដឹកជញ្ជូនតាមផ្លូវគោកក៏សម្បូរជាងមុននៅគ្រប់កន្លែងនោះ ប្រជាជនរស់នៅក្បែរព្រំដែនក៏ចាប់ផ្ដើមស្វែងរកសេវាសុខភាពនៅក្នុងប្រទេសជិតខាង។ បញ្ហានេះបណ្ដាលជាចម្បងមកពីពួកគេមិនអាចពឹងផ្អែកលើ គ្រឹះស្ថានសុខភាពនៅតាមមូលដ្ឋាន ដែលមិនទាន់មានលទ្ធភាពជួយដល់ការសម្រាលកូនមានដំណើរស្មុគស្មាញ។

កំណើនការប្រើប្រាស់គ្រឹះស្ថានសុខភាពសាធារណៈ សម្រាប់សេវាសម្រាលកូន ក៏អាចមើលឃើញច្បាស់ដែរក្នុងអំឡុងពេលនោះ ជាពិសេសក្នុងចំណោមអ្នករស់នៅតំបន់ទីក្រុង ហើយវាឆ្លុះបញ្ចាំងពីការរៀបចំឡើងវិញ នូវប្រព័ន្ធសុខាភិបាល និងការផ្ដល់សេវាសុខភាព ដែលនាំឲ្យមានការកសាងមន្ទីរពេទ្យជាពិសេសនៅតំបន់ទីក្រុង។ អ្នកចូលរួមសម្ភាសន៍នៅតំបន់ទីក្រុងប្រាប់ថា គាត់ស្គាល់មន្ទីរពេទ្យជាច្រើននៅក្នុងក្រុង និងដឹងពីមធ្យោបាយដឹកជញ្ជូនអាចរកបាន សម្រាប់ទៅកាន់មន្ទីរពេទ្យទាំងនោះ។ ដោយឡែក គ្រួសារយោធាអាចប្រើសេវាសម្រាលកូនដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យយោធា។

អ្នកចូលរួមសម្ភាសន៍ម្នាក់ៗ ហាក់ដូចជាបានដឹងពុច្រើនជាងមុន អំពីព័ត៌មានផ្នែកសុខភាពនៅតំបន់ទីក្រុង។ ទំនាក់ទំនងប្រចាំថ្ងៃ អាចឲ្យប្រជាជនចែករំលែកព័ត៌មានជាមួយអ្នកជិតខាង និងមិត្តភក្តិ អំពីការថែទាំសុខភាពក្នុងពេលសម្រាលកូន ជួយគាត់ឲ្យស្វែងយល់ពីតម្រូវការរបស់ខ្លួន និងថ្លឹងថ្លែងពីជម្រើសផ្សេងៗដែលគាត់មាន។

កត្តាសេដ្ឋកិច្ច និងភាពក្រីក្រក្នុងគ្រួសារ ក៏ប៉ះពាល់ទៅលើការសម្រេចចិត្តទាក់ទងនឹងសេវាសម្រាលកូនដែរ។ នៅតំបន់ខ្លះ គ្រឹះស្ថានសុខភាពសាធារណៈមិនគិតថ្លៃសេវាទេ សម្រាប់ប្រជាជនមានចំណាត់ថ្នាក់ជាអ្នកក្រ ប៉ុន្តែគ្រឹះស្ថានបែបនេះមិនមែនមាននៅគ្រប់ទីកន្លែងឡើយ៖ អ្នកចូលរួមសម្ភាសន៍ខ្លះប្រាប់ថាមន្ទីរពេទ្យមិនយកប្រាក់ទេ ប៉ុន្តែខ្លះទៀតប្រាប់ថាត្រូវបង់ថ្លៃព្យាបាល។ អ្នកដែលអាចរ៉ាប់រងចំណាយបាន គាត់ក៏សម្រេចចិត្តប្រើប្រាស់ គ្រឹះស្ថានសុខភាពសាធារណៈ រីឯអ្នកមិនមានលទ្ធភាពត្រូវបែរទៅប្រើ សេវាឆ្មបបុរាណដែលមានតម្លៃថោកខ្លាំងជាងមន្ទីរពេទ្យ។ អ្នកចូលរួមតែងប្រាប់ជារឿយៗថាឆ្មបបុរាណមិនទាមទារយកប្រាក់ ឬក៏គាត់សុខចិត្តមកនៅពេលសម្រាលកូនដើម្បីជួយដល់អ្នកនៅភូមិជាមួយគ្នា ឬនៅភូមិក្បែរគ្នា៖ ជារឿយៗគាត់ទទួលបានសគុណជាអំណោយ ឬសម្ភារទៅតាមលទ្ធភាពធនធានរបស់ប្រជាជន។

## ពីឆ្នាំ២០០០ មកទល់បច្ចុប្បន្ន

ទោះបីកន្លងមក ឥរិយាបថនៅតែបង្ហាញពីការបន្តប្រើប្រាស់សេវាសម្រាលកូន ៣ប្រភេទ (នៅផ្ទះជាមួយឆ្មបបុរាណនៅផ្ទះជាមួយឆ្មបមានការបណ្ដុះបណ្ដាល និង នៅគ្រឹះស្ថានសុខភាពសាធារណៈ) ប៉ុន្តែបទសម្ភាសន៍បានបង្ហាញនូវការផុសឡើងនៃគ្លីនិកសម្ភពឯកជន។ កត្តាកំណត់ចម្បងនៃការប្រើប្រាស់គ្លីនិកទាំងនេះ គឺ ស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចនៃអ្នកប្រើប្រាស់សេវា និងតម្រូវការសេវាសម្រាលកូន មានគុណភាពខ្ពស់ជាងសេវាទាំងបីខាងលើ។ ទន្ទឹមគ្នានោះ ការពឹងផ្អែកលើឆ្មបបុរាណបានចាប់ផ្ដើមថយចុះជាបណ្ដើរៗ។ អ្នកឆ្លើយសម្ភាសន៍ ក៏ដូចជាកូនក្មួយគាត់ (តារាង ១) ដែលមានលទ្ធភាពរ៉ាប់រងចំណាយ ហាក់ដូចបានបែរទៅប្រើគ្រឹះស្ថានសុខភាពសាធារណៈ រីឯអ្នកគ្មានលទ្ធភាពនៅតែពឹងផ្អែកលើឆ្មបបុរាណ។ កត្តាសំខាន់មួយដែលជំរុញកំណើនការប្រើប្រាស់សេវាសុខភាពសាធារណៈ គឺគុណភាពនៃសេវាសម្រាលកូន គួបផ្សំនឹងការផ្គត់ផ្គង់គ្រប់គ្រាន់នូវឱសថនិងសម្ភារបរិក្ខារពេទ្យ។ អ្នកឆ្លើយសម្ភាសន៍ប្រាប់ថាគាត់ប្ដូរពីការប្រើឆ្មបបុរាណ មកប្រើមន្ទីរពេទ្យសាធារណៈនៅពេលមានស្ថានភាពធ្ងន់ធ្ងរ ឬការសម្រាលកូនមានដំណើរស្មុគស្មាញ។

នៅតំបន់ខ្លះ គោលនយោបាយសុខាភិបាលថ្មីអំណោយផលដល់ជនក្រីក្រ ដែលជួយប្រជាជនឲ្យបានប្រើប្រាស់សេវាសុខភាពដោយឥតគិតថ្លៃនោះ ពិតជាមានឥទ្ធិពលទៅលើការសម្រេចចិត្តប្រើប្រាស់គ្រឹះស្ថានសុខភាពសាធារណៈ។ ប្រជាជនបាននិយាយ

អំពីការលើកលែង និងការមិនយកថ្លៃសេវាសម្រាលកូន តាមរយៈ មូលនិធិសមធម៌សុខភាព និងគម្រោងធានារ៉ាប់រងសុខភាពផ្អែកលើសហគមន៍។ ប៉ុន្តែនៅតំបន់ខ្លះទៀត ទោះបីមានគម្រោងប័ណ្ណក្រីក្រ (ID Poor scheme) និងជំនួយឧបត្ថម្ភលើសេវាសុខភាពសាធារណៈសម្រាប់ជនក្រីក្រក្តី ក៏ប្រជាជននៅតែពុំមានលទ្ធភាពប្រើប្រាស់គ្រឹះស្ថានសុខភាពសាធារណៈ ព្រោះមិនអាចរ៉ាប់រងលើចំណាយដោយប្រយោលបាន ក្នុងនោះមានទាំងប្រាក់កម្រៃក្រៅផ្លូវការទាមទារដោយពួកឆ្មបផង។ កត្តាមួយទៀតដែលបង្អាក់ទឹកចិត្តប្រជាជន ក្នុងការប្រើប្រាស់សេវាសុខភាពសាធារណៈ គឺឥរិយាបថមិនល្អរបស់បុគ្គលិកពេទ្យមួយចំនួនចំពោះ អតិថិជនដែលមានស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចខ្សត់ខ្សោយ។

ការលើកកម្ពស់ការយល់ដឹងពីសារៈសំខាន់ នៃសេវាថែទាំសុខភាពនៅពេលមានគភ៌ និងការផ្លាស់ប្តូរទស្សនៈលើសេវានេះ ជាពិសេសក្នុងចំណោមក្មេងជំនាន់ក្រោយ បានរួមចំណែកជួយបង្កើនការប្រើប្រាស់គ្រឹះស្ថានសុខភាពសាធារណៈ។ ការផ្លាស់ប្តូរទស្សនៈនេះសម្រេចបានតាមរយៈ ការចែករំលែកព័ត៌មាន និងកម្មវិធីពង្រីកដែនគ្របដណ្តប់ផ្សេងៗ ផ្តួចផ្តើមឡើងដោយរដ្ឋាភិបាល NGOs បណ្តាញផ្សព្វផ្សាយ ក្រុមសហគមន៍ និងអាជ្ញាធរមូលដ្ឋាន។

## សេចក្តីសន្និដ្ឋាន

ការសិក្សានេះបង្ហាញថា ឥរិយាបថផ្នែកសុខភាពរបស់ប្រជាជនកម្ពុជា ជាពិសេសចាប់ពី ចុងទសវត្សរ៍១៩៩០ និងដើមទសវត្សរ៍២០០០ កាន់តែផ្លាស់ប្តូរពី ការពឹងផ្អែកលើឆ្មបបុរាណ ទៅជាការស្វែងរកសេវាសុខភាពបែបទំនើប និងគ្រឹះស្ថានថែទាំសុខភាពទាំងក្នុងវិស័យសាធារណៈ និងឯកជន។ កត្តាបីយ៉ាងដែលជះឥទ្ធិពល ទៅលើការផ្លាស់ប្តូរឥរិយាបថស្វែងរកសេវាសុខភាពនេះ គឺមាន ១) ការរីកលូតលាស់សេវាសម្ភពនៅតាមគ្រឹះស្ថានសាធារណៈ និងឯកជន, ២) ទិដ្ឋភាពផ្នែកសង្គមនយោបាយ ដូចជា ភាពល្អប្រសើរឡើងនៃសន្តិសុខ និងលទ្ធភាពប្រើប្រាស់សេវាសុខភាពបែបទំនើប និង ៣) លក្ខណៈផ្ទាល់របស់បុគ្គល ដូចជា ការយល់ដឹង និងស្ថានភាពសេដ្ឋកិច្ចគ្រួសារជាដើម។

របាយការណ៍ពីប្រវត្តិជីវិត បង្ហាញពីលំនាំនៃការវិវត្តសេវាសម្ភពនៅក្នុងប្រទេស ដែលលេចធ្លោឡើង រលត់បាត់ទៅវិញ ហើយបន្ទាប់មក ផុសឡើងជាថ្មី ព្រោះរងឥទ្ធិពលពីរបបនយោបាយផ្សេងៗ និងស្ថានភាពមានជម្លោះជាបន្តបន្ទាប់ ហើយវាជះឥទ្ធិពលទៅលើជម្រើសសេវាសម្ភពរបស់ប្រជាជន។ នៅមុនសង្គ្រាម ក្នុងពេលសង្គ្រាម និងក្រោយសង្គ្រាម ប្រជាជនត្រេកអរចំពោះសេវាឆ្មបបុរាណ ព្រោះវាមានតម្លៃទាប និងងាយស្រួលប្រើនៅពេលដែលសេវាសម្ភពបែបទំនើបនៅមិនទាន់មាន។ របៀបអនុវត្ត និងជំនឿទៅលើសេវាសុខភាពតាមបែបបុរាណ ដែលផ្ទេរបន្តមកពីមួយជំនាន់ទៅមួយជំនាន់ បានចាប់ផ្តើមសាបរលាបនៅពេលប្រជាជនបានយល់ដឹង (តាមរយៈការផ្ទេរព័ត៌មានផ្នែកសុខាភិបាលនៅក្នុង ឬនៅក្រៅគ្រួសារ) ពីសារៈសំខាន់នៃការសម្រាលកូននៅគ្រឹះស្ថានសុខភាពសាធារណៈ។ ក្នុងពេលជាមួយគ្នាការផ្តល់សេវាសម្ភព នៅតាមគ្រឹះស្ថានសុខភាពសាធារណៈ និងឯកជន (ជួនកាលមានទាំងមន្ទីរពេទ្យនៅបរទេសផង) បានផុសឡើង និងរីករាលដាល, ផ្លូវថ្នល់ក៏មានសាងសង់បន្ថែម ហើយមធ្យោបាយដឹកជញ្ជូនក៏កាន់តែសម្បូរ។

លទ្ធផលសិក្សា បានគូសបញ្ជាក់ពីការបង្កើតគម្រោងហិរញ្ញប្បទានសុខាភិបាលអំណោយផលដល់ជនក្រីក្រ ដើម្បីបំបាត់ឧបសគ្គផ្នែកហិរញ្ញវត្ថុចំពោះគ្រួសារក្រីក្រ ស្របតាមកំណែទម្រង់ហិរញ្ញប្បទានសុខាភិបាលនៅដើមទសវត្សរ៍២០០០។ គំនិតផ្តួចផ្តើមទាំងនេះ ជួយបង្កើនលទ្ធភាពប្រើប្រាស់សេវាសម្ភពនៅតាមគ្រឹះស្ថានសុខភាពសាធារណៈ ប៉ុន្តែចាំបាច់ត្រូវមានការត្រួតពិនិត្យទៅលើលទ្ធផលនៃគម្រោងទាំងនោះ។

សរុបមក ប្រវត្តិលំអិតនៃការប្រែប្រួលឥរិយាបថក្នុងការស្វែងរកសេវាថែទាំសុខភាព ដោយផ្អែកលើបទពិសោធន៍ជាក់ស្តែង អាចមានប្រយោជន៍ដល់ការបង្កើតជា អន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព នៅតាមស្ថាប័ននានាដែលផ្តល់សេវាសុខភាព។ ព័ត៌មានជាក់ស្តែង ស្តីពីជម្រើសសេវាសម្ភព អាចជួយដល់កិច្ចប្រឹងប្រែងរបស់អ្នកកសាងគោលនយោបាយ ក្នុងការបង្កើតជាអន្តរាគមន៍ដើម្បីសង្គ្រោះអាយុជីវិត, និងដោះស្រាយមូលហេតុធំៗទាំងឡាយ (ការយឺតយ៉ាវទាំងបី) គឺមាន បញ្ហាមរណៈមាតា ការលើកកម្ពស់ការប្រើប្រាស់សេវាសម្ភព និងការផ្តល់សេវាសម្ភពនៅកម្ពុជា។

## ឯកសារយោង

Gramling, L.F., and L.C. Carr. 2004. "Lifelines: A Life History Methodology." *Nursing Research* 53(3): 207-10.

Ir, P., D. Horeman, S. Narin and W. Van Damme. 2008. "Improving Access to Safe Delivery for Poor Pregnant Women: A Case Study of Vouchers Plus Health Equity Funds in Three Health Districts in Cambodia." *Studies in HSO&P* 24: 225-256.

National Institute of Statistics, Directorate General for Health, and ICF Macro. 2011. *Cambodia Demographic and Health Survey 2010.* Phnom Penh; Calverton, MA: National Institute of Statistics, Directorate General for Health, and ICF Macro.

Ovesen, Jan, and Ing-Britt Trankell. 2010. *Cambodians and their Doctors: A Medical Anthropology of Colonial and Post-Colonial Cambodia.* Singapore: NIAS Press.

Payne, C. 2000. "Deathwork: Unbearable Witness." *Canadian Medical Association Journal* 163 (9): 1176-1178.

UNFPA, United Nations Population Fund. 2013. "Strengthening of Midwifery Skills on Emergency Obstetric and Newborn Care in Cambodia." www.countryoffice.unfpa.org/cambodia/drive/ Poster-EmONCinterventions.pdf.

Wang, Wenjuan, and Rathavuth Hong. 2013. *Completing the Continuum Care for Maternal and Newborn Health in Cambodia: Who Drops Out?* DHS Further Analysis Report No. 85. Calverton, MA: ICF International.

Yanagisawa, S. 2004. "Crossing the River: Health of Mothers and Children in Rural Cambodia." *International Congress Series* 1267: 113-126.

Yanagisawa, S., S. Oum and S. Wakai. 2006. Determinants of Skilled Birth Attendance in Rural Cambodia. *Tropical Medicine and International Health* 11(2): 238-251.

# សន្តិសុខទឹកប្រសើរ ជួយបង្កើនសមត្ថភាព បន្សាំនឹងការប្រែប្រួលអាកាសធាតុ

## សេចក្តីផ្តើម

អ្នកធ្វើគោលនយោបាយ បានបង្កើតគោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុ ដោយផ្តោតលើរបៀបវារៈពីរគឺៈ ការបន្សាំជាមួយនិង ការកាត់បន្ថយមូលហេតុនៃ ការប្រែប្រួលអាកាសធាតុ។ ការបន្សាំ គឺ ការស្វែងរកវិធីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ លើការរីកចម្រើនសេដ្ឋកិច្ចជាតិ និងសុខុមាលភាពប្រជាជន។ ការកាត់បន្ថយមូលហេតុនៃការប្រែប្រួលអាកាសធាតុ គឺ តាមរយៈការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ (ឧ. កាបូនឌីអុកស៊ីត) ចេញពីការអភិវឌ្ឍសេដ្ឋកិច្ចក្នុងវិស័យផ្សេងៗ។ កម្ពុជាពុំបានរួមចំណែក ក្នុងមូលហេតុនៃការប្រែប្រួលអាកាសធាតុច្រើនទេ ប៉ុន្តែប្រទេសនេះ បានរងគ្រោះជាខ្លាំងដោយគ្រោះធម្មជាតិ ដូចជា ភ្លៀងធ្លាក់មិនទៀងទាត់ ភាពរាំងស្ងួត និងទឹកជំនន់ ដែលជាឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។ គ្រោះធម្មជាតិទាំងអស់នេះ បាននិងកំពុងបង្កផលវិបាកធ្ងន់ធ្ងរលើជីវភាពប្រជាជន ជាពិសេសនៅទីជនបទ។ ផលប៉ះពាល់អវិជ្ជមានខ្លាំងបំផុតនោះ គឺ ហានិភ័យទឹកជំនន់ និងភាពរាំងស្ងួតកាន់តែកើនឡើង ដែលប៉ះពាល់លើដំណាំស្រូវ។

ការសិក្សានេះពិនិត្យមើលថា តើការប្រែប្រួលអាកាសធាតុ និងប្រព័ន្ធមនុស្ស បានជះឥទ្ធិពលយ៉ាងដូចម្តេចលើសន្តិសុខទឹក និងជីវភាពប្រជាជន ក្នុងសហគមន៍មូលដ្ឋាននៅអាងស្ទឹងជ្រៃបាក់។ ការសិក្សានេះ ផ្អែកលើលទ្ធផលនៃការសិក្សាមួយចំនួនទៀតរបស់ CDRI ដែលធ្វើឡើងតាំងពីឆ្នាំ២០០៧ និងបានប្រើប្រាស់ វិធីសាស្ត្រស្រាវជ្រាវមានការចូលរួមពីសហគមន៍ តាមរយៈការពិគ្រោះយោបល់យ៉ាងទូលំទូលាយ ជាមួយភាគីពាក់ព័ន្ធនានាដែលកំពុងអនុវត្តការងារគ្រប់គ្រងអាងស្ទឹង ដូចជា មន្ទីរជំនាញតាមខេត្ត អង្គភាពរដ្ឋថ្នាក់ស្រុក ឃុំ និងសហគមន៍កសិករប្រើប្រាស់ទឹកតាមប្រព័ន្ធធារាសាស្ត្រនីមួយៗ។

## អាងស្ទឹងជ្រៃបាក់

អាងស្ទឹងជ្រៃបាក់ ស្ថិតនៅខេត្តកំពង់ឆ្នាំង។ ការធ្វើដំណាំស្រូវបានផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ពីការធ្វើស្រែវស្សាមួយលើកក្នុងមួយឆ្នាំដោយពឹងផ្អែកលើទឹកភ្លៀង ទៅធ្វើពីរ ឬបីលើកដោយមានការស្រោចស្រព។ ប្រព័ន្ធធារាសាស្ត្រចំនួន ៧កន្លែង – ៣ នៅតំបន់ខ្សែទឹកលើ, ១ នៅកណ្តាល, និង ៣ នៅតំបន់ខ្សែទឹកក្រោម – បានទាញយកទឹកពីស្ទឹងជ្រៃបាក់ ជាសំខាន់សម្រាប់ស្រូវប្រាំង (រូបភាព ១)។ កសិករដែលរស់នៅតំបន់ខ្សែទឹកក្រោមភាគច្រើនប្រកបមុខរបរធ្វើស្រែប្រាំង ដោយពឹងផ្អែកទាំងស្រុងលើការស្រោចស្រព ដោយយកទឹកពីប្រព័ន្ធធារាសាស្ត្រ ព្រោះតំបន់នោះ ត្រូវទឹកទន្លេសាបជន់លិចពេញមួយរដូវវស្សា។ ផ្ទៃដីស្រោចស្រពស្រូវប្រាំង ដែលចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ បានបណ្តាលឲ្យខ្វះខាតទឹកស្រោចស្រព។ ការខ្វះខាតទឹកស្រោចស្រពនេះ ធ្វើឲ្យមានការបារម្ភពី ការបែងចែកទឹកឲ្យមានសមធម៌ ចីរភាពក្នុងការប្រើប្រាស់ទឹក ការប្រទាំងប្រទើសគ្នារវាងសហគមន៍ប្រើប្រាស់ទឹកនៅខ្សែទឹកលើ និងខ្សែទឹកក្រោម និងចីរភាពយូរអង្វែងនៃធនធានទឹក។ ការធ្វើផែនការផ្គត់ផ្គង់ទឹកបែបប្រពៃណី មិនអាចអនុវត្តបន្តទៀតបានទេ។ ការធ្វើផែនការស្រោចស្រព និងប្រតិទិនដាំដុះ ឲ្យស្របតាមបរិមាណទឹកដែលមាន ត្រូវផ្តោតជាសំខាន់លើការគ្រប់គ្រងទឹកផ្អែកលើតម្រូវការវិញ ទើបមានប្រសិទ្ធភាពជាង (Chem, Hirsch and Paradis 2011)។

## ក្របខ័ណ្ឌស្រាវជ្រាវៈ ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ និងប្រព័ន្ធមនុស្ស លើសន្តិសុខទឹក

ដូចមានបង្ហាញក្នុង រូបភាព ២ ក្របខ័ណ្ឌនៃការសិក្សានេះផ្អែកលើទំនាក់ទំនង រវាងការប្រែប្រួលអាកាសធាតុ នឹងសន្តិសុខទឹក។ ក្របខ័ណ្ឌនៃការសិក្សា ពិនិត្យមើលដំណើរការនៃអន្តរអំពើរវាងការប្រែប្រួលអាកាសធាតុ នឹងសកម្មភាពមនុស្សនៅកម្រិតអាងស្ទឹង។ អន្តរអំពើនេះ មានឥទ្ធិពលលើសន្តិសុខទឹក កំណត់នូវភាពងាយរងគ្រោះ និងសមត្ថភាពបន្សាំការប្រែប្រួលអាកាសធាតុ និងសមត្ថភាពទទួលបានទឹកប្រើប្រាស់របស់ប្រជាជន។ ក្របខ័ណ្ឌនៃការសិក្សាបានសន្និដ្ឋានថា អភិបាលកិច្ចទឹកល្អ ដើរតួនាទីសំខាន់ក្នុងការបង្កើន សមត្ថភាពបន្សាំការប្រែប្រួលអាកាសធាតុរបស់ប្រជាជន និងស្ថាប័ន។ ហើយទីបំផុត គេអាចកំណត់បានពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងសកម្មភាពមនុស្សលើសន្តិសុខទឹក និងជីវភាពរស់នៅក្នុងមូលដ្ឋាន និងកំណត់នូវយុទ្ធសាស្ត្របន្សាំនានាសម្រាប់ពេលអនាគត។

## ការប្រែប្រួលប្រព័ន្ធធម្មជាតិ និងប្រព័ន្ធមនុស្ស

សីតុណ្ហភាព និងរបបទឹកភ្លៀងនឹងកើនឡើង។ ការប្រែប្រួលនេះហើយ ដែលបង្កើតជាហានិភ័យនៃគ្រោះធម្មជាតិ ដូចជាទឹកជំនន់រហ័សនិងភាពរាំងស្ងួត។ គ្រោះធម្មជាតិនេះប៉ះពាល់ដល់ជីវិត និងជីវភាពរស់នៅ ដែលមានតឹកតាងកាន់តែច្បាស់លាស់ក្នុងពេលបច្ចុប្បន្ននេះ។ ទឹកជំនន់រហ័សអាចកាន់តែធ្ងន់ធ្ងរឡើងៗ (Eastham et al. 2008)។ ទឹកជំនន់មិនមែនបណ្តាលមកពី

---

អត្ថបទនេះ រៀបចំឡើងដោយ បណ្ឌិត ចែម ផល្លា អ្នកស្រាវជ្រាវ នៃផ្នែកបរិស្ថាន នៃវិទ្យាស្ថាន CDRI។ សូមយោងឯកសារនេះថាៈ Chem P. 2014. “Improved Water Security Increases Adaptive Capacity to Climate Change.” *Cambodia Development Review* 18(4): 6-11.។

រូបភាព ១៖ អាងស្ទឹងជ្រៃបាក់ ខេត្តកំពង់ឆ្នាំង




ប្រភព៖ Chem 2013

ភ្លៀងធ្លាក់កើនឡើងតែម្យ៉ាងនោះទេ ប៉ុន្តែក៏បណ្តាលមកពីសកម្មភាពមនុស្ស ដូចជា ការប្រើប្រាស់ដី និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនានាផងដែរ។ ការបាត់បង់គម្របព្រៃឈើបានធ្វើឲ្យសំណឹកដីកើនឡើង។ ការកសាងទំនប់ធ្វើឲ្យបរិមាណទឹកនៅតំបន់ខ្សែទឹកក្រោមថយចុះ និងខ្វះខាតទឹកស្រោចស្រព។ បញ្ហាធំជាងគេបណ្តាលមកពីការប្រែប្រួលប្រព័ន្ធធម្មជាតិ និងប្រព័ន្ធមនុស្ស គឺ កង្វះទឹកស្រោចស្រពក្នុងរដូវប្រាំងបណ្តាលឲ្យមានការប្រជែងគ្នាតឹងតែង រវាងសហគមន៍ជាវាសាស្ត្រនៅខ្សែទឹកខាងលើ នឹងខាងក្រោម ដើម្បីយកទឹកស្រោចស្រពស្រូវប្រាំងដែលត្រូវតែដោះស្រាយ សម្រាប់ពេលបច្ចុប្បន្ន និងថ្ងៃអនាគត (Chem 2013)។

## សន្តិសុខទឹក

ការទទួលបានទឹកស្អាតគ្រប់គ្រាន់ប្រកបដោយចីរភាព និងមានតម្លៃសមរម្យ ជាកត្តាដ៏សំខាន់ក្នុងទស្សនទានសន្តិសុខទឹក។ ការសិក្សានេះ គណនាបរិមាណទឹកក្នុងអាងស្ទឹងជ្រៃបាក់ ដោយធ្វើម៉ូដែលសម្រាប់វាស់ "កង្វះទឹក" ប្រើប្រាស់ និង "ការខ្សត់ទឹក"។ កង្វះទឹក សំដៅលើការខ្វះខាតទឹកបណ្តាលមកពីកំណើនប្រជាជន និងទាក់ទងនឹងចំនួនមនុស្សត្រូវចែករំលែកទឹកនោះ សម្រាប់ប្រើប្រាស់ និងស្រោចស្រព។ ការខ្សត់ទឹក សំដៅលើកំណើននៃតម្រូវការទឹក និងទាក់ទងជាសំខាន់ទៅនឹងបរិមាណទឹកបូមយកមកប្រើប្រាស់។

តាមនិយមន័យ សន្តិសុខទឹក ផ្តោតលើការទទួលបានទឹកប្រើប្រាស់គ្រប់គ្រាន់ មានតម្លៃទឹកសមរម្យដែលប្រជាជនអាចប្រើប្រាស់បាន សម្រាប់បំពេញតម្រូវការរបស់មនុស្ស និងសុខភាពអេកូឡូស៊ី (Cook and Bakker 2012)។ ទស្សនទានសន្តិសុខទឹក គ្របដណ្តប់លើរូបភាពជាច្រើននៃ ការទទួលបានទឹកប្រើប្រាស់គ្រប់គ្រាន់ សម្រាប់សន្តិសុខស្បៀង និងការរីកចម្រើនរបស់មនុស្សជាតិ។ ការសម្រេចបានគោលដៅសន្តិសុខទឹក ត្រូវមាន ១) ឧបករណ៍ធ្វើម៉ូដែលសម្រាប់គណនាបរិមាណទឹក និងវាស់គុណភាពទឹក និង ២) អភិបាលកិច្ចទឹកល្អដែលអាចធានាឲ្យមានទឹកប្រើប្រាស់គ្រប់ៗគ្នា ប្រកបដោយសមធម៌ក្នុងការទទួលបានទឹក និង ការប្រើប្រាស់ទឹកប្រកបដោយចីរភាព។

សន្តិសុខទឹក ក៏ផ្តោតផងដែរ ទៅលើគ្រោះថ្នាក់ផ្សេងៗដែលទាក់ទងនឹងទឹក ដូចជា ការបំពុល ទឹកជំនន់ ភាពរាំងស្ងួត និងបរិស្ថានល្អនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជាដើម។ ដើម្បីជាកិច្ចការពារប្រព័ន្ធទឹកពីគ្រោះថ្នាក់ និងធានានូវមុខងារ និងសេវាកម្មទឹក ទស្សនទានសន្តិសុខទឹកបានដាក់បញ្ចូលនូវវិធានការបង្ការ ការវាយតម្លៃលើការបំពុលទឹក និងការការពារប្រព័ន្ធទឹកដែលងាយខូចខាត។

## ភាពងាយរងគ្រោះទៅនឹងការប្រែប្រួលប្រព័ន្ធធម្មជាតិ-មនុស្ស

ទស្សនទាននៃការប្រែប្រួលអាកាសធាតុ បានកំណត់ថាភាពងាយរងគ្រោះបណ្តាលមកពី ការប្រែប្រួលអាកាសធាតុ

រូបភាព ២៖ ក្របខ័ណ្ឌគោលគំនិតពី ផលប៉ះពាល់នៃការប្រែប្រួលធម្មជាតិ និងប្រព័ន្ធមនុស្ស ទៅលើសន្តិសុខទឹក




ប្រភព៖ CDRI 2012

វាផ្សារភ្ជាប់ជាមួយកត្តាបី៖ ភាពប្រឈម (exposure) ភាពរស់ (sensitivity) និងសមត្ថភាពបន្សាំ (adaptive capacity)។ ការសិក្សានេះ បានកំណត់និយមន័យនៃការប្រើពាក្យទាំងបីនេះ ស្របតាមការកំណត់ន័យដោយ ក្រុមជំនាញការអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC 2001)។[១]

***ភាពប្រឈម៖*** "លក្ខណៈ និងកម្រិតដែលប្រព័ន្ធមួយត្រូវរងឥទ្ធិពលពីការប្រែប្រួលគួរឲ្យកត់សំគាល់នៃអាកាសធាតុ" (p. 987)។

***ភាពរស់៖*** "កម្រិត ដែលប្រព័ន្ធណាមួយទទួលរងផលប៉ះពាល់ល្អ ឬអាក្រក់ពីការប្រែប្រួលអាកាសធាតុ" (p. 993)។

***សមត្ថភាពបន្សាំ៖*** "សមត្ថភាពដែលប្រព័ន្ធណាមួយអាចសម្រប ខ្លួនជាមួយនឹងការប្រែប្រួលអាកាសធាតុ (រាប់ទាំងការប្រែប្រួលធាតុអាកាស និងភាពធ្ងន់ធ្ងររបស់វាផង) ដើម្បីជំនះលើផលវិបាកនៃការប្រែប្រួលអាកាសធាតុ" (p. 982)។

## លទ្ធផល និងការពិភាក្សា

### *ភាពប្រឈម*

អាងស្ទឹងជ្រៃបាក់ ចែកចេញជា ៣តំបន់ខុសគ្នា៖ តំបន់ខ្សែទឹកលើ តំបន់កណ្តាល និង តំបន់ខ្សែទឹកក្រោម។ កម្រិតនៃភាពប្រឈមចំពោះការប្រែប្រួលអាកាសធាតុ គឺខុសៗគ្នាទៅតាមតំបន់នីមួយៗ។ សហគមន៍នៅខ្សែទឹកលើ និងតំបន់កណ្តាល ប្រឈមមុខនឹងទឹកជំនន់រហ័ស។ រីឯតំបន់ខ្សែទឹកក្រោមប្រឈមនឹងទឹកជំនន់រយៈពេលពេញមួយរដូវវស្សា ដែលបណ្តាលមកពីទឹកជំនន់ធម្មតារបស់ទន្លេសាប។ តំបន់ទាំងបីនេះ ប្រឈមមុខនឹងភាពរាំងស្ងួតដូចៗគ្នា។

ការសិក្សាពីការប្រែប្រួលរបបទឹកភ្លៀង នៅខេត្តកំពង់ឆ្នាំង ដោយ វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល បានរកឃើញថា នៅដើមសតវត្សរ៍ទី២០ មានភ្លៀងធ្លាក់ច្រើនបំផុតក្នុងខែកញ្ញា ប៉ុន្តែនៅចុងសតវត្សរ៍ទី២០ មានភ្លៀងធ្លាក់ច្រើនបំផុតក្នុងខែតុលាវិញ។ តាំងពីចុងសតវត្សទី២០មក ទឹកភ្លៀងប្រចាំខែនៅរដូវប្រាំង បានធ្លាក់ចុះ ជាពិសេសក្នុងខែមករា កុម្ភៈ វិច្ឆិកា និងធ្នូ (Ham and Someth ជិតចេញផ្សាយ)។

ការសិក្សារបស់ Chem (2013) បានប្រើប្រាស់ទិន្នន័យអង្កេតពីកម្ពស់ទឹកស្ទឹងដើម្បីគណនាធារទឹក ហើយរកឃើញថា ធារទឹកអតិបរមាក្នុងអាងស្ទឹងជ្រៃបាក់ កើតមានក្នុងខែតុលា ដូចគ្នានឹងការរកឃើញរបស់ វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលដែរ។ ក្រៅពីការប្រែប្រួលអាកាសធាតុ សកម្មភាពមនុស្សក៏ធ្វើឲ្យប្រែប្រួលគម្របដី ក្នុងតំបន់អាងស្ទឹងដែរ។ កំណើនផ្ទៃដីស្រោចស្រព និងនគរូបនីយកម្ម បានបង្កើនតម្រូវការទឹក។

---
១ ក្នុងនិយមន័យដូចតទៅនេះ "ប្រព័ន្ធ" សំដៅដល់ទាំងប្រព័ន្ធមនុស្ស និងប្រព័ន្ធធម្មជាតិ។

រូបភាព ៣៖ លំហូរទឹកស្ទឹងជ្រៃបាក់ ឆ្នាំ២០០៧-០៨







ប្រភព៖ Chem 2013

ការបាត់បង់ព្រៃឈើបានបង្កើនសំណឹកដី ធ្វើឲ្យអាងស្តុកទឹកធារាសាស្ត្រកករាក់ និងបង្កកំណើនល្បឿនទឹកជំនន់រហ័ស។ ប្រជាជននៅអាងស្ទឹងជ្រៃបាក់ ត្រូវប្រឈមចំពោះបញ្ហាកង្វះទឹកផង និងការខ្សត់ទឹកផង។

## ភាពរស់

សហគមន៍នៅតំបន់ខ្សែទឹកលើ ធ្វើតែស្រែវស្សាប៉ុណ្ណោះ។ សហគមន៍នៅតំបន់កណ្តាល ភាគច្រើនធ្វើស្រែវស្សា ស្រូវបង្កើនរដូវ និងធ្វើស្រែប្រាំងខ្លះដែរ (គម្រោងប្រព័ន្ធស្រោចស្រពនៅតាំងក្រសាំង)។ សហគមន៍នៅខ្សែទឹកខាងក្រោម ភាគច្រើនធ្វើស្រែប្រាំង។ កំណើនប្រជាជន នាំឲ្យតម្រូវការស្បៀងអាហារកើនឡើង និងនាំឲ្យកសិករពង្រីកដីសម្រាប់ការដាំដុះនៅរដូវប្រាំង។ មុនឆ្នាំ១៩៩០ ពុំមានការធ្វើស្រែប្រាំងទេ ប៉ុន្តែក្រោយមកការធ្វើស្រែប្រាំងបានកើនឡើង។ ផ្ទៃដីដាំស្រូវសរុប មានជាង ១ម៉ឺនហិកតា (១០.៣៧០ ហិកតា) ក្នុងពេលបច្ចុប្បន្ននេះមាន ៧៤០ហិកតា ជាស្រែប្រាំង។ យើងបានប៉ាន់ស្មានថា ផ្ទៃដីស្រូវប្រាំងពង្រីកប្រហែល ៥% ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ១៩៩២ មក ជាពិសេស នៅវាលទំនាបទឹកលិចនៃតំបន់ខ្សែទឹកក្រោម ដែលដីនៅទីនោះ មានជីជាតិច្រើន និងផ្តល់ទិន្នផលខ្ពស់។ និន្នាការកំណើននេះ បានបង្កើនតម្រូវការទឹកស្រោចស្រពនៅក្នុងអាងស្ទឹងយ៉ាងឆាប់រហ័ស ជាហេតុនាំឲ្យការរៀបចំផែនការគ្រប់គ្រង និងបែងចែកទឹក ដើរមិនទាន់សភាពការណ៍ទេ ហើយជាទូទៅកសិករប្រើប្រាស់ទឹកដែលមានទាំងអស់ សម្រាប់ស្រោចស្រពស្រូវប្រាំង ដោយមិនបានគិតគូរពីតម្រូវការធារទឹកបរិស្ថានឡើយ។

សេវាប្រព័ន្ធអេកូឡូស៊ី (ជាពិសេសត្រី) បានថយចុះ ឬប្រើប្រាស់ដោយគ្មានចីរភាព។ សំណឹកដីខ្លាំង នាំឲ្យកំណកល្បាប់បំពេញអាងស្តុកទឹកនៃប្រព័ន្ធធារាសាស្ត្រកើនឡើង ហើយកាត់បន្ថយសមត្ថភាពស្តុកទឹកប្រចាំឆ្នាំរបស់អាង។ ធារទឹកមានត្រឹមតែ ៤លានម៉ែត្រគូបប៉ុណ្ណោះ ក្នុងខែមីនា។ ក្នុងអំឡុងពេលនោះ ការខ្សត់ទឹកមានលក្ខណៈធ្ងន់ធ្ងរជាងគេ ស្របពេលដែលតម្រូវការទឹកស្រោចស្រពក្នុងខែនេះ កើនខ្ពស់បំផុត។ ស្ថានភាពនេះ នាំឲ្យមានការខូចខាតផលស្រូវមួយចំនួន និងទំនាស់កាន់តែតឹងតែងលើការប្រើប្រាស់ទឹក។

កង្វះខាតទឹក ទោះបីបណ្តាលមកពី ការខ្សត់ទឹកសេដ្ឋកិច្ច[២] ឬការខ្សត់ទឹករូបវ័ន្ត[៣] ក្តី វាជាឧបសគ្គចម្បងមួយក្នុងការធ្វើស្រែរដូវប្រាំង (រូបភាព ៣)។ ភ្លៀងមូសុង បានផ្តល់ទឹកយ៉ាងសម្បូរក្នុងខែកញ្ញា និងតុលា ប៉ុន្តែកសិករប្រឈមនឹងការរាំងស្ងួតបែបធម្មជាតិ (ភ្លៀងតិច) ក្នុងខែមិថុនា និងកក្កដា។ កសិករនៅខ្សែទឹកលើ និងតំបន់កណ្តាល ត្រូវការទឹកបន្ថែមពីប្រព័ន្ធស្រោចស្រពក្នុងខែទាំងនេះ។

ភាពរាំងស្ងួត បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការធ្វើស្រែប្រាំង។ ក្នុងឆ្នាំទឹកតូច កសិករនៅត្រពាំងត្របែក (ប្រព័ន្ធធារាសាស្ត្រទី៧ ក្នុង រូបភាព ១) អាចចាប់ផ្តើមព្រោះស្រូវប្រាំងតាំងពីដើមដែ នៅដើមខែវិច្ឆិកា។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ប្រព័ន្ធធារាសាស្ត្រនេះ នៅតែធ្លាប់ជួបកង្វះទឹកធ្ងន់ធ្ងរ ក្នុងខែកុម្ភៈ និងមីនា ស្ទើរតែជារៀងរាល់ឆ្នាំ។ ផ្ទុយទៅវិញ ក្នុងឆ្នាំទឹកធំ ដោយសារធារទឹកស្ទឹងអតិបរមាក្នុងខែតុលា រីឯទឹកជំនន់ទន្លេសាបក៏ស្រកចុះយឺត ធ្វើឲ្យកសិករនៅប្រព័ន្ធធារាសាស្ត្រទី៧ ត្រូវពន្យាពេលដាំដុះ (ទៅចុងខែវិច្ឆិកា) ហើយពួកគាត់នៅតែជួបបញ្ហាកង្វះទឹក ក្នុងខែកុម្ភៈ និងមីនា ប៉ុន្តែអាចតិចតួចជាងឆ្នាំទឹកតូច។ ចំណុចនេះបង្ហាញពីសារៈសំខាន់នៃការព្យាករណ៍អាកាសធាតុ និងរបបជលសាស្ត្រអាងស្ទឹង ដែលអាចផ្តល់ព័ត៌មានដល់សហគមន៍កសិករប្រើប្រាស់ទឹក ឲ្យបានជ្រាបពីរបបជលសាស្ត្រអាងស្ទឹង ដើម្បីពួកគាត់អាចធ្វើផែនការប្រតិទិនដាំដុះ ឲ្យស្របតាមរបបជលសាស្ត្រ និងបរិមាណទឹកដែលមាន។

## សមត្ថភាពបន្សាំ

ទឹកជាធនធានសំខាន់បំផុត សម្រាប់ការចិញ្ចឹមជីវិតរបស់កសិករ។ អ្នករស់នៅតំបន់ខ្សែទឹកក្រោម យល់ដឹងច្រើនពីរបៀបគ្រប់គ្រង និងការប្រើប្រាស់ទឹកស្រោចស្រព។ ពួកគាត់អាចទទួលបានសេវាស្រោចស្រព និងមានបទពិសោធន៍ក្នុងការទប់ទល់នឹងគ្រោះរាំងស្ងួត។ ប៉ុន្តែកិច្ចសហការគ្នាគ្រប់គ្រងធនធានទឹក រវាង

២ ការខ្សត់ទឹកសេដ្ឋកិច្ច សំដៅលើកង្វះទឹក បណ្តាលពីកង្វះវិនិយោគទុនលើហេដ្ឋារចនាសម្ព័ន្ធទឹក ដើម្បីទាញយកទឹកមកប្រើប្រាស់។

៣ ការខ្សត់ទឹករូបវ័ន្ត សំដៅដល់ កង្វះទឹកនៅក្នុងអាង។

តំបន់នៅខ្សែទឹកលើ នឹងខ្សែទឹកក្រោម នៅតែជាបញ្ហាប្រឈមមួយយ៉ាងធំ សម្រាប់អ្នកគ្រប់គ្រងប្រព័ន្ធស្រោចស្រព និង សហគមន៍កសិករប្រើប្រាស់ទឹក (FWUCs)។ ដើម្បីជួយទប់ទល់នឹងទឹកជំនន់ គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយ (CDM) បានដំណើការនៅថ្នាក់រដ្ឋបាលទាំងបួន គឺ ថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក និង ថ្នាក់ភូមិឃុំ។ មន្ទីរធនធានទឹក និងឧតុនិយមខេត្ត ក៏ដើរតួនាទីយ៉ាងសំខាន់ ក្នុងការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត។ ស្ថាប័នថ្នាក់ក្រោមជាតិទាំងនេះ មានផែនការត្រៀមទប់ទល់ជាបន្ទាន់ នឹងគ្រោះមហន្តរាយផ្សេងៗ ប៉ុន្តែសមត្ថភាពនៅទាប និងធនធានហិរញ្ញវត្ថុមានកម្រិត បានរារាំងពួកគាត់ ក្នុងការឆ្លើយតបឲ្យបានលឿន និងគ្រប់គ្រាន់ ទៅនឹងភាពបន្ទាន់នៃការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ការឆ្លើយតបអន់ខ្សោយ អាចមើលឃើញច្បាស់នៅតាមសហគមន៍មូលដ្ឋាន ដែលមានសមត្ថភាពបន្សាំនៅទន់ខ្សោយ និងចំណេះដឹងតិច ស្តីពីជម្រើសផ្សេងៗនៃការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

## សន្និដ្ឋាន៖ ការប្រឈមនាបច្ចុប្បន្ន និងនៅអនាគត

អាងស្ទឹងជ្រៃបាក់ ត្រូវប្រឈមនឹងភាពរាំងស្ងួត ច្រើនជាងទឹកជំនន់។ គ្រោះរាំងស្ងួតសឹងតែបានក្លាយជាបញ្ហាប្រចាំឆ្នាំទៅហើយ។ កសិករភាគច្រើន បានខូចខាតផលស្រូវ និងទទួលបានទិន្នផលទាប ហើយគ្រោះថ្នាក់បែបនេះបានកើតមានកាន់តែញឹកញាប់។ ធនធានទ្រទ្រង់ការចិញ្ចឹមជីវិត ដូចជា ទឹក ដី ព្រៃឈើ និងត្រី ងាយទទួលរងជាខ្លាំងនូវឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ និងសកម្មភាពមនុស្ស ហើយសមត្ថភាពបន្សាំការប្រែប្រួលអាកាសធាតុរបស់ប្រជាជន ក៏នៅទាប។

បណ្តាឃុំនៅតំបន់ខ្សែទឹកលើ ធ្លាប់ជួបប្រទះទឹកជំនន់រហ័ស រីឯនៅតំបន់ខ្សែទឹកក្រោម នៅជិតវាលទំនាបទឹកលិចបឹងទន្លេសាប ទទួលរងការប៉ះពាល់ដោយទឹកពីទន្លេសាបជន់លិច។ ទោះបីប្រជាជនជាច្រើន បានរាយការណ៍ពីការប៉ះពាល់ដោយគ្រោះរាំងស្ងួត ប៉ុន្តែមានតិចនាក់ណាស់ដែលយល់ដឹងថាគ្រោះរាំងស្ងួតកើតឡើងមួយផ្នែកមកពីការប្រែប្រួលអាកាសធាតុ ឬការខូចខាតបរិស្ថាន ដែលនាំឲ្យមានទឹកជំនន់ផងដែរ។ ការយល់ដឹងរបស់សហគមន៍មូលដ្ឋាន ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅមានកម្រិតនៅឡើយ។

កង្វះទឹក និងការខ្សត់ទឹក ជាមូលហេតុចម្បងនៃទិន្នផលស្រូវទាប។ ដីស្រែនៅតំបន់ខ្សែទឹកលើ (ជាពិសេស នៅតាំងក្រសាំង) មិនសូវជួបការលំបាកទេក្នុងបញ្ហាការផ្គត់ផ្គង់ទឹក។ ប៉ុន្តែតំបន់ធំៗ នៅខ្សែទឹកក្រោម (ប្រព័ន្ធធារាសាស្ត្រជ្រៃបាក់ និងត្រពាំងត្របែក) ត្រូវប្រឈមនឹងកង្វះទឹកពិតប្រាកដ។

ទំនប់ សំណង់ធារាសាស្ត្រផ្សេងៗទៀត និងប្រព័ន្ធប្រឡាយ មានតួនាទីយ៉ាងសំខាន់ ក្នុងការស្តុក បញ្ជូ និងបែងចែកទឹកស្រោចស្រព។ ប៉ុន្តែប្រព័ន្ធធារាសាស្ត្រទាំងនោះ មានសំណង់សិល្បៈការមិនគ្រប់គ្រាន់ទេ។ ក្រៅពីហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត អភិបាលកិច្ចទឹកក្នុងអាងស្ទឹងដើរតួនាទីសំខាន់ ក្នុងការផ្គត់ផ្គង់ទឹកសម្រាប់សហគមន៍ដែលត្រូវការវា–តាំងពីការស្តុក និងការបញ្ជូនទឹកដោយប្រើហេដ្ឋារចនាសម្ព័ន្ធ និងធនធានហិរញ្ញវត្ថុឲ្យបានប្រសើរបំផុត រហូតដល់ការបែងចែកទឹកប្រកបដោយយុត្តិធម៌ និងការប្រើប្រាស់ប្រកបដោយចីរភាព។ ម្យ៉ាងទៀតអភិបាលកិច្ចទឹកនៅអាងស្ទឹងជ្រៃបាក់មានភាពទន់ខ្សោយនៅឡើយ ហើយមកទល់ពេលនេះ មិនបានជួយសម្របសម្រួលឲ្យមានសេចក្តីសម្រេចចិត្តជាសមូហភាព ហើយមិនទាន់បានទទួលស្គាល់ពីផលវិបាកផ្សេងៗ នៃការប្រែប្រួលប្រព័ន្ធមនុស្ស និងប្រព័ន្ធធម្មជាតិ ទៅលើការគ្រប់គ្រងធនធានទឹកនោះទេ។

អវត្តមាន គណៈកម្មការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រអាងស្ទឹង (CIMC) សម្រាប់គ្រប់គ្រងការបែងចែកទឹកប្រើប្រាស់ឲ្យបានសមស្រប បានបង្កភាពរកេតរកូតក្នុងការគ្រប់គ្រងទឹកស្រោចស្រព និងពុំមានការបែងចែកទឹកដោយស្មើភាពគ្នា រវាងប្រព័ន្ធស្រោចស្រពទាំង៧។ ស្ថានភាពនេះនាំឲ្យមានការប្រជែងយកទឹកកាន់តែតឹងតែង រវាងក្រុមអ្នកប្រើប្រាស់ទឹកនៅតំបន់កណ្តាល នឹងតំបន់ខ្សែទឹកក្រោម។ ក្នុងករណីនេះ តួនាទីចម្បងនៃ CIMC គឺបង្កើតផែនការបែងចែកទឹកស្រោចស្រពឲ្យវាសមាមាត្រល្អទៅនឹងទំហំនៃតំបន់ស្រោចស្រពទាំង៧ និងសម្រេចបានការប្រើប្រាស់ទឹកប្រសើរបំផុត ទាំងសម្រាប់សហគមន៍នៅខ្សែទឹកលើ និងនៅខ្សែទឹកក្រោម។

រូបភាព ៤៖ ស្ថាប័នគ្រប់គ្រងអាងស្ទឹងដែលអាចចូលរួមក្នុង CIMC




កត់សម្គាល់៖ FAC=រដ្ឋបាលជលផល;
PDAFF=មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត;
PDLMUP=មន្ទីររៀបចំដែនដី នគរូបនីយកម្មខេត្ត;
PDOE=មន្ទីរបរិស្ថានខេត្ត;
PDOWRAM=មន្ទីរធនធានទឹក និងឧតុនិយមខេត្ត;
PDRD=មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត;
TWC=គណៈកម្មការការងារបច្ចេកទេស

ប្រភព៖ Chem 2013

## អនុសាសន៍

ការយល់ដឹងកាន់តែប្រសើរពី របបជលសាស្ត្រអាងស្ទឹង អាចជួយឲ្យអ្នកគ្រប់គ្រងទឹកនៅមូលដ្ឋាន កែលំអការគ្រប់គ្រងប្រព័ន្ធស្រោចស្រព និងធ្វើផែនការឲ្យកាន់តែប្រសើរជាងមុន។ កិច្ចសម្ភាសជាមួយកសិករ និងសមាជិក FWUC បានបង្ហាញនូវតម្រូវការបន្ទាន់ដើម្បីបង្កើត CIMC ហើយឈានចេញពីការគ្រប់គ្រងប្រព័ន្ធស្រោចស្រពមួយៗដាច់ពីគ្នា ដូចកំពុងអនុវត្តសព្វថ្ងៃ ទៅកាន់ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រអាងស្ទឹង។

CIMC តែមួយ ពុំមានសមត្ថភាពអនុវត្តមុខងាររបស់ខ្លួនក្នុងការសម្របសម្រួលការធ្វើផែនការបានទេ បើគ្មានការចូលរួមពេញលេញពី ស្ថាប័នទាំងអស់ដែលពាក់ព័ន្ធការគ្រប់គ្រងទឹកក្នុងអាងស្ទឹងនោះ (រូបភាព ៤)។ ដើម្បីសម្រេចការងារឲ្យបានស្ថាប័នទាំងនេះ ត្រូវមានព័ត៌មានថ្មីទាន់ហេតុការណ៍ផ្អែកធារាសាស្ត្រ ដើម្បីយល់ដឹងបានពេញលេញពី ការចាំបាច់ត្រូវធ្វើផែនការរួមគ្នាអំពីការប្រើទឹក និងដាំដុះ តាំងពីប្រព័ន្ធធារាសាស្ត្រទី១ ដល់ទី៧។

ការប្រមូលថ្លៃសេវាស្រោចស្រពបានតិច សម្រាប់កិច្ចដំណើរការ និងការថែទាំ ជាក្តីបារម្ភធំមួយទៀតរបស់ FWUCs។ ក្នុងន័យនេះ CMIC នឹងជួយកែលំអការសម្របសម្រួល ហើយធានាឲ្យប្រព័ន្ធស្រោចស្រពនីមួយៗ ទទួលបានទឹកគ្រប់គ្រាន់នៅពេលមានតម្រូវការ។ ការទទួលបានការផ្គត់ផ្គង់ទឹកដែលអាចទុកចិត្តបាន នឹងលើកទឹកចិត្តកសិករឲ្យបង់ថ្លៃសេវាស្រោចស្រពបានត្រឹមត្រូវ។

ស្ថាប័ន CIMC ដែលគេស្នើឲ្យបង្កើតនេះ នឹងជួយសម្របសម្រួលការប្រមូល និងចែករំលែកទិន្នន័យផ្អែកជលសាស្ត្រ ដើម្បីផ្តល់ព័ត៌មានដល់សេចក្តីសម្រេចក្នុងការបែងចែកទឹក និងបន្សីផែនការដាំដុះ រវាងតំបន់ស្រោចស្រពនៅខ្សែទឹកលើ និងខ្សែទឹកក្រោម។ ប្រព័ន្ធស្រោចស្រពអាចផ្តល់អត្ថប្រយោជន៍បានច្រើនថែមទៀត ប្រសិនបើមានការអនុវត្តបានជោគជ័យនូវការសម្របសម្រួលនៅថ្នាក់លើស្តីពី ការធ្វើផែនការដាំដុះ និងបែងចែកទឹក រវាង FWUCs ក្រុមប្រឹក្សាសហគមន៍ នឹងមន្ត្រីថ្នាក់ស្រុក។ ដោយមានព័ត៌មានអាចទុកចិត្តបាន ស្តីពី ការបែងចែកទឹកទៅតាមកន្លែងផ្សេងៗ និងតាមពេល CIMC អាចជួយធានាថាទាំងកសិករនៅខ្សែទឹកលើ និងខ្សែទឹកក្រោម នឹងទទួលបានការផ្គត់ផ្គង់ទឹកប្រកបដោយសមធម៌ ជាពិសេស នៅពេលមានទឹកតិច។

ការដាំស្រូវប្រាំង គួរធ្វើផែនការដោយផ្អែកលើព័ត៌មានធារាសាស្ត្រ។ ធារទឹកតិចបំផុតក្នុងខែមីនា (៤លានម៉ែត្រគូប) នាំឲ្យមានកង្វះទឹកធ្ងន់ធ្ងរនៅតំបន់ខ្សែទឹកក្រោម ដូចជា ប្រព័ន្ធស្រោចស្រពនៅ តាំងក្រសាំង ជ្រៃបាក់ និងត្រពាំងត្របែក។ ដូច្នេះត្រូវប្រឹងប្រែងឲ្យបានខ្លាំង ក្នុងកិច្ចសម្របសម្រួលរវាងប្រព័ន្ធស្រោចស្រពទាំងនេះ ដើម្បីញុាំងឲ្យតម្រូវការស្រោចស្រពទាំងក្នុងពេលបច្ចុប្បន្ន និងទៅអនាគត វាស្របតាមបរិមាណទឹកដែលមាន។ ការដាំដុះ គួរធ្វើការកែតម្រូវពីមួយឆ្នាំទៅមួយឆ្នាំឲ្យស្របទៅនឹងរបបទឹកភ្លៀង (បរិមាណ និងពេលវេលា) ក្នុងតំបន់នៅខ្សែទឹកលើ និង របបទឹកជំនន់ពីបឹងទន្លេសាប (តូច ឬធំ) នៅតំបន់ខ្សែទឹកក្រោម។ កាលវិភាគដាំដុះ គួរធ្វើឡើងដោយផ្អែកលើព័ត៌មានជលសាស្ត្រ។ ចំណុចសំខាន់មួយ គឺ ផ្ទៃដីដាំដុះស្រូវប្រាំង ក្នុងប្រព័ន្ធស្រោចស្រពទាំង៣ មិនគួរលើសពី ៧៤០ហិកតា ឡើយ បើមិនដូច្នេះទេ អាចជួបនឹងកង្វះទឹកធ្ងន់ធ្ងរ និងការខូចខាតផលដំណាំ។

## ឯកសារយោង


CDRI, Cambodia Development Resource Institute. 2012. "Climate Change and Water Governance in Cambodia." *Cambodia Development Review* 16(4): 1-5.

Chem Phalla, Philip Hirsch and Someth Paradis. 2011. *Hydrological Analysis in Support of Irrigation Management: A Case Study of Stung Chrey Bak Catchment, Cambodia*. Working Paper Series No. 59. Phnom Penh: CDRI.

Chem Phalla. 2013. *Integrated Catchment Management and Irrigation Development: The Role of Hydrological Analysis in Improved Water Governance in Cambodia*, School of Geoscience, Faculty of Science, University of Sydney, Sun Heang Printing House, Cambodia.

Cook, Christina, and Karen Bakker. 2012. "Water Security: Debating an Emerging Paradigm." *Global Environmental Change* 22:8.

Eastham, Judy, Freddie Mpelasoka, Mohammed Mainuddin, Catherine Ticehurst, Peter Dyce, Geoff Hodgson, Riasat Ali and Mac Kirby. 2008. "Mekong River Basin Water Resources Assessment: Impacts of Climate Change." In *Water for a Healthy Country Flagship Report*, edited by CSIRO: Water for a Healthy Country National Research Flagship.

Ham K and Someth P. Forthcoming. "Impacts of Social-Ecological Change on Farming Practices in the Stung Chreybak Catchment, Kampong Chhnang, Cambodia." In *Learning for Resilience: Insights from Cambodia's Rural Communities*, edited by J.-C. Diepart. Phnom Penh: The Learning Institute.

IPCC, Intergovernmental Panel on Climate Change. 2001. "Climate Change 2001: Impacts, Adaptation and Vulnerability." In *Contribution of Working Group II to the Third Assessment Report of the Intergovernmental Panel on Climate Change*. Cambridge: Cambridge University Press.

# ការងារ ១០ឆ្នាំ នៅវិទ្យាស្ថាន CDRI នៅកម្ពុជា – ការពិចារណាផ្ទាល់ខ្លួនលើបទពិសោធន៍នេះ

## សេចក្តីផ្តើម៖ ការរក្សាតុល្យភាពរវាងលក្ខណៈឯករាជ្យ នឹងការចូលពាក់ព័ន្ធ

អស់រយៈពេលជាង១០ឆ្នាំ ក្នុងដំណែងជានាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI ខ្ញុំបានទទួលការអញ្ជើញជាច្រើនលើក ទាំងនៅកម្ពុជា និងប្រទេសផ្សេងទៀតក្នុងតំបន់អាស៊ី ឲ្យធ្វើបទបង្ហាញស្តីពី ប្រទេសកម្ពុជា និងការអភិវឌ្ឍ។ ជារឿយៗខ្ញុំចាប់ផ្តើមបទបង្ហាញដោយនិយាយថា "ក្នុងការសិក្សាអន្តរជាតិស្តីអភិវឌ្ឍន៍ គេតែងពណ៌នាកម្ពុជាថាជា ប្រទេសលូតលាស់តិចជាងគេទើបបញ្ចប់ទំនាស់ និងពឹងផ្អែកលើជំនួយ ដែលសុទ្ធតែជាការវាយតម្លៃអវិជ្ជមាន។ តទៅនេះ ខ្ញុំសូមបង្ហាញពីរូបភាពមានតុល្យភាពល្អគួរសមមួយ នៃសមិទ្ធផលអភិវឌ្ឍន៍គួរឲ្យកត់សំគាល់របស់កម្ពុជាក្នុងសម័យថ្មី ក្រោយពេលទទួលបានសន្តិភាព និងស្ថិរភាពក្នុងឆ្នាំ១៩៩៨ ព្រមទាំងបញ្ហាប្រឈមជាច្រើនដែលត្រូវដោះស្រាយ។" ការតាំងចិត្តធ្វើការស្រាវជ្រាវមានការថ្លឹងថ្លែងល្អផ្អែកលើភស្តុតាង មានការវិភាគត្រឹមត្រូវ និងមានការចូលរួមជាលក្ខណៈកសាង បានកំណត់នូវវិធីសាស្ត្ររបស់ខ្ញុំ ក្នុងការដឹកនាំ CDRI ។

វិធីសាស្ត្រនេះ បានទទួលការបញ្ជាក់គាំទ្រពីការវាយតម្លៃដោយឯករាជ្យ អនុវត្តឡើងដោយក្រុមទីប្រឹក្សានៃទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) សម្រាប់ការត្រួតពិនិត្យពាក់កណ្តាលអាណត្តិលើកម្មវិធីរយៈពេលប្រាំឆ្នាំ (២០១១-១៦) នៃជំនួយទ្រទ្រង់ និងភាពជាដៃគូជាមួយវិទ្យាស្ថាន CDRI (www.sida.se/publications)។ លទ្ធផលរកឃើញដ៏សំខាន់មួយផ្អែកលើការវាយតម្លៃពីផលិតផល សកម្មភាព និងប្រព័ន្ធស្រាវជ្រាវផ្អែកគោលនយោបាយរបស់ CDRI និងបទសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធ ២៥រូប មកពីជួររដ្ឋាភិបាល ដៃគូអភិវឌ្ឍ មជ្ឈដ្ឋានសិក្សា សហគមន៍ស្រាវជ្រាវ វិស័យឯកជន និង សង្គមស៊ីវិលបង្ហាញថា CDRI "រក្សាបានល្អនូវតុល្យភាពរវាងឯករាជ្យ នឹងការចូលរួមពាក់ព័ន្ធ" ហើយគេមើលឃើញ CDRI ជាតួអង្គដ៏សំខាន់ក្នុងការជជែកវែកញែកផ្អែកគោលនយោបាយ ក្នុងបរិយាកាសនយោបាយមួយដ៏ស្មុគស្មាញ។ គេបានរកឃើញ ដូច្នេះ ទាំងនៅក្នុងផលិតផលស្រាវជ្រាវ វេទិកាសាធារណៈ និងក្នុងកិច្ចសន្ទនាជាមួយរដ្ឋាភិបាល និងអ្នកមានឥទ្ធិពលនានាដែលជាប់ពាក់ព័ន្ធនឹងការអភិវឌ្ឍប្រទេសកម្ពុជា។

ពិនិត្យលើ បទពិសោធន៍មួយទសវត្សរ៍កន្លងទៅរបស់រូបខ្ញុំជាមួយ CDRI គឺមាន ៣ចំណុច លេចធ្លោជាងគេ៖ (១) ល្បឿននៃកំណើន និងការផ្លាស់ប្តូរសម្រាប់ទាំងកម្ពុជា និង CDRI, (២) បទសោធន៍សំខាន់ៗមួយចំនួនអំពី ភាពជាដៃគូពិតៗ, ការកសាងសមត្ថភាពស្ថាប័នពិតៗ និងសង្គមស៊ីវិលពិតៗ និង (៣) បែបទដែលទិដ្ឋភាពនៃការអភិវឌ្ឍបច្ចុប្បន្ន និងទៅអនាគតរបស់ CDRI ត្រូវជាប់ពាក់ព័ន្ធកាត់មិនដាច់ជាមួយតំបន់ជុំវិញពោលគឺ មហាអនុតំបន់មេគង្គ អាស៊ាន អាស៊ីខាងកើត និងតំបន់ក្រៅពីនេះទៀត។

## កំណើន និងការផ្លាស់ប្តូរក្នុងមួយទសវត្សរ៍ —សម្រាប់កម្ពុជា និងសម្រាប់ CDRI

ក្នុងរយៈមួយទសវត្សរ៍ពីឆ្នាំ២០០៤ ដល់ ២០១៤ មានការផ្លាស់ប្តូរគួរឲ្យកត់សំគាល់ ទាំងនៅកម្ពុជា និងនៅ CDRI។ ក្នុងពិធីអបអរសាទរការផ្ទេរតំណែងថ្នាក់ដឹកនាំរបស់ CDRI ក្នុងខែកញ្ញាកន្លងទៅ ខ្ញុំបានរំលឹកដល់អ្នករួមការងារអំពីសមិទ្ធផលដែលយើងសម្រេចបានរួមគ្នា។ បុគ្គលិក CDRI បានកើនពី ៦៥ ដល់ ៨៥នាក់, ថវិកាសម្រាប់ប្រតិបត្តិការប្រចាំឆ្នាំកើនពី ១,៥លាន ដល់ ២,៥លានដុល្លារ ហើយបុគ្គលិកផ្នែកស្រាវជ្រាវកើនពី ២០ ដល់ ៤៥នាក់ ក្នុងនោះអ្នកស្រាវជ្រាវសញ្ជាតិកម្ពុជាបានបញ្ចប់ថ្នាក់បណ្ឌិត កើនពី 0 ដល់ ៧នាក់ និងកំពុងបន្តកើនឡើងទៀត។ CDRI បានរៀបចំ កម្មវិធីស្រាវជ្រាវរបស់ខ្លួនជាថ្មី ដើម្បីឆ្លុះបញ្ចាំងពី វិស័យអភិវឌ្ឍន៍ជាអាទិភាពចម្បងៗប្រាំរបស់កម្ពុជា ដោយមានអ្នកស្រាវជ្រាវជាន់ខ្ពស់សញ្ជាតិកម្ពុជា បំពេញតួនាទីជាអ្នកសម្របសម្រួលក្នុងកម្មវិធីនីមួយៗ។ យើងបានចេញផ្សាយរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ ក្នុងទម្រង់មួយងាយស្រួលប្រើដើម្បីចែករំលែកលទ្ធផលស្រាវជ្រាវសំខាន់ៗមួយចំនួន របស់ CDRI ដែលជាប់ពាក់ព័ន្ធខ្លាំងទៅនឹងគោលនយោបាយ។ យើងបានចាប់ដៃគូជាមួយធនាគារ ANZ Royal ផ្តួចផ្តើមគំនិតធ្វើសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាប្រចាំឆ្នាំ ដែលមានអ្នកចូលរួមកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ រហូតដល់សន្និសីទលើកទី៩ នេះ។

វិទ្យាស្ថាន CDRI ទទួលបានជំនួយទ្រទ្រង់កាន់តែរឹងមាំពីដៃគូចម្បងរបស់ខ្លួន គឺ ទីភ្នាក់ងារ សហប្រតិបត្តិការអន្តរជាតិស៊ុយអែត (Sida) ដែលមានតាំងពី កម្មវិធីទ្រទ្រង់រយៈពេលបីឆ្នាំ លើចំណាយប្រតិបត្តិការ និង ការងារផ្អែកអភិបាលកិច្ចជាពិសេស កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, រហូតដល់កម្មវិធីទ្រទ្រង់ធំទូលាយរយៈពេលប្រាំឆ្នាំ ក៏ដូចជា មូលនិធិសម្រាប់បញ្ហាសំខាន់ៗទើបផុសឡើងថ្មី ដូចជា កំណើនសម្រាប់គ្រប់គ្នា ការអប់រំ និង ការប្រែប្រួលអាកាសធាតុ ជាដើម។ ដោយមានជំនួយទ្រទ្រង់រឹងមាំពីសំណាក់ មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) នៃប្រទេសកាណាដា យើងបានផ្តួចផ្តើមបង្កើតវេទិកាស្រាវជ្រាវអភិវឌ្ឍន៍ (DRF) នៅកម្ពុជា ដែលជាកិច្ចសហការរវាងស្ថាប័នស្រាវជ្រាវឈានមុខ រួមមាន CDRI សកលវិទ្យាល័យភូមិន្ទភ្នំពេញ សកលវិទ្យាល័យភូមិន្ទកសិកម្ម វិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាល វិទ្យាស្ថានជាតិសុខភាពសាធារណៈ និង

---

អត្ថបទនេះ រៀបរៀងដោយ Larry Strange ជាទីប្រឹក្សាជាន់ខ្ពស់នៃវិទ្យាស្ថាន CDRI ។ សូមយោងអត្ថបទនេះថា L. Strange. 2015. “My Decade with CDRI – A Personal Reflection.” *Cambodia Development Review* 18(4): 12-16.

សមាគមសេដ្ឋកិច្ចកម្ពុជា។ វេទិកានេះមាន ក្រុមចំណាប់អារម្មណ៍ស្រាវជ្រាវតាមប្រធានបទចំនួន ៦ ដោយក្រុមនីមួយៗដឹកនាំដោយសមាជិកដៃគូមួយនៃ DRF និងមានធ្វើសន្និសីទប្រចាំឆ្នាំ និងវេទិកា ICT ដើម្បីផ្តល់ឱកាសឲ្យអ្នកស្រាវជ្រាវវ័យក្មេងអាចចែករំលែកចំណេះដឹង និងបទពិសោធន៍គ្នាទៅវិញទៅមក និងកសាងសមត្ថភាពស្រាវជ្រាវរបស់ខ្លួន។

ដោយមានជំនួយទ្រទ្រង់ពី IDRC និង មូលនិធិ Rockefeller នោះ វិទ្យាស្ថាន CDRI បានពង្រឹង បណ្តាញវិភាគអភិវឌ្ឍន៍សហការគ្នាក្នុងតំបន់ ដើម្បីបង្កើតភាពជាដៃគូធំទូលាយក្នុងមហាអនុតំបន់មេគង្គ (GMS) ដែលមានសមាជិកជា ស្ថាប័នស្រាវជ្រាវឈានមុខមកពីប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ វៀតណាម និង ខេត្តយុនណាន នៃប្រទេសចិន និងមានការងារផ្តោតលើបញ្ហាសំខាន់ៗដូចជា កំណើនសម្រាប់គ្រប់គ្នាក្នុង GMS ជាដើម។ ដោយមើលឃើញពីសារៈសំខាន់ នៃសមាហរណកម្ម និង សហប្រតិបត្តិការក្នុងតំបន់ សម្រាប់អនាគតប្រទេសកម្ពុជានោះ យើងបានខិតខំជំរុញ CDRI ឲ្យក្លាយជាវិទ្យាស្ថានថ្នាក់តំបន់មួយដែលដើរតួនាទីសកម្ម ក្នុងបណ្តាញស្រាវជ្រាវក្នុងតំបន់ តាមរយៈវេទិកា និងដៃគូនានាផ្នែកគោលនយោបាយអភិវឌ្ឍន៍។

## ដៃគូពិតៗ ការកសាងសមត្ថភាពពិតៗ សង្គមស៊ីវិលពិតៗ

ភាពជាដៃគូប្រកបដោយប្រសិទ្ធភាព និងការកសាងសមត្ថភាពស្ថាប័នក្នុងរយៈពេលវែង សំខាន់ខ្លាំងណាស់ដើម្បីឲ្យ CDRI អាចសម្រេចតាមគោលដៅរបស់ខ្លួន។ ក្នុងការងារមួយទសវត្សរ៍នៅ CDRI ខ្ញុំអាចសន្និដ្ឋានបានថា ពាក្យពីរដែលឃើញប្រើខុសញឹកញាប់ជាងគេ នៅក្នុងកម្រងពាក្យនៃការអភិវឌ្ឍក្នុងតំបន់ គឺ "ដៃគូ" ឬ "ភាពជាដៃគូ", និង "ការកសាងសមត្ថភាព" ឬ "ការអភិវឌ្ឍសមត្ថភាព"។ ហេតុអ្វីបានជាខ្ញុំសន្និដ្ឋានដូច្នេះ និង ហេតុអ្វីបានជាខ្ញុំតែងលើកពីចំណុចនេះ នៅតាមវេទិកាផ្សេងៗ នៅក្នុងតំបន់ និងអន្តរជាតិ?

ខ្ញុំជឿថា ក្នុងចំណោមជំនួយអភិវឌ្ឍន៍ពីក្រៅប្រទេស (ODA) ផ្តល់ទៅឲ្យ ប្រទេសលូតលាស់តិចជាងគេនៅក្នុងតំបន់យើងនេះ មានភាគច្រើនពេកដែលជំរុញឡើងដោយផ្នែកផ្គត់ផ្គង់ មិនមែនដោយផ្នែកតម្រូវការនោះទេ ហើយមិនសូវឆ្លុះបញ្ចាំងពីគំនិតផ្តួចផ្តើម និងភាពជាម្ចាស់នៃប្រជាជនក្នុងស្រុកឡើយ។ រយៈពេលខ្លីនៃការសន្យាផ្តល់ និងការផ្តល់ ODA ព្រមទាំងការរចនារៀបចំកម្មវិធីពាក់ព័ន្ធតាមប្រទេសនីមួយៗ នៅតែជាកត្តារារាំងដល់ការផ្តល់ និងប្រសិទ្ធភាពជំនួយ ហើយជារឿយៗណាស់ ក៏ឃើញមានការខកខាន ឬអសមត្ថភាពក្នុងការធ្វើវិនិយោគរយៈពេលវែងទៅលើការពង្រឹងស្ថាប័នក្នុងស្រុក និងការលំអៀងទៅតាមមនោគមវិជ្ជា និងប្រភេទស្ថាប័ន ដែលត្រូវផ្តល់វិនិយោគធំៗទៅឲ្យ។

បញ្ហាជាច្រើនក្នុងការគ្រប់គ្រង និងសម្របសម្រួលជំនួយដែលប្រទេសលូតលាស់តិចជាងគេត្រូវប្រឈមមុខ វាផុសចេញពីលក្ខណៈដែល សហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ គឺជាឧស្សាហកម្មមួយយ៉ាងធំដល់រាប់ពាន់លានដុល្លារ និងមានអំណាចខ្លាំងណាស់។ រហូតមកដល់ពេលថ្មីៗ ផ្នែកផ្តល់ជំនួយនេះស្ថិតក្រោមការគ្របដណ្តប់នៃប្រទេសអភិវឌ្ឍន៍ ឬទីភ្នាក់ងារអភិវឌ្ឍន៍ពហុភាគី ដែលពួកគេត្រួតត្រា ឬទីភ្នាក់ងារទ្វេភាគីរបស់ពួកគេ ឬបណ្តាក្រុមហ៊ុនផ្តល់ការប្រឹក្សា ឬពួកទីប្រឹក្សាដែលមានច្រើននាក់ ជាអតីតបុគ្គលិកនៃទីភ្នាក់ងារអភិវឌ្ឍន៍ទាំងនោះ ឬផ្នែកផ្តល់មតិប្រឹក្សានៃសកលវិទ្យាល័យ និងស្ថាប័នសិក្សាស្រាវជ្រាវនានា ដែលកំពុងប្រឈមមុខនឹងតម្រូវការបង្កើតប្រាក់ចំណូល។ ឧស្សាហកម្មអភិវឌ្ឍន៍នេះ នៅពេលដែលគោលនយោបាយ និងចំណូលចិត្តក្នុងការអភិវឌ្ឍអន្តរជាតិមានការផ្លាស់ប្តូរ ក៏បង្កើតចេញជាអនុឧស្សាហកម្មមានប្រាក់ចំណេញខ្ពស់ដែលក្នុងពីរទសវត្សរ៍កន្លងទៅនេះ មានដូចជា ផ្នែកអភិបាលកិច្ចយេនឌ័រ ការកសាងសមត្ថភាព ហើយថ្មីៗបំផុតនេះ គឺផ្នែកប្រសិទ្ធភាពជំនួយ។

## ដៃគូអភិវឌ្ឍន៍ពិតៗ

ក្នុងមួយទសវត្សកន្លងទៅនេះ CDRI មានកិច្ចសហការល្អខាងផ្នែកគម្រោងស្រាវជ្រាវ និងធនធានជាមួយដៃគូពហុភាគី និងទ្វេភាគីភាគច្រើន ក្នុងការអភិវឌ្ឍប្រទេសកម្ពុជា ប៉ុន្តែមាន ២ស្ថាប័នដែលជាដៃគូអភិវឌ្ឍន៍ពិតៗ បានជួយទ្រទ្រង់ខ្លាំងក្លាដល់គោលដៅ និងសកម្មភាព CDRI គឺមាន Sida និង IDRC។ Sida បានសហការជាមួយ CDRI តាំងពីដើមទីក្នុងប្រវត្តិវិទ្យាស្ថាន ហើយបានពង្រឹងជំនួយទ្រទ្រង់ពីមួយឆ្នាំទៅមួយឆ្នាំ រហូតក្លាយជាដៃគូរយៈពេលវែងសំខាន់ជាងគេរបស់ CDRI នាបច្ចុប្បន្ន។ កម្មវិធីជំនួយទ្រទ្រង់រយៈពេល ៥ឆ្នាំ របស់ Sida សម្រាប់ចំណាយប្រតិបត្តិការស្នូល អាចជួយ CDRI ឲ្យសម្រេចបាននូវស្តង់ដាខ្ពស់ផ្នែកអភិបាលកិច្ច, ការពង្រឹងស្ថាប័ន និងប្រព័ន្ធប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ក៏ដូចជា ធ្វើការស្រាវជ្រាវមានគុណភាពខ្ពស់ផ្នែកអភិបាលកិច្ច កំណែទម្រង់វិស័យសាធារណៈ កំណើនសម្រាប់គ្រប់គ្នា ការអប់រំ ជំនាញនិងការងារ និង ការប្រែប្រួលអាកាសធាតុ។

IDRC បានផ្តល់ជំនួយទ្រទ្រង់រយៈពេលមធ្យម និងវែងដ៏មានតម្លៃ សម្រាប់បណ្តាញវិភាគអភិវឌ្ឍន៍មហាអនុតំបន់មេគង្គ (GMS-DAN) របស់ CDRI, វេទិកាស្រាវជ្រាវអភិវឌ្ឍន៍ជំហានទី១ និងទី២, និង កម្មវិធីថ្មីស្តីពី ការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ចធនធានទឹកនៅកម្ពុជា ដែលជាកិច្ចសហការរវាង CDRI នឹង ក្រសួងធនធានទឹកនិងឧតុនិយម អាជ្ញាធរទន្លេសាប វិទ្យាស្ថានបច្ចេកទេសនៃកម្ពុជា និង សកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ដៃគូពិតៗទាំងពីរ បង្ហាញជានិច្ចនូវការគោរពដល់គំនិតផ្តួចផ្តើម និងភាពជាម្ចាស់នៃស្ថាប័នក្នុងស្រុក, តម្លៃនៃវិនិយោគរយៈពេលមធ្យម និងរយៈពេលវែងទៅលើស្ថាប័នក្នុងស្រុក, ការអភិវឌ្ឍកម្មវិធីជំរុញឡើងដោយតម្រូវការ ជាជាងការផ្គត់ផ្គង់, ព្រមទាំង តម្លាភាព និងគណនេយ្យភាពទៅវិញទៅមក។

## ការកសាងសមត្ថភាពពិតៗ

គ្មានលស់ថ្ងៃទេ ក្នុងបន្ទប់ទទួលភ្ញៀវនៅតាមសណ្ឋាគារនានានៅក្រុងភ្នំពេញ មានសញ្ញាបង្ហាញផ្លូវអ្នកចូលរួមទៅកាន់

បន្ទប់សិក្ខាសាលា និងការប្រជុំផ្សេងៗស្តីពីការអភិវឌ្ឍ។ កម្មវិធីទាំងនេះជាច្រើន សុទ្ធតែផ្សព្វផ្សាយថាជា "ការកសាងសមត្ថភាព" ប៉ុន្តែតាមពិតជា វគ្គបណ្តុះបណ្តាលរយៈពេលខ្លី ឬជាសកម្មភាពបំផុសការយល់ដឹង ហើយខ្លះក៏មានប្រយោជន៍ និងខ្លះក៏គ្មានប្រយោជន៍ទេ។ បទពិសោធន៍នៅ CDRI បានបង្រៀនយើងថា ការកសាង ឬការអភិវឌ្ឍសមត្ថភាពស្ថាប័នប្រកបដោយប្រសិទ្ធភាព ជាពិសេសសម្រាប់ស្ថាប័នស្រាវជ្រាវ ត្រូវមានការគួបផ្សំគ្នានូវការវិភាគពីតម្រូវការស្ថាប័ន, ការរៀបចំឡើងវិញ និងការពង្រឹងស្ថាប័ន, ការបង្កើនគុណសម្បត្តិផ្នែកអប់រំ និងជំនាញវិជ្ជាជីវៈតាមរយៈការអប់រំក្រោយថ្នាក់ឧត្តម, កម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍវិជ្ជាជីវៈ, ការផ្តល់មតិណែនាំផ្នែកជំនាញបច្ចេកទេស និងការផ្ទេរជំនាញ ក៏ដូចជា កិច្ចសហការជាលក្ខណៈស្ថាប័នធ្វើការផ្លាស់ប្តូរគ្នានូវបុគ្គលិក និងអ្នកហាត់ការ។ ក្នុងបរិបទកម្ពុជា ការកសាងសមត្ថភាពអាចមានប្រសិទ្ធភាពខ្ពស់បំផុត នៅពេលមានកិច្ចសហការជាលក្ខណៈស្ថាប័នរយៈពេលវែង រវាងស្ថាប័នស្រាវជ្រាវទន់ខ្សោយ នឹងស្ថាប័នខ្លាំងៗ ជាពិសេសនៅតាមប្រទេសក្នុងតំបន់ (ប្រទេសអាស៊ាន, ចិន, កូរ៉េខាងត្បូង, ជប៉ុន) ដែលត្រូវមានទំនាក់ទំនងអភិវឌ្ឍន៍ និងសេដ្ឋកិច្ចរយៈពេលវែងជាមួយកម្ពុជា។ ការពឹងផ្អែកខ្លាំងពេកលើទីប្រឹក្សាបច្ចេកទេស និងទីប្រឹក្សាអន្តរជាតិមានតម្លៃខ្ពស់ៗ ហើយនិងការធ្វើវិនិយោគរយៈពេលខ្លីជារឿយៗ ជាជាងការធ្វើវិនិយោគរយៈពេលវែងក្នុងការកសាងសមត្ថភាព និងភាពជាម្ចាស់ក្នុងស្រុក វាជាការយកសមត្ថភាពមកជំនួស មិនមែនការអភិវឌ្ឍសមត្ថភាពទេ ហើយត្រូវពឹងផ្អែកលើគេកាន់តែយូរទៀត។ ការកសាងសមត្ថភាពស្ថាប័នពិតៗ ទាមទារការប្រឹងប្រែងជាខ្លាំងទាំងពីថ្នាក់គ្រប់គ្រង និងបុគ្គលិក។ គេពិបាករចនារៀបចំវាឲ្យមានប្រសិទ្ធភាព ហើយផ្ទៃក្នុងអង្គភាព ក៏ត្រូវប្រឹងជំរុញ និងតាំងខ្លួនជាម្ចាស់វាដែរ។ តាមធម្មតា វាទាមទារនូវសមត្ថភាពជំនាញទាំងនៅខាងក្នុង និងមកពីខាងក្រៅ។ វាមានតម្លៃខ្ពស់ ហើយត្រូវចំណាយពេលច្រើន។ ការកសាងសមត្ថភាពពុំមានទីបញ្ចប់ឡើយ ពីព្រោះបរិស្ថានជុំវិញស្ថាប័ន និងតម្រូវការរបស់អតិថិជនផ្លាស់ប្តូរឥតឈប់។

## ឈានទៅកាន់សង្គមស៊ីវិលពិតៗនៅកម្ពុជា

ក្នុងឆ្នាំ២០១៣ អ្នកស្រាវជ្រាវនៃវិទ្យាស្ថាន CDRI បានចេញផ្សាយឯកសារពីរ ដែលមានលក្ខណៈចម្រូងចម្រាស់ គឺ *NGOs និងក្តីស្រម័យពីសង្គមស៊ីវិលនៅកម្ពុជា* និង *២០ឆ្នាំធ្វើការពង្រឹងសង្គមស៊ីវិលនៅកម្ពុជា៖ ដល់ពេលត្រូវបូកសរុបឡើងវិញ* (Ou and Kim 2013a, b)។ ឯកសារទាំងពីរបានលើកនូវបញ្ហាគោលនយោបាយសាធារណៈសំខាន់ៗ ស្តីពី តួនាទី គុណភាព និងអភិបាលកិច្ចនៃសហគមន៍ NGO ដ៏ធំទូលាយ និងខុសៗគ្នានៅកម្ពុជា និងភាពក្មេងខ្ចីនៃសង្គមស៊ីវិលពិតៗ ទោះបីមានជំនួយទ្រទ្រង់ហិរញ្ញវត្ថុធំដុំពីអន្តរជាតិ ជាច្រើនទសវត្សរ៍មកហើយក្តី។ ក្នុងមួយទសវត្សរ៍កន្លងទៅនេះ ខ្ញុំកាន់តែបារម្ភខ្លាំងឡើងពីគុណភាព និងប្រសិទ្ធភាពមិនស្មើគ្នានៃ NGOs នៅកម្ពុជា។ NGOs មានច្រើន និងទទួលបានជំនួយទ្រទ្រង់ហិរញ្ញវត្ថុច្រើនៗក៏ពិតមែន ប៉ុន្តែជារឿយៗពួកគេនៅមានយន្តការត្រួតពិនិត្យ និងវាយតម្លៃអន់ខ្សោយ ឬគ្មានសោះតែម្តង ខ្វះខាតការយល់ដឹង និងការប្តេជ្ញាចិត្តអនុវត្តតាមស្តង់ដាអភិបាលកិច្ចកម្រិតខ្ពស់ ក្នុងអង្គការរបស់ខ្លួន ទោះបីតែងណែនាំជាសាធារណៈលើចំណុចទាំងនេះដល់អង្គការឯទៀតក្តី។

ខ្ញុំចាប់ផ្តើមបម្រើការនៅកម្ពុជា បន្ទាប់ពីបានបញ្ចប់អាជីពវិជ្ជាជីវៈនៅប្រទេសអូស្ត្រាលី ដែលរួមមានការចូលរួមសំខាន់ៗក្នុងបណ្តាញ និងអង្គការសង្គមស៊ីវិលឈានមុខនានា ក្នុងឋានៈជាអ្នកតស៊ូមតិគាំទ្រសហជីពពលករឧស្សាហកម្ម, ជាបុគ្គលិកបន្ទាប់មកជាសមាជិកក្រុមប្រឹក្សាភិបាល ហើយក្រោយមកទៀតជាប្រធានក្រុមប្រឹក្សាភិបាល នៃមជ្ឈមណ្ឌលតស៊ូមតិដើម្បីផលប្រយោជន៍សាធារណៈ (Public Interest Advocacy Centre) ដែលជាមជ្ឈមណ្ឌលផ្នែកច្បាប់ បម្រើផលប្រយោជន៍សាធារណៈឈានមុខនៅអូស្ត្រាលី, ជាបេក្ខជនរបស់សមាគមអ្នកប្រើប្រាស់អូស្ត្រាលី សម្រាប់ការតែងតាំងក្នុងគណៈកម្មការផ្តល់អាជ្ញាប័ណ្ណ NGO (ក្រោយមកទៀតប្តូរឈ្មោះថា ក្រុមប្រឹក្សាអូស្ត្រាលីដើម្បីជំនួយក្រៅប្រទេសៈ ACFOA) ដែលជាអង្គការកំពូលសម្រាប់ពួក NGO ជាប់ពាក់ព័ន្ធនឹងជំនួយអន្តរជាតិ នៅប្រទេសអូស្ត្រាលី។

តាមប្រវត្តិដូចខាងលើ ខ្ញុំរីករាយណាស់ដោយបានចូលបម្រើការមួយអាណត្តិក្នុង គណៈកម្មការផ្តល់អាជ្ញាប័ណ្ណ NGO នៃកម្មវិធីរបៀបអនុវត្តល្អសម្រាប់ NGO (NGO-GPP) នៃគណៈកម្មការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ដែលជាយន្តការដ៏សំខាន់មួយគ្រប់គ្រង និងជំរុញឡើងដោយបណ្តាស្ថាប័នក្នុងស្រុក ដើម្បីលើកកម្ពស់អភិបាលកិច្ច តម្លាភាព និងគណនេយ្យភាពក្នុងសហគមន៍ NGO។ បទពិសោធន៍នេះជួយឲ្យខ្ញុំបានឃើញនូវសេវាប្រកបដោយគុណភាព ផ្តល់ឲ្យដោយ NGOs ជាតិ និងអន្តរជាតិជាច្រើននៅកម្ពុជា និងអង្គភាពកំពូលរបស់ពួកគេ ដូចជា វេទិកា NGO និង CCC ដែលដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍវិស័យសុខភាព អប់រំ ការអភិវឌ្ឍស្ត្រីនិងយុវជន ការអភិវឌ្ឍសហគមន៍ មីក្រូហិរញ្ញវត្ថុ ការត្រួតពិនិត្យការបោះឆ្នោត និងវិស័យផ្សេងៗទៀត។ ពួកគេក៏បានបង្ហាញការប្តេជ្ញាចិត្តសម្រេចឲ្យបាននូវអភិបាលកិច្ចល្អ និងការចូលរួមបែបស្ថាបនាផ្នែកគោលនយោបាយជាមួយរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសហគមន៍ស្រាវជ្រាវដែរ។ ខ្ញុំសូមលើកទឹកចិត្តអ្នកដទៃទៀតដែលមិនទាន់មានការចាស់ចិត្តចាស់គំនិតដល់កម្រិតនេះឲ្យ "អនុវត្តដូចអ្វីដែលខ្លួនបានទូន្មានគេ" ក្នុងការលើកកម្ពស់អភិបាលកិច្ច តម្លាភាព និងគណនេយ្យភាព, ការចូលរួមប្រកបដោយទំនួលខុសត្រូវ, និងការប្រើប្រាស់ភស្តុតាងផ្អែកលើការស្រាវជ្រាវ, សម្រាប់ធ្វើការតស៊ូមតិ និងសកម្មភាពកែប្រែសង្គមផ្សេងៗ។

## លំនាំការអភិវឌ្ឍនៅកម្ពុជា និងតំបន់ជុំវិញ៖ តើមានអ្នកផ្លាស់ប្តូរស្ថានការណ៍ខ្លះទេ?

មុនពេលខ្ញុំមកបម្រើការនៅ CDRI និងកម្ពុជា ខ្ញុំបានបំពេញការងារ ១០ឆ្នាំ ជានាយកវិទ្យាស្ថានអាស៊ី-អូស្ត្រាលី ដែលជាក្រុមផ្តល់គំនិតឯករាជ្យមួយផ្តោតការងារលើ នយោបាយក្រៅប្រទេសរបស់អូស្ត្រាលី សមាហរណកម្មក្នុងតំបន់ និង និន្នាការភូមិសាស្ត្រនយោបាយសំខាន់ៗនៅអាស៊ីខាងកើត, ដោយមានបណ្តាញជា

បណ្ដាស្ថាប័នស្រាវជ្រាវឈានមុខផ្នែកគោលនយោបាយ នៅក្នុងតំបន់។ នៅពេលរូបខ្ញុំទទួលការតែងតាំង ក្រុមប្រឹក្សាភិបាល CDRI បានលើកទឹកចិត្តខ្ញុំឲ្យប្រើប្រាស់ប្រវត្តិការងារនេះ ដើម្បីជំរុញឲ្យ CDRI មានស្ថានភាពកាន់តែយុទ្ធសាស្ត្រឡើង ក្នុងឋានៈជាស្ថាប័នស្រាវជ្រាវផ្នែកគោលនយោបាយ ទាំងនៅក្នុងស្រុក និងក្នុងតំបន់។

ជាលទ្ធផល ក្នុងមួយទសវត្សរ៍កន្លងទៅនេះ យើងបានបង្កើតកិច្ចសហការគួរជាទីគាប់ចិត្តបំផុតជាមួយ វិទ្យាស្ថាននានានៃបណ្ឌិតសភាផ្នែកវិទ្យាសាស្ត្រសង្គមនៃប្រទេសចិន (CASS), វេទិកាវិទ្យាស្ថាននៅអាស៊ីបូព៌ា នៃវិទ្យាស្ថានកូរ៉េសម្រាប់គោលនយោបាយសេដ្ឋកិច្ចអន្តរជាតិ (KIEP), បណ្ដាញអភិវឌ្ឍន៍អាស៊ីបូព៌ានៃធនាគារពិភពលោក (EADN), ធនាគារអភិវឌ្ឍន៍អាស៊ី (ADB), និង បណ្ដាញក្រុមផ្ដល់គំនិតខាងការអភិវឌ្ឍក្នុងតំបន់នៃវិទ្យាស្ថាន ADB, បណ្ដាញស្រាវជ្រាវនិងបណ្ដុះបណ្ដាលផ្នែកពាណិជ្ជកម្មនៅតំបន់អាស៊ីប៉ាស៊ីហ្វិក (ARTNeT) នៃគណៈកម្មាធិការសង្គម និងសេដ្ឋកិច្ចសហប្រជាជាតិសម្រាប់តំបន់អាស៊ីនិងអាស៊ីប៉ាស៊ីហ្វិក (UNESCAP) និង វិទ្យាស្ថានសិក្សាពីតំបន់អាស៊ីអាគ្នេយ៍ (SEAS) នៃប្រទេសសិង្ហបុរី។ យើងក៏បានគាំទ្រយ៉ាងសកម្មដល់ការបង្កើត និងការចាប់ដៃគូជាមួយវិទ្យាស្ថានធនធានអភិវឌ្ឍន៍មីយ៉ាន់ម៉ា (MDRI) ដែរ។

ការក្ដាប់យកបានស្ថានភាពនេះ ជួយឲ្យយើងសម្រេចគោលដៅនៃការជំរុញ CDRI ឲ្យមានវត្តមាននៅតុប្រជុំពិភាក្សាពីការស្រាវជ្រាវ ផ្នែកគោលនយោបាយសំខាន់ៗ ស្ដីពីសហប្រតិបត្តិការ និងសមាហរណកម្មក្នុងតំបន់អាស៊ី និងផលពាក់ព័ន្ធដល់ការអភិវឌ្ឍសង្គមកិច្ចសេដ្ឋកិច្ចនៅក្នុងតំបន់ និងនៅកម្ពុជាព្រមទាំងដល់អនាគតរួមគ្នានៅក្នុងតំបន់។

នៅឆ្នាំ២០១១ សាស្ត្រាចារ្យ Zhang Yunling នាយកផ្នែកការសិក្សាអន្តរជាតិ នៃ CASS បានអញ្ជើញរូបខ្ញុំឲ្យចូលរួមក្នុងក្រុមជំនាញការថ្នាក់តំបន់មួយ ធ្វើការងារលើគម្រោងដែលគាត់កំពុងដឹកនាំសម្រាប់ វិទ្យាស្ថានស្រាវជ្រាវផ្នែកសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ERIA) ស្ដីពី *ការឈានទៅអនុវត្តគំរូអភិវឌ្ឍន៍ថ្មីមួយសម្រាប់អាស៊ីបូព៌ា៖ តួនាទីគោលនយោបាយក្នុងស្រុក និងសហប្រតិបត្តិការក្នុងតំបន់។ ខ្ញុំបានចូលរួមចងក្រងជំពូកមួយ ស្ដីពី សេដ្ឋកិច្ចប្រទេសតូចៗមានការអភិវឌ្ឍតិចនៅក្នុងអាស៊ាន៖ តម្រូវការវិធីសាស្ត្រថ្មីមួយ* (Strange 2012)។ ការចូលរួមក្នុងការសិក្សានេះ ជួយឲ្យខ្ញុំអាចប្រមូលនូវគំនិតជាច្រើនដែលខ្ញុំបានយកទៅបង្ហាញនៅក្នុងវេទិកាថ្នាក់ជាតិ និងថ្នាក់តំបន់ ព្រមទាំងក្នុងអត្ថបទមួយចំនួនដែលបានពុម្ពផ្សាយខ្លះ និងមិនបានបោះពុម្ពផ្សាយខ្លះក្នុងមួយទសវត្សរ៍កន្លងទៅនេះ។

សរុបមកខ្ញុំជឿថា ដើម្បីឲ្យកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សម្រាប់កម្ពុជា និងសម្រាប់ប្រទេសកំពុងអភិវឌ្ឍផ្សេងទៀតនៅអាស៊ីបូព៌ាកាន់តែមានប្រសិទ្ធភាព និងសម្រេចបានលទ្ធផលកាន់តែប្រសើរក្នុងការអភិវឌ្ឍសមត្ថភាពបុគ្គល និងស្ថាប័ននោះ គួរអនុវត្តប្រើវិធីសាស្ត្រកាន់តែធំទូលាយដល់កម្រិតតំបន់ ដោយមានលក្ខណៈដូចខាងក្រោម៖

- ការគោរព និងយល់ដឹងកាន់តែប្រសើរពីតម្រូវការ និងភាពជាម្ចាស់របស់ប្រជាជនស្រុក
- ការកាត់បន្ថយលក្ខខណ្ឌដាក់ចំហ ឬបង្កប់ ក្នុងការផ្ដល់ជំនួយអភិវឌ្ឍន៍
- ការផ្ដោតលើការកសាងស្ថាប័ន និងអភិវឌ្ឍសមត្ថភាពក្នុងរយៈពេលវែង, ការយល់ដឹងកាន់តែស៊ីជម្រៅពីភាពស្មុគស្មាញនៃយុទ្ធសាស្ត្រទប់ទល់ប្រឆាំងអំពើពុករលួយ នៅក្នុងប្រព័ន្ធផ្សេងៗ និងតួនាទីនៃយុទ្ធសាស្ត្រទាំងនោះក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍប្រកបដោយចីរភាព
- ការគិតដល់រយៈពេលវែងក្នុងការបង្កើត និងផ្ដល់ ODA, តួនាទីកាន់តែសំខាន់នៃភាពជាដៃគូរវាងវិស័យឯកជន នឹងទីភ្នាក់ងារផ្ដល់ ODA
- ការគោរពដល់ និងការកេណ្ឌប្រមូល នូវបទពិសោធន៍ និងជំនាញក្នុងស្រុក, ការចែករំលែក និងបង្កើតដំណោះស្រាយ និងគំរូអភិវឌ្ឍន៍ក្នុងតំបន់
- ការបង្កើតកិច្ចសហការជាដៃគូផ្នែកស្ថាប័ន ក្នុងរយៈពេលវែងរវាងរដ្ឋាភិបាល វិស័យឯកជន ស្ថាប័នសិក្សាអប់រំ និងស្រាវជ្រាវពីគោលនយោបាយ និងអង្គការសង្គមស៊ីវិលក្នុងតំបន់អាស៊ីបូព៌ា ដែលសុទ្ធតែជាធាតុផ្សំដ៏មានប្រយោជន៍សម្រាប់សហប្រតិបត្តិការអភិវឌ្ឍន៍ក្នុងតំបន់ និងសម្រាប់សហគមន៍ក្នុងតំបន់នៅថ្ងៃអនាគត។ (Strange 2006)

ទោះបីនៅតំបន់អាស៊ីបូព៌ាសព្វថ្ងៃ កំពុងមានភាពតានតឹងដ៏ស្មុគស្មាញផ្នែកភូមិសាស្ត្រនយោបាយក្ដី ក៏ដំណើរការបង្កើត និងអនុវត្ត ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) របស់ ១០ប្រទេសសមាជិកអាស៊ាន បូកនឹងប្រទេសចិន កូរ៉េខាងត្បូង ជប៉ុន ឥណ្ឌា អូស្ត្រាលី និង ញូហ្សីលែន (ឬហៅកាត់ថា អាស៊ានបូក៦) បានផ្ដល់ជាយានគួរជាទីសង្ឃឹមមួយដើម្បីអនុវត្តវិធីសាស្ត្រកាន់តែធំទូលាយដល់កម្រិតតំបន់ ក្នុងការបង្កើតកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ដ៏មានប្រសិទ្ធភាព សម្រាប់កម្ពុជា និងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀតនៅក្នុងតំបន់។ ក្នុងកិច្ចប្រជុំកំពូលអាស៊ានប្រចាំឆ្នាំ២០១៤ នៅប្រទេសមីយ៉ាន់ម៉ា ថ្នាក់ដឹកនាំប្រទេសអាស៊ានបូក៦ បានបញ្ជាក់ជាថ្មីពីការប្ដេជ្ញាចិត្តសម្រេចឲ្យបាននូវកិច្ចព្រមព្រៀង ស្ដីពីក្របខ័ណ្ឌ RCEP នៅត្រឹមឆ្នាំ២០១៥ ហើយបន្ទាប់មកឈានទៅអនុវត្តវា ដោយផ្អែកលើបទពិសោធន៍នៃ កិច្ចព្រមព្រៀងសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ និង កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនិងសហប្រតិបត្តិការក្នុងតំបន់ ផ្សេងៗទៀត។ RCEP បានទទួលស្គាល់ពីលក្ខណៈខុសៗគ្នានៃប្រទេសជាសមាជិក និងស្ថានភាពពិសេសនៃប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម (CLMV) ដែលត្រូវមានភាពបត់បែនខ្លះក្នុងរបៀបចាត់ចែងជាលក្ខណៈពិសេស និងខុសប្លែកពីគេ មានជាអាទិ៍ ការប្ដេជ្ញាញ៉ាំងឲ្យមានសហប្រតិបត្តិការផ្នែកបច្ចេកទេស និងផ្នែកសេដ្ឋកិច្ច ដើម្បីកាត់បន្ថយគម្លាតអភិវឌ្ឍន៍។

នៅឆ្នាំ២០១៤ មិនគ្រាន់តែមានការប្ដេជ្ញាចិត្តពីប្រទេសអាស៊ានបូក៦ ញ៉ាំងឲ្យ RCEP ជឿនលឿនទៅមុខប៉ុណ្ណោះទេ

ប៉ុន្តែក៏មានទាំងការវិវត្តសំខាន់ៗផ្សេងទៀត ដែលអាចផ្លាស់ប្តូរស្ថានការណ៍សម្រាប់កម្ពុជា និងគំរូនៃការអភិវឌ្ឍនៅកម្ពុជា។ ការវិវត្តទាំងនេះ រួមមាន ការបង្កើតធនាគារអភិវឌ្ឍន៍ថ្មី ដោយប្រទេស BRICS (ប្រទេសមានសេដ្ឋកិច្ចកំពុងផុសឡើងចម្បងៗទាំងប្រាំ គឺ ប្រេស៊ីល រុស្ស៊ី ឥណ្ឌា ចិន និង អាហ្វ្រិកខាងត្បូង) នៅក្រុងសៀងហៃ និង ធនាគារវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) នៅក្រុងប៉េកាំង ហើយកម្ពុជាក៏បានចុះហត្ថលេខាចូលរួមផងដែរ។ ក្នុងកិច្ចប្រជុំកំពូល GMS ឆ្នាំ២០១៤ លោក ស៊ី យិនពីង ប្រធានាធិបតីប្រទេសចិន បានប្រកាសពីវិនិយោគ និងជំនួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដ៏ធំ ដោយប្រទេសចិនទៅក្នុង ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញទំនាក់ទំនងក្នុង GMS ដែលជាប់ទាក់ទងនឹងសមត្ថភាពផលិតកម្ម និងការកាត់បន្ថយភាពក្រីក្រ, និង ទៅក្នុងមូលនិធិ AIIB ថ្មី ដែលជាប់ទាក់ទងនឹងគំនិតផ្តួចផ្តើមផ្លូវសូត្រ (Silk Road) តាមសមុទ្រ និងផ្លូវគោករបស់ចិន។ ទោះបីគំនិតផ្តួចផ្តើម និងធនធានអភិវឌ្ឍន៍ថ្មីៗខ្លះមិនទាន់មានព័ត៌មានលំអិតច្បាស់លាស់ក្តី ក៏វាទំនងមានផលប៉ះពាល់ខ្លាំង មកលើទិដ្ឋភាពនៃការអភិវឌ្ឍរបស់កម្ពុជា និងប្រទេសជិតខាងកម្ពុជា។

## សិល្បៈ និងជីវិតនៅកម្ពុជា

ការសប្បាយរីករាយដ៏ធំមួយសម្រាប់ខ្ញុំ ក្នុងមួយទសវត្សរ៍កន្លងទៅនេះ គឺ ពិភពសិល្បៈសម័យថ្មីនៅកម្ពុជា ការទិញបានស្នាដៃសិល្បៈកម្ពុជាសម័យថ្មីចម្រុះមួយចំនួន និងចំណងមិត្តភាពជាមួយពួកតារា និងអ្នកសិល្បៈសម័យថ្មីឈានមុខមួយចំនួននៅកម្ពុជា។ នៅខែមេសា ឆ្នាំ២០១៣ ខ្ញុំមានភ័ព្វជា ពិសេសបានចូលរួមព្រឹត្តិការណ៍រយៈពេលមួយសប្តាហ៍ដ៏ចម្បងមួយ នៃមហោស្រពវប្បធម៌ រដូវនៅកម្ពុជា នៅទីក្រុងញូវយកដែលបានប្រមូលផ្តុំសិល្បករសញ្ជាតិកម្ពុជាជាច្រើន ខាងផ្នែកសិល្បៈរូបភាព និងការសម្តែង។ ក្នុងកម្មវិធីរយៈពេល១ខែ គឺមានការសម្តែងការតាំងពិពណ៌ សិក្ខាសាលា និងព្រឹត្តិការណ៍ជាប់ពាក់ព័ន្ធផ្សេងៗដែលផ្តួចផ្តើមឡើង និងសម្របសម្រួលដោយ អង្គការសិល្បៈខ្មែរអមតៈ និងដៃគូនានារបស់អង្គការនេះ។

ក្នុងរយៈពេលតែមួយសប្តាហ៍ ខ្ញុំបានចូលរួមក្នុងការតាំងពិពណ៌ទោល របស់សិល្បករសម័យថ្មីឈានមុខនៅកម្ពុជា គឺ លោក ពេជ្រ សុភាព នៅសារៈមន្ទីរសិល្បៈ Metropolian និងបទសម្ភាសន៍របស់គាត់ ជាមួយលោកប្រធានទទួលបន្ទុកលើវត្ថុតាំងពិពណ៌ ក្នុងសាល Met ដែលមានអ្នកចូលរួមពេញណែន។ ខ្ញុំក៏បានចូលទស្សនា ការសម្តែងរបាំសម័យថ្មីដ៏មានឥទ្ធិពលរបស់ លោកស្រី សុភិលីន ជាម សាពីរោ មានចំណងជើងថា *បត់មួយតាមដងទន្លេ* ក្នុងសាលសម្តែង Joyce Theatre ដែលមានក្រពើយក្សធ្វើពីផ្តៅផលិតដោយលោក ពេជ្រ សុភាព និងសាច់ភ្លេងរបស់អ្នកនិពន្ធបទភ្លេងឈានមុខ គឺ លោក ហ៊ឹម សុភី, និងការពិភាក្សាជាក្រុម រវាងសិល្បករទាំងបីនាក់ ដែលសម្របសម្រួលដោយ អ្នកសិក្សាស្រាវជ្រាវសញ្ជាតិកម្ពុជាកំពុងរស់នៅសហរដ្ឋអាមេរិក នៅចំពោះមុខទស្សនិកជនយ៉ាងច្រើនកុះករពេញក្នុងសាល Asia Society ដ៏ល្បីល្បាញ។

ខ្ញុំជឿថា ជីវិតវប្បធម៌ និងសិល្បៈដ៏រស់រវើកនេះ ជាសូចនាករសំខាន់នៃដំណាក់កាលអភិវឌ្ឍន៍ និងសុខភាពសង្គមរបស់ប្រជាជាតិមួយ។ ខ្ញុំសង្ឃឹមថា សិល្បករកម្ពុជាដ៏ក្លាហានទាំងនេះ និងសិល្បករជំនាន់ក្រោយទើបផុសឡើងថ្មី នឹងទទួលបានការវាយតម្លៃកាន់តែខ្ពស់ និងការគាំទ្រកាន់តែច្រើន នៅពេលកម្ពុជាវិវត្តទៅមុខទៀត។

## សេចក្តីសន្និដ្ឋាន៖ ការបន្តដំណែងថ្នាក់ដឹកនាំ CDRI

ខ្ញុំតែងសង្ឃឹមជានិច្ចថា ដល់ពេលសមគួរខ្ញុំត្រូវលាលែងពីដំណែងនោះ នឹងមានជនកម្ពុជាប្រកបដោយគុណសម្បត្តិសមស្របមកបន្តវេន។ នៅពាក់កណ្តាលឆ្នាំ២០១៤ ក្រុមប្រឹក្សាភិបាល CDRI បានតែងតាំងបណ្ឌិត ឆែម វិទ្ធី ដែលជាជនកម្ពុជាដ៏ល្បីល្បាញ និងពេលនោះកំពុងកាន់ដំណែងជានាយកផ្នែកសុខភាពមនុស្ស នៃនាយកដ្ឋានវិទ្យាសាស្ត្របរមាណូ នៃទីភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ ហើយមានបំណងវិលមកបម្រើការងារក្នុងប្រទេសកម្ពុជាវិញនោះ ឲ្យមកបន្តវេនជានាយកប្រតិបត្តិថ្មីរបស់ CDRI ចាប់ពីខែកញ្ញា ឆ្នាំ២០១៤ តទៅ។ ខ្ញុំក៏បានយល់ព្រមដោយរីករាយតាមសំណើរបស់គាត់ ឲ្យរូបខ្ញុំបន្តចូលរួមបម្រើការងារក្នុងដំណែងជាទីប្រឹក្សាជាន់ខ្ពស់នៃ CDRI រហូតដល់ចុងឆ្នាំ២០១៥ ដើម្បីជួយគាំទ្រឲ្យការផ្លាស់ប្តូរថ្នាក់ដឹកនាំមានដំណើររលូនល្អ ព្រមទាំងស្វែងរកឱកាសបម្រើប្រទេសកម្ពុជាតទៅអនាគតទៀត។

ខ្ញុំសូមអរគុណដល់អ្នករួមការងារ សមាជិក និងប្រធានក្រុមប្រឹក្សាភិបាល នាបច្ចុប្បន្ន និងពីអតីតកាល នៅ CDRI ព្រមទាំង ដៃគូ និងអ្នកពាក់ព័ន្ធទាំងអស់ ដែលជួយឲ្យខ្ញុំបានឆ្លងកាត់បទពិសោធន៍ការងារដ៏តឹងតែង ប៉ុន្តែលើកទឹកចិត្តជាខ្លាំង ធ្វើឲ្យខ្សែជីវិតរបស់ខ្ញុំមានការផ្លាស់ប្តូរយ៉ាងប្រសើរ។ ខ្ញុំសូមជូនពរឲ្យ CDRI បន្តលូតលាស់ និងរីកចម្រើនទៅមុខក្នុងការបម្រើប្រទេសកម្ពុជា និងប្រជាជនកម្ពុជា។

## ឯកសារយោង


Christoplos, Ian, and Karen L. Greene. 2014. *Mid-Term Review of Sweden's Support to the Cambodia Development Resource Institute.* Stockholm: Sida.

Ou Sivhuoch and Kim Sedara. 2013a. *20 Years' Strengthening of Cambodian Civil Society: Time for Reflection.* Working paper Series No. 85. Phnom Penh: CDRI.

Ou Sivhuoch and Kim Sedara. 2013b. "NGOs and the Illusion of a Cambodian Civil Society." *In Southeast Asia and the Civil Society Gaze: Scoping a Contested Concept in Cambodia and Vietnam.* London: Routledge.

Strange, L. 2006. "Development Cooperation for Regional Economic Integration, Prosperity and Community – An East Asian Way Forward?" Paper presented to 2nd East Asian Institutes Forum on *East Asian Economic Integration: Progress and Impediments*, Jeju Island, Philippines, 13 December.

Strange, L. 2012. "ASEAN Small Less Developed Economies: Need for a New Approach." In *Moving Toward a New Development Model for East Asia- The Role of Domestic Policy and Regional Cooperation*, edited by Y. Zhang, F. Kimura and S. Oum, 279-311. ERIA Research Project Report 2011-10, Jakarta: ERIA.

# តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ ពណ៌នាពីសូចនាករសេដ្ឋកិច្ចមួយចំនួននៃប្រទេសមានសេដ្ឋកិច្ចធំៗក្នុងពិភពលោក និងបណ្ដាប្រទេសនៅអាស៊ីខាងត្បូង និងអាស៊ីខាងកើត។

នៅត្រីមាសទី៣ សេដ្ឋកិច្ចបណ្ដាប្រទេសនៅអាស៊ី បន្តមានដំណើរការល្អ ធៀបនឹងសេដ្ឋកិច្ចរបស់ប្រទេសឧស្សាហកម្មនានា ទោះបីសេដ្ឋកិច្ចប្រទេសអាស៊ីខ្លះ ដូចជា ថៃ និង សិង្ហបុរី មានកំណើនយឺតជាងមុនក្ដី។ មានវិបត្តិសកលថ្មីៗបានផុសឡើង ដូចជា ការវាយប្រហារតាមបណ្ដាញអ៊ីនធឺណិត និងអស្ថិរភាពផ្នែកភូមិសាស្ត្រនយោបាយជាដើម។

ផសស ពិតប្រចាំឆ្នាំនៅឥណ្ឌូនេស៊ី មានអត្រាកំណើនជាមធ្យម ៥,០% រហូតមកទល់ត្រីមាសទី៣ ហើយនៅម៉ាឡេស៊ី វាមានកំណើន ៥,៦%។ ផសស ពិតក្នុងរយៈពេល១២ខែ នៅសិង្ហបុរី មានកំណើន ២,៤% ធៀបនឹង ៥,៨% កាលពីឆ្នាំមុន រីឯនៅថៃ វាមានកំណើន ០,៦% ធៀបនឹង ២,៦% កាលពីឆ្នាំមុន។ ភាពតានតឹងផ្នែកនយោបាយ និងការធ្លាក់ថ្លៃទំនិញកសិកម្មសំខាន់ៗក្នុងពិភពលោក (ឧ. អង្ករ និងកៅស៊ូ) អាចពន្យល់បានមួយផ្នែកពី ការថយចុះកំណើននៅប្រទេសថៃ។ កំណើន ផសស នៅប្រទេសចិនធ្លាក់ចុះបន្តិច មកត្រឹម ៧,៣%។

នៅត្រីមាសទី៣ កំណើន ផសស ក្នុងតំបន់ចាយប្រាក់អឺរ៉ូ មានអត្រា ០,៣% ដែលមិនគួរឲ្យពេញចិត្តប៉ុន្មានទេ ប៉ុន្តែវាបានប្រសើរឡើងខ្លះហើយ បើធៀបនឹងការរួមចុះ ០,៤% កាលពីឆ្នាំមុន។ ផសស ពិតរបស់ប្រទេសជប៉ុនរួមចុះ ១,២% ក្នុងរយៈពេល១២ខែ កន្លងទៅ ទោះបីមានការបន្តអនុវត្តគំនិតផ្ដួចផ្ដើមតាមទ្រឹស្ដី Abenomic ក៏ដោយ។ សហរដ្ឋអាមេរិក សម្រេចបានកំណើន ផសស ល្អបង្គួរ ដល់ ២,៣% ធៀបនឹង ១,៦% កាលពីឆ្នាំមុន។ ទីផ្សារការងារសហរដ្ឋអាមេរិក បានងើបឡើងវិញ ក្រោយពីបានធ្លាក់ចុះធ្ងន់ធ្ងរបំផុត គិតចាប់ពីពេលមានមហាវិបត្តិសេដ្ឋកិច្ច មក។ ក្នុងខែធ្នូ ២០១៤ មានការបង្កើត ២៥២.០០០ការងារថែមទៀត ធ្វើឲ្យអត្រាគ្មានការងារធ្វើមានត្រឹម ៥,៦%។

## អតិផរណាក្នុងពិភពលោក និងអត្រាប្ដូរប្រាក់

នៅត្រីមាសទី៣ ទាំងក្នុងប្រទេសមានសេដ្ឋកិច្ចកំពុងផុសឡើង និងប្រទេសមានសេដ្ឋកិច្ចជឿនលឿន អត្រាអតិផរណាមានតួលេខត្រឹមមួយខ្ទង់ ហើយនៅប្រទេសខ្លះ វាមានកម្រិតទាបជាងការរំពឹងទុកទៅទៀត។ អតិផរណានៅប្រទេសកម្ពុជាធ្លាក់ចុះមកត្រឹម ៤,០% ធៀបនឹង ៤,៩% កាលពីត្រីមាសមុន។ ការចុះថ្លៃប្រេងឥន្ធនៈ នាំឲ្យទំនិញដែលពឹងផ្អែកខ្លាំងលើវាក្នុងដំណើរការផលិតកម្ម បានចុះថ្លៃដែរ។ នៅប្រទេសឥណ្ឌូនេស៊ី អតិផរណាប្រចាំឆ្នាំ មានកម្រិត ៤,៣% ហើយនៅប្រទេសម៉ាឡេស៊ី វាមានកម្រិត ៣,០%។ អតិផរណានៅប្រទេសវៀតណាម មានដំណើរដូចប្រក្រតីឡើងវិញនៅកម្រិត ៤,៥% ក្រោយពីបានឡើងដល់កម្រិតកំពូល ២៣,៣% ក្នុងឆ្នាំ២០០៨ ដែលជាឆ្នាំមានវិបត្តិសកល និងការអនុវត្តគោលនយោបាយបង្កើនសាច់ប្រាក់នៅវៀតណាម។ អតិផរណាក្នុងតំបន់ចាយប្រាក់អឺរ៉ូនៅមានកម្រិតទាប ប៉ុន្តែនៅប្រទេសជប៉ុនមានការឡើងថ្លៃខ្ពស់បំផុត ក្នុងពីរត្រីមាសជាប់គ្នា បើគិតចាប់ពីពេលមានបរិត្តផរណា នៅត្រីមាសទី២ ឆ្នាំ២០១៣ មក។ អតិផរណានៅសហរដ្ឋអាមេរិក នៅតែមានកម្រិតទាបជាងការរំពឹងទុក គឺត្រឹម ១,៨% ទោះបីមានការសម្រួលបរិមាណសាច់ប្រាក់ក្ដី។ គេមិនឃើញមានសញ្ញានៃការកាត់បន្ថយគំហុកនូវ ការផ្គត់ផ្គង់សាច់ប្រាក់ ដោយធនាគារកណ្ដាលនោះទេ។ វិបត្តិសកលមួយអាចផ្ទុះឡើង តាមការកើតមានបរិត្តផរណាក្នុងប្រទេសមានសេដ្ឋកិច្ចចម្បងៗ។ នៅត្រីមាសទី៣ នេះ ប្រាក់រៀលឡើងថ្លៃ ០,១% ទល់នឹងប្រាក់ដុល្លារ ធៀបឆ្នាំមុន ដល់ ៤០៥៩,៥រៀល។ ប្រាក់អឺរ៉ូ និងប្រាក់យេន ធ្លាក់ថ្លៃ ០,១% និង ៥,២% រៀងគ្នា ហើយបានផ្ដល់ផលប្រយោជន៍ដល់ការនាំចេញ ព្រោះទំនិញមានថ្លៃប្រកួតប្រជែងជាងមុន។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

នៅត្រីមាសទី៣ ឆ្នាំ២០១៤ ថ្លៃទំនិញសំខាន់ៗក្នុងពិភពលោកបានធ្លាក់ចុះ បើធៀបនឹងឆ្នាំមុន។ ពោតធ្លាក់ថ្លៃ ២៩.០% ធៀបឆ្នាំមុន មកត្រឹម ១៧៤,៨ដុល្លារ/តោន ប្រេងឆាធ្លាក់ថ្លៃ ៦,៨% មកត្រឹម ៧៧០,៧ដុល្លារ/តោន ហើយកៅស៊ូធ្លាក់ថ្លៃ ៣០,២% មកត្រឹម ១៦៧២,១ដុល្លារ/តោន។ អង្ករថៃធ្លាក់ថ្លៃ ១១.០% ធៀបឆ្នាំមុន មកត្រឹម ៤៤៧ដុល្លារ/តោន ហើយសណ្ដែកសៀងធ្លាក់ថ្លៃ ១៥,១% មកត្រឹម ៤៦៣ដុល្លារ/តោន។ ប្រេងឆៅធ្លាក់ថ្លៃ ៥,៧% មកត្រឹម ១០០,៨ដុល្លារ/ធុង សាំងធ្លាក់ថ្លៃ ៤,៤% មកត្រឹម ០,៧០ដុល្លារ/លីត្រ ហើយម៉ាស៊ូតធ្លាក់ថ្លៃ ៧,៣% មកត្រឹម ០,៧៤ដុល្លារ/លីត្រ។ ការធ្លាក់ថ្លៃទំនិញសំខាន់ៗនេះ បានផ្ដល់អត្ថប្រយោជន៍ដល់ប្រទេសនាំចូល ដូចជា កម្ពុជាជាដើម។

---

អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៨-២០១៤ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 6.8 | 0.1 | 6.0 | 6.1 | 6.2 | - | - | - | - | - | - | - |
| ឥណ្ឌូណេស៊ី | 6.1 | 4.2 | 6.2 | 6.5 | 6.3 | 6.0 | 5.8 | 5.6 | 5.7 | 5.2 | 5.1 | 5.0 |
| ម៉ាឡេស៊ី | 4.6 | -2.4 | 9.0 | 4.9 | 5.4 | 4.1 | 4.3 | 5.0 | 5.1 | 6.2 | 6.4 | 5.6 |
| សិង្ហបុរី | 1.1 | -4.5 | 4.7 | 4.7 | 1.3 | 0.2 | 3.7 | 5.8 | 5.5 | 5.1 | 2.4 | 2.4 |
| ថៃ | 2.6 | 3.3 | 7.9 | 0.0 | 6.7 | 5.4 | 2.6 | 2.6 | 0.4 | 3.1 | 0.3 | 0.6 |
| វៀតណាម | 6.2 | 4.7 | 6.7 | 6.1 | 5.0 | - | - | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 9.0 | 8.2 | 10.4 | 9.3 | 7.7 | 7.7 | 7.5 | 7.8 | 7.7 | 7.1 | 7.5 | 7.3 |
| ហុងកុង | 2.4 | -3.2 | 6.9 | 4.9 | 2.9 | 2.8 | 3.3 | 2.9 | 3.0 | 2.5 | 1.8 | 2.7 |
| កូរ៉េខាងត្បូង | 2.2 | -1.0 | 6.1 | 3.6 | 2.1 | 1.5 | 2.3 | 3.3 | 4.0 | 4.1 | 3.5 | 3.2 |
| តៃវ៉ាន់ | 0.1 | -3.6 | 1.1 | 4.2 | 1.2 | 1.7 | 2.3 | 1.7 | 2.9 | 3.1 | 3.7 | 3.8 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 0.9 | -3.8 | 1.6 | 1.6 | -0.5 | 1.1 | -0.7 | -0.4 | 0.5 | 0.9 | 0.7 | 0.3 |
| ជប៉ុន | -0.7 | -5.4 | 4.1 | -0.8 | 1.7 | 0.4 | 0.9 | 2.7 | 2.6 | 3.1 | -0.1 | -1.2 |
| សហរដ្ឋអាមេរិក | 1.1 | -2.5 | 2.7 | 1.8 | 2.1 | 1.8 | 1.4 | 1.6 | 2.5 | 2.3 | 2.6 | 2.3 |

Sources: International Monetary Fund, Economist and countries' statistic offices

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៨-២០១៤ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 19.7 | -0.5 | 4.1 | 5.5 | 3.0 | 1.5 | 2.2 | 3.8 | 4.3 | 4.5 | 4.9 | 4.0 |
| ឥណ្ឌូណេស៊ី | 10.1 | 4.7 | 5.1 | 5.4 | 4.3 | 5.3 | 5.7 | 8.6 | 8.4 | 7.7 | 7.1 | 4.3 |
| ម៉ាឡេស៊ី | 5.3 | 0.4 | 1.7 | 3.2 | 1.7 | 1.4 | 1.8 | 2.2 | 3.0 | 3.5 | 3.3 | 3.0 |
| សិង្ហបុរី | 6.5 | 0.5 | 2.9 | 5.2 | 4.6 | 3.6 | 1.6 | 1.8 | 2.0 | 1.0 | 2.3 | 0.9 |
| ថៃ | 5.5 | -0.9 | 3.1 | 3.8 | 3.0 | 3.1 | 2.3 | 1.7 | 1.7 | 2.0 | 2.5 | 2.0 |
| វៀតណាម | 23.3 | 7.3 | 9.0 | 18.6 | 9.3 | 6.9 | 6.6 | 7.0 | 5.9 | 4.8 | 4.7 | 4.5 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 5.9 | -0.8 | 3.2 | 5.4 | 2.7 | 2.4 | 2.4 | 2.8 | 2.9 | 2.1 | 2.2 | 2.0 |
| ហុងកុង | 4.3 | -0.3 | 2.4 | 5.3 | 4.1 | 2.2 | 4.0 | 5.3 | 4.3 | 4.1 | 3.6 | 4.9 |
| កូរ៉េខាងត្បូង | 4.6 | 2.8 | 3.0 | 4.4 | 2.1 | 1.4 | 1.1 | 1.2 | 0.9 | 1.1 | 1.6 | 1.4 |
| តៃវ៉ាន់ | 3.2 | -1.1 | 1.0 | 1.4 | 1.9 | 1.8 | 0.8 | 0.0 | 0.5 | 1.1 | 1.6 | 1.5 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 3.3 | 0.4 | 1.6 | 2.7 | 2.5 | 1.8 | 1.5 | 1.3 | 0.6 | 0.6 | 0.6 | 0.4 |
| ជប៉ុន | 1.4 | -1.3 | -0.7 | 0.1 | -0.03 | -0.3 | -0.3 | 0.9 | 1.4 | 1.5 | 3.6 | 3.4 |
| សហរដ្ឋអាមេរិក | 3.8 | -0.4 | 1.7 | 3.2 | 2.1 | 1.7 | 1.4 | 1.6 | 1.2 | 1.4 | 2.1 | 1.8 |

Sources: International Monetary Fund, Economist and National Institute of Statistics

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៨-២០១៤ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4054.2 | 4140.5 | 4187.1 | 4063.6 | 4037.8 | 3995.0 | 4032.9 | 4062.0 | 4018.9 | 3993.8 | 4026.9 | 4059.5 |
| ឥណ្ឌូណេស៊ី (រូពីយ៉ា) | 9699.0 | 10413.8 | 9089.9 | 4374.0 | 9363.0 | 9681.9 | 9783.6 | 10,666.0 | 11,545.1 | 11,765.8 | 11,615.3 | 11,775.7 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.3 | 3.5 | 3.2 | 1.5 | 3.1 | 3.1 | 3.0 | 3.2 | 3.2 | 3.3 | 3.2 | 3.2 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.4 | 1.5 | 1.4 | 1.3 | 1.2 | 1.2 | 1.2 | 1.3 | 1.3 | 1.3 | 1.3 | 1.3 |
| ថៃ (បាត) | 33.4 | 34.3 | 31.7 | 30.5 | 31.1 | 29.8 | 29.9 | 31.4 | 31.7 | 32.6 | 32.4 | 32.1 |
| វៀតណាម (ដុង) | 16,382.0 | 17,725.2 | 19,200.8 | 20,574.3 | 20,856.9 | 20,829.6 | 20,828.0 | 20,908.7 | 21,036.0 | 21,036.0 | 21,036.0 | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ៉ន់) | 6.9 | 6.8 | 6.8 | 6.5 | 6.3 | 6.2 | 6.2 | 6.1 | 6.1 | 6.1 | 6.2 | 6.2 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1137.2 | 1277.8 | 1156.3 | 1108.6 | 1126.6 | 1085.9 | 1123.4 | 1108.8 | 1062.0 | 1069.7 | 1028.9 | 1027.5 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 31.5 | 33.0 | 31.3 | 29.4 | 29.6 | 29.5 | 29.9 | 29.9 | 29.6 | 30.3 | 30.1 | 30.0 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.840 | 0.720 | 0.755 | 0.719 | 0.777 | 0.757 | 0.767 | 0.755 | 0.735 | 0.730 | 0.729 | 0.755 |
| ជប៉ុន (យ៉េន) | 102.5 | 93.6 | 87.8 | 79.9 | 79.8 | 92.3 | 98.8 | 98.9 | 100.5 | 102.8 | 102.1 | 104.0 |

Sources: International Monetary Fund, Economist and National Bank of Cambodia

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៨-២០១៤ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ពោត (US No. 2) - USA (USD/តោន) | 218.2 | 167.3 | 167.3 | 291.4 | 296.5 | 305.2 | 291.4 | 246.2 | 199.3 | 209.6 | 214.7 | 174.8 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 912.2 | 686.8 | 834.7 | 1125.4 | 999.3 | 852.7 | 850.3 | 827.3 | 897.3 | 911.3 | 887.3 | 770.7 |
| កៅស៊ូ SMR 5 (USD/តោន) | 2586.3 | 1884.8 | 3152.2 | 4630.6 | 3200.7 | 3029.5 | 2497.2 | 2394.6 | 2380.0 | 2034.7 | 1777.6 | 1672.1 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 615.3 | 524.5 | 456.2 | 558.5 | 594.8 | 607.0 | 570.0 | 502.3 | 455.7 | 450.7 | 411.7 | 447.0 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 460.4 | 414.0 | 375.4 | 507.9 | 566.1 | 558.4 | 569.8 | 545.1 | 514.9 | 533.0 | 565.7 | 463.0 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 95.4 | 60.5 | 71.6 | 106.2 | 109.5 | 109.5 | 100.9 | 106.9 | 106.4 | 104.7 | 105.9 | 100.8 |
| សាំង - US Gulf Coast (សេន/លីត្រ) | 62.2 | 42.9 | 49.8 | 71.9 | 74.6 | 74.8 | 71.2 | 73.3 | 65.7 | 70.1 | 74.1 | 70.0 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 51.6 | 75.7 | 83.8 | 77.8 | 80.7 | 80.3 | 81.5 | 75.6 | 79.6 | 77.5 | 77.1 | 73.7 |

Sources: Food and Agriculture Organisation and US Energy Information Administration

# តាមដានសេដ្ឋកិច្ច – ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

ក្នុងត្រីមាសទី៣ អនុមតិវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ មានចំនួន ៦២៥,៨លានដុល្លារ ធៀបនឹង ២៥៧,៩លានដុល្លារ កាលពីឆ្នាំមុន ក្នុងនេះ ៦៩,៤% ស្ថិតក្នុងវិស័យឧស្សាហកម្ម (៤៣៤,៤លានដុល្លារ), ៣០,៦% ក្នុងវិស័យសេវាកម្ម ហើយមិនមានអនុមតិវិនិយោគក្នុងវិស័យកសិកម្មទេ។ វិនិយោគក្នុងវិស័យកាត់ដេរ កើន ២៥,២% ធៀបឆ្នាំមុន ដល់ ៨១,៦លានដុល្លារ។ វិនិយោគ និងការនាំចេញផលិតផលសម្លៀកបំពាក់ និងវាយនភ័ណ្ឌ មានកំណើនខ្លាំងក្នុងពេលកំពុងមានភាពតានតឹងខាងនយោបាយ កូដកម្ម និងការបន្តការជជែកដេញដោលអំពីប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភក៏ពិតមែន ប៉ុន្តែអាទិភាពចម្បងមួយសម្រាប់រដ្ឋាភិបាល និងវិស័យឯកជន គឺការធ្វើពិពិធកម្មចូលទៅក្នុង វិស័យនានាដែលមានឧត្តមភាពប្រៀបធៀបខ្ពស់ ។

សេវាកម្មជា វិស័យរួមចំណែកចម្បងមួយក្នុង កំណើនផសស ទាំងក្នុងពេលកន្លងមក និងទៅថ្ងៃអនាគត។ នៅត្រីមាសទី៣ វិនិយោគក្នុងវិស័យនេះ កើន ២៨៩,១លានដុល្លារ ធៀបនឹង ៥,៣លានដុល្លារកាលពីឆ្នាំមុន ក្នុងនេះវិស័យសណ្ឋាគារ និងបដិសណ្ឋារៈ មានចំណែក ៩៣%។ នៅត្រីមាសដដែលនេះ អ្នកទេសចរមកដល់កម្ពុជា កើន ៣,៥% ធៀបឆ្នាំមុនដល់ ៩៩៨.៦៩០នាក់។ ចំនួនភ្ញៀវទេសចរមកដល់កម្ពុជាតាមផ្លូវអាកាស កើន ១៦,២% រីឯភ្ញៀវមកដល់តាមផ្លូវគោក ឬផ្លូវទឹកធ្លាក់ចុះ ៦,៦%។ កំណើនចំនួនភ្ញៀវទេសចរមកកម្ពុជា ក្នុងរយៈពេល ២ឆ្នាំចុងក្រោយនេះ មានអត្រាមិនសូវខ្ពស់ទេ។

ការនាំចេញកើន ៨,៣% ធៀបឆ្នាំមុន។ ការនាំចេញសម្លៀកបំពាក់ដែលមានចំណែក ៧៦,២% ក្នុងតម្លៃនាំចេញសរុបនោះ កើន ៣,៦% ដល់ ១,៦ពាន់លានដុល្លារ។ សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុបនៅតែជា ទីផ្សារចម្បងសម្រាប់ផលិតសម្លៀកបំពាក់ និងវាយនភ័ណ្ឌ ដោយរួមចំណែក ៣១,៥% និង ៤១,៥% រៀងគ្នា។ ទោះយ៉ាងណាក្តី ការនាំចេញសម្លៀកបំពាក់ទៅសហរដ្ឋអាមេរិកធ្លាក់ចុះ ១៤,៥% ធៀបនឹងឆ្នាំមុន។ ការនាំចេញសម្លៀកបំពាក់ ទៅប្រទេសសមាជិកអាស៊ានកើន ១៧,៨% និងទៅជប៉ុនកើន ១៩,៨% ប៉ុន្តែការនាំចេញទៅប្រទេសទាំងនេះ រួមចំណែកត្រឹមតែ ១,៣% និង ៧,២% រៀងគ្នា ក្នុងការនាំចេញសរុបប៉ុណ្ណោះ។ ការធ្វើចម្រុះកម្មទីផ្សារ និងអនុវិស័យនេះ វាចាំបាច់បំផុតដើម្បីកាត់បន្ថយការប៉ះទង្គិចពីខាងក្រៅទៅថ្ងៃមុខទៀត។ ការកើនឡើងនៃបៀវត្សរ៍អប្បបរមា និងការបើកចំហប្រទេសមីយ៉ាន់មា ជាកត្តាពីរទៀតដែលគួរលើកមកជជែកវែកញែកសម្រាប់ការធ្វើពិពិធកម្ម។

នៅត្រីមាសទី៣ នេះដែរ ការនាំចេញផលិតផលកសិកម្មរួមចំណែក ៦,៣% នៃការនាំចេញសរុប ឬកើន ៣,៨% ធៀបឆ្នាំមុន។ ការនាំចេញកៅស៊ូធ្លាក់ចុះ ២៨,៨% អង្ករធ្លាក់ចុះ ២,៧% ហើយត្រីធ្លាក់ចុះ ២៧,៨%។ ការធ្លាក់ចុះនេះបណ្តាលជាសំខាន់មកពី ការធ្លាក់ថ្លៃនៅលើទីផ្សារពិភពលោក។ នៅត្រីមាសទី៣ កៅស៊ូលើទីផ្សារពិភពលោកបន្តធ្លាក់ថ្លៃ មកត្រឹម ១៦៧២,១ដុល្លារ/តោន។ អង្ករថៃធ្លាក់ថ្លៃ ១១% ធៀបឆ្នាំមុនមកត្រឹម ៤៤៧ដុល្លារ/តោន។ ការពឹងផ្អែកខ្លាំងរបស់កសិករកម្ពុជា ទៅលើទីផ្សារថៃ និងវៀតណាម អាចធ្វើឲ្យថយចុះនូវអំណាចក្នុងការតថ្លៃរបស់ពួកគេ។

នៅត្រីមាសទី៣ ការនាំចូលកើន ៣៥,៧% ធៀបឆ្នាំមុនដល់ ២,៨ពាន់លានដុល្លារ។ ការនាំចូលសាំងកើន ១២,៥% ម៉ាសូតកើន ៨,៣% ហើយសម្ភារសំណង់កើន ៦០,៩%។ ការនាំចូលសាំងអាចកើនឡើង ដោយសារមានការធ្លាក់ថ្លៃប្រេងអន្តរជាតិ។ នៅត្រីមាសទី៣ ឱនភាពពាណិជ្ជកម្ម មានតម្លៃសរុប ៦៦២,៣លានដុល្លារ ធៀបនឹង ៨៩,៨ពាន់លានដុល្លារកាលពីឆ្នាំមុន។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី៣ ចំណូលសរុបរបស់រដ្ឋាភិបាលកើន ៣៨,១% ធៀបឆ្នាំមុន ដល់ ២៥៨០,៦ពាន់លានរៀល (៦៣៦លានដុល្លារ) ក្នុងនោះ ចំណូលចរន្តកើន ៣៨,៤% ដល់ ២៥៧១,៤ពាន់លានរៀល។ ចំណូលពន្ធមានចំណែក ៨៨% នៃចំណូលសរុប ឬកើន ៣៧,៦% ដល់ ២២៦៤,៦ពាន់លានរៀល (៥៥៨លានដុល្លារ)។ ចំណូលមិនមែនពន្ធកើន ៤៤,៦%។ នៅត្រីមាសដដែល ចំណាយសរុបធ្លាក់ចុះ ១៩,៨% មកត្រឹម ២៤៨០ពាន់លានរៀល ដោយសារមួយផ្នែកមកពីចំណាយមូលធនធ្លាក់ចុះ ៥៧,៧% ធៀបឆ្នាំមុន។ ចំណាយចរន្តកើន ៩,៦% ដល់ ១៩០៩,៥ពាន់លានរៀល ចំណាយលើបៀវត្សរ៍និងឧបត្ថម្ភធន និង ជំនួយសង្គមដទៃទៀត កើន ៩,៥% និង ៥២,២% រៀងគ្នា។ អតិរេកថវិកា មាន ១០០,៥ពាន់លានរៀល ធៀបនឹងឱនភាព ១២២៤,១ពាន់លានរៀល កាលពីឆ្នាំមុន។ កំណើនការប្រមូលចំណូល និងការកាត់បន្ថយចំណាយខ្ជះខ្ជាយនៅតែជាអាទិភាពដដែល។ កិច្ចប្រឹងប្រែងនាពេលថ្មីៗដើម្បីពង្រឹងការប្រមូលពន្ធ (ទ្រព្យសម្បត្តិ, ដីធ្លី និងប្រាក់ចំណូល) ទទួលបានប្រតិកម្មចម្រុះពីសាធារណជន។ ទោះយ៉ាងនេះក្តី នីតិវិធីនិងការប្រមូលពន្ធដែលសាមញ្ញ មានប្រសិទ្ធភាព និងមានសមធម៌ ទទួលបានការអបអរសាទរ។ ការប្រើប្រាស់ប្រាក់ពន្ធប្រកបដោយតម្លាភាព ក៏ជាកត្តាចាំបាច់ដែរ។

---

អត្ថបទនេះរៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៣ ថ្លៃទំនិញប្រើប្រាស់សរុបកើន ៤,០% ធៀបនឹង ៣,៧% កាលពី ១២ខែមុន។ ថ្លៃអាហារ និងភេសជ្ជៈគ្មានជាតិស្រា កើនយ៉ាងគំហុកដល់ ៥,១%។ ថ្វីបើអតិផរណាមានតួលេខកំណើនត្រឹមមួយខ្ទង់ក្តី ប៉ុន្តែវាបានកើនឡើងរហូតចាប់ពីឆ្នាំ២០១២ មក។ ប្រាក់រៀល ឡើងថ្លៃ ០,១% ធៀបនឹងឆ្នាំមុនទល់នឹងប្រាក់ដុល្លារ និងឡើងថ្លៃ ៣,២% ទល់នឹងប្រាក់បាតថៃ។ មាសធ្លាក់ថ្លៃ ៣,៥% ធៀបឆ្នាំមុន មកត្រឹម ១៥៥,៥ដុល្លារ/ជី រីឯម៉ាស៊ូត និងសាំង ឡើងថ្លៃ ០,៥% និង ២,០% រៀងគ្នា។

## ការវិវត្តរូបិយវត្ថុ

នៅត្រីមាសទី៣ សាច់ប្រាក់ងាយស្រួលសរុប កើន ៣៨,៩% ធៀបឆ្នាំមុន, រូបិយវត្ថុកើន ១៨,៣% ហើយរូបិយវត្ថុផ្សេងៗកើន ៤២,៨%។ ទ្រព្យសកម្មបរទេសសុទ្ធកើន ៤៣,៣% ធៀបឆ្នាំមុន ហើយទ្រព្យសកម្មក្នុងស្រុកសុទ្ធកើន ៣១,២%។ ឥណទានផ្តល់ឲ្យវិស័យឯកជន កើន ២៥,៦% ធៀបនឹងឆ្នាំមុន ដែលជាដំណឹងល្អសម្រាប់អាជីវកម្មឯកជន ប៉ុន្តែកំណើនការផ្គត់ផ្គង់រូបិយវត្ថុ អាចមានទំនាក់ទំនងវិជ្ជមានជាមួយនឹង អតិផរណាក្នុងរយៈពេលវែង។ ថ្លៃទំនិញសរុបមាននិន្នាការកើនឡើង ថ្វីបើវាស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបានក្តី។ ដូច្នេះ គួរមានការពិនិត្យតាមដានឲ្យបានដិតដល់លើកំណើនការផ្គត់ផ្គង់រូបិយវត្ថុ និងអតិផរណាក្នុងរយៈពេលវែង។ ធនាគារកណ្តាលក៏គួរធានាដែរថា វិស័យធនាគារមានសុខភាពល្អ ហើយឥណទានផ្តោតចំបណ្តាវិស័យមានផលិតភាពខ្ពស់។

## ស្ថានភាពក្រីក្រ

នៅខែវិច្ឆិកា ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ អ្នករើសអេតចាយ បានធ្លាក់ចុះធៀបនឹងឆ្នាំមុន។

បើធៀបនឹងអង្កេតលើកមុន ចំណូលរបស់កម្មករសំណង់មានជំនាញ ធ្លាក់ចុះ ១០% មកត្រឹម ១៨.៣០២រៀល/ថ្ងៃ។ សកម្មភាពសាងសង់បានកើនឡើង ប៉ុន្តែមានកម្មករកាន់តែច្រើនជាងមុន មកប្រជែងគ្នារកការងារធ្វើ។ អ្នកឆ្លើយសម្ភាសន៍ទាំងអស់ជាអ្នកមកពីខេត្ត ជាពិសេស ខេត្តស្វាយរៀង (៤០%) និង ព្រៃវែង (២៣%)។ ពួកគេជាប្រភពចំណូលចម្បងក្នុងគ្រួសារ។ កម្មករ ៦០% ធ្វើដំណើរមកភ្នំពេញតែម្នាក់ឯង ហើយ ៨៥% ស្នាក់នៅតាមការដ្ឋានគាត់ធ្វើការ។ កម្មករចំណាយប្រាក់រកបានអស់ជាមធ្យម ប្រហែលពាក់កណ្តាលទៅលើចំណាយប្រើប្រាស់ប្រចាំថ្ងៃ ជាពិសេស ម្ហូបអាហារដែលមានចំណែក ៩១% នៃចំណាយសរុប។ កម្មករ ៦៥% ប្រាប់ថា អាចទ្រទ្រង់ជីវភាពគ្រួសារបានតែមួយចំណែកប៉ុណ្ណោះ ហើយគ្រួសារគាត់ត្រូវពឹងផ្អែកផងដែរលើការចិញ្ចឹមសត្វ។

នៅខែវិច្ឆិកា ប្រាក់ចំណូលរបស់អ្នកស៊ីឈ្នួលធ្វើស្រែ ធ្លាក់ចុះ ២៣% ធៀបនឹងអង្កេតលើកមុន មកត្រឹម ៦៧៨១រៀល/ថ្ងៃ។ អ្នកឆ្លើយសម្ភាសន៍ ៥៣% មិនមានដីទេ ហើយអ្នកដទៃទៀតមានតិចជាង ១ហិចតា។ ពួកគេជាអ្នករកស៊ីចិញ្ចឹមគ្រួសារ ប៉ុន្តែរកមិនបានគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ជីវភាពគ្រួសារទេ ព្រោះមិនអាចរកការងារធ្វើបានពេញៗមួយខែ។ កម្មកររហូតដល់ ៨៣% ត្រូវខ្ចីប្រាក់គេ ឬសុំជំនួយពីសាច់ញាតិ ហើយអ្នកដទៃទៀតត្រូវពឹងផ្អែកលើធនធានទ្រព្យរួម និងការងារផ្សេងៗទៀត។

ចំណូលរបស់អ្នកបម្រើតាមភោជនីយដ្ឋាន កើន ២៥% ដល់ ៩៤៣៥រៀល/ថ្ងៃ ដោយសារពេលនេះចំរដូវកាលឈប់សំរាក។ កម្មករចាយវាយអស់ត្រឹមតែ ៣៨% នៃចំណូលប្រចាំថ្ងៃប៉ុណ្ណោះ ជាពិសេសលើ ម្ហូបអាហារ ពីព្រោះកន្លែងស្នាក់នៅ ម្ចាស់ហាងមានផ្តល់ឲ្យ។ ទោះយ៉ាងនេះក្តី ពួកគេមិនអាចសន្សំប្រាក់ទេ ព្រោះលុយរកបានភាគច្រើនត្រូវផ្ញើទៅឲ្យគ្រួសារ ។

អ្នកធាក់ស៊ីក្លូរកបាន ១១.៦៣៤រៀល/ថ្ងៃ ឬ ១៨% ច្រើនជាងកាលពីអង្កេតលើកមុន។ អ្នកឆ្លើយសម្ភាសន៍ ៦៨% ប្រាប់ថា ចំនួនអ្នកធាក់ស៊ីក្លូបានធ្លាក់ចុះ។ ត្រឹមតែ ៣៥% នៃអ្នកធាក់ស៊ីក្លូប៉ុណ្ណោះដែលមានស៊ីក្លូផ្ទាល់ខ្លួន រីឯអ្នកដទៃទៀតត្រូវជួលស៊ីក្លូគេ។ អ្នកឆ្លើយសម្ភាសន៍ ប្រាប់ថា គាត់ស្នាក់នៅតាមដងផ្លូវ ឬនៅក្នុងវត្ត ឬក៏ផ្ទះរបស់ម្ចាស់ស៊ីក្លូ។ ពួកគាត់ត្រូវទ្រទ្រង់ជីវភាពគ្រួសារ ប៉ុន្តែមានតែ ២៥% ប៉ុណ្ណោះដែលនិយាយថា អាចរកចំណូលបានគ្រប់គ្រាន់សម្រាប់ដោះស្រាយតម្រូវការចាយវាយក្នុងគ្រួសារ។ អ្នកធាក់ស៊ីក្លូបានត្អូញត្អែរពីចំណាយប្រចាំថ្ងៃដ៏ខ្ពស់ដែលស្រូបអស់ ៨៩% នៃចំណូលរបស់គាត់។

ចំណូលរបស់អ្នកលក់បន្លែ កើន ១៥% ធៀបនឹងកាលពីខែសីហា ដល់ ១៧.៧៣៥រៀល/ថ្ងៃ ដោយសារជាសំខាន់វាចំពេលមានបុណ្យទានច្រើន។ ពួកគាត់ ៦០% មកពីខេត្តកណ្តាល ហើយត្រូវត្រឡប់ទៅផ្ទះវិញក្រោយពីលក់បន្លែអស់។ អ្នកលក់ ៧៣% ត្រូវការដើមទុនបន្ថែមដើម្បីពង្រីកអាជីវកម្មរបស់ខ្លួន។

ចំណូលប្រចាំថ្ងៃរបស់អ្នករើសអេតចាយ កើន ១៥% ធៀបនឹងអង្កេតលើកមុន ដល់ ៩.៥៤៨រៀល។ អ្នកឆ្លើយសម្ភាសន៍ ៨៥% មកពីខេត្ត ហើយមួយចំនួនធំមកពីខេត្តព្រៃវែង។ ពួកគេធ្វើដំណើរមករាជធានីភ្នំពេញជាមួយគ្រួសារ។ អ្នករើសអេតចាយ ៦៨% ប្រាប់ថា គាត់មិនអាចពឹងផ្អែកលើ ប្រាក់ចំណូលរបស់គាត់ទេ ហើយត្រូវខ្ចីប្រាក់គេសម្រាប់តែទិញម្ហូបអាហារ។

ប្រាក់ចំណូលរបស់កម្មកររោងចក្រកាត់ដេរ កើន ៤,៩% ធៀបនឹងអង្កេតលើកមុន ដល់ ១២.០៩២រៀល/ថ្ងៃ។ ពួកគេ ៤៦% ប្រាប់ថា ខ្លួនទទួលបានការងារបន្ថែមម៉ោងជារឿយៗ។ កម្មករមិនអាចសន្សំប្រាក់រកបាននោះឡើយ ព្រោះត្រូវចំណាយមួយភាគធំលើម្ហូបអាហារ និងត្រូវផ្ញើប្រាក់ទៅឲ្យគ្រួសារថែមទៀត។ កម្មករ ៣៨% មិនចង់ប្តូរការងារទេ ព្រោះមិនអាចរកការងារដទៃធ្វើបាន ដោយសារខ្លួនមានការអប់រំ និងជំនាញតិចតួច។

# តាមដានសេដ្ឋកិច្ច – សូចនាករ

## តារាង ១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៨-១៤*

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 92.0 | 615.0 | 530.68 | 725 | 531.6 | 2.3 | 57.8 | 133.1 | 738.3 | 28.9 | 27.6 | 0.0 |
| ឧស្សាហកម្ម | 724.9 | 818.5 | 403.66 | 2860.1 | 829.3 | 195.4 | 1928.3 | 119.5 | 1014.1 | 179.0 | 239.3 | 434.3 |
| *កាត់ដេរ* | 142.8 | 90.1 | 122.81 | 393.9 | 497.0 | 109.5 | 76.4 | 65.15 | 73.1 | 109.3 | 172.4 | 81.6 |
| សេវាកម្ម | 10,003.2 | 4432.0 | 1337.34 | 3425.4 | 916.6 | 21.2 | 106.0 | 5.3 | 8.3 | 219.1 | 114.4 | 289.1 |
| *សណ្ឋាគារ និងទេសចរណ៍* | 8758.1 | 3980.1 | 1105.14 | 2850.9 | 691.5 | 0.0 | 106.0 | 0.0 | 0.0 | 163.3 | 15.4 | 268.1 |
| សរុប | 10,570.9 | 5865.5 | 2271.7 | 7010.42 | 2278.0 | 218.9 | 2091.1 | 257.9 | 1760.7 | 426.9 | 302.2 | 625.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | -81.1 | 855.5 | -87.7 | 582.8 | -75.8 | -29.2 | 64.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 308.6 | -44.5 | -61.3 | 209 | -67.5 | -47.5 | 666.0 | -39.9 | 52.2 | 95.1 | -81.8 | 142.7 |

* Including expansion project approvals. Source: Cambodian Investment Board

## តារាង ២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៧-១៤

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 79.1 | 154.7 | 64.3 | 36.2 | 185.5 | 175.2 | 145.2 | 10.3 | 51.6 | 110.2 | 27.1 | 8.8 |
| ផ្ទះល្វែង | 297.2 | 221.6 | 149.6 | 183.8 | 219.6 | 372.1 | 114.1 | 33.0 | 62.7 | 131.9 | 106.5 | 75.2 |
| ផ្សេងៗ | 259.6 | 740.9 | 227.3 | 269.7 | 199.9 | 463.6 | 154.4 | 238.3 | 336.0 | 130.8 | 190.0 | 141.7 |
| សរុប | 635.8 | 1117.0 | 441.2 | 489.8 | 605.0 | 1010.9 | 413.7 | 281.6 | 450.3 | 372.9 | 323.6 | 225.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | 130.3 | -36.5 | 59.9 | -17.2 | -13.2 | -30.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 96.7 | 75.7 | -60.5 | 11.0 | 23.5 | 67.1 | 28.1 | -15.6 | 157.5 | 107.6 | -21.8 | -19.8 |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង ៣. ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៨-១៤

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 1239.4 | 1111.7 | 1304.3 | 1480.4 | 1722.1 | 611.2 | 398.1 | 428.0 | 580.4 | 699.0 | 438.2 | 497.5 |
| តាមផ្លូវគោក និងទឹក | 881.9 | 999.7 | 1094.6 | 1401.4 | 1862.2 | 560.9 | 522.5 | 536.6 | 572.5 | 569.0 | 495.2 | 501.2 |
| សរុប | 2121.3 | 2111.5 | 2398.9 | 2881.8 | 3584.3 | 1172.1 | 920.5 | 964.6 | 1153.0 | 1268.0 | 933.4 | 998.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 16.4 | -21.5 | 4.8 | 19.5 | 10.0 | -26.4 | 7.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 5.3 | 0.5 | 13.6 | 20.1 | 24.4 | 17.8 | 20.9 | 17.5 | 14.5 | 8.0 | 1.4 | 3.5 |

Source: Ministry of Tourism

## តារាង ៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៨-១៤*

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 3097.8 | 2901.6 | 3630.2 | 4929.5 | 6106.4 | 1576.9 | 1620.1 | 1969.9 | 1815.4 | 1976.5 | 1859.8 | 2132.5 |
| ក្នុងនេះ៖ សម្លៀកបំពាក់ | 2986.2 | 2565.3 | 3223.4 | 4259.6 | 5015.4 | 1225.2 | 1259.0 | 1568.5 | 1333.4 | 1464.0 | 1379.2 | 1624.7 |
| - *សហរដ្ឋអាមេរិក* | 1908.3 | 1512.6 | 1853.9 | 2055.3 | 2143.3 | 526.8 | 474.6 | 597.9 | 476.0 | 531.1 | 452.5 | 511.2 |
| - *សហភាពអឺរ៉ុប* | 689.0 | 644.7 | 809.5 | 1322.2 | 1716.9 | 397.5 | 477.5 | 572.8 | 521.9 | 532.7 | 558.5 | 673.8 |
| - *អាស៊ាន* | 10.76 | 6.9 | 9.9 | 17.6 | 39.4 | 13.0 | 12.7 | 17.4 | 17.2 | 21.9 | 19.3 | 20.5 |
| - *ជប៉ុន* | 25.2 | 44.5 | 86.5 | 147.0 | 188.6 | 57.6 | 51.4 | 98.1 | 71.6 | 101.4 | 74.9 | 117.6 |
| - *ប្រទេសផ្សេងៗ* | 352.9 | 356.5 | 463.6 | 717.5 | 927.2 | 230.3 | 242.8 | 282.4 | 247.4 | 277.0 | 273.9 | 301.6 |
| កសិកម្ម | 44.5 | 73.1 | 164.9 | 362.1 | 376.7 | 123.8 | 128.9 | 362.4 | 173.0 | 167.0 | 157.3 | 133.7 |
| - *កៅស៊ូ* | 35.8 | 51.6 | 89.1 | 197.6 | 176.6 | 36.6 | 38.7 | 282.4 | 51.1 | 31.7 | 40.0 | 34.8 |
| - *ឈើ* | 3.4 | 3.5 | 34.1 | 48.8 | 36.8 | 14.5 | 8.9 | 16.9 | 33.3 | 55.9 | 48.4 | 19.6 |
| - *ត្រី* | 2.3 | 3.9 | 2.8 | 3.1 | 2.0 | 0.3 | 0.5 | 0.2 | 0.2 | 0.3 | 0.2 | 0.1 |
| - *អង្ករ* | 2.6 | 10.9 | 34.7 | 106.6 | 146.4 | 65.8 | 56.5 | 57.3 | 82.7 | 57.9 | 52.8 | 55.8 |
| - *ផលិតផលកសិកម្មផ្សេងៗ* | 0.5 | 3.0 | 4.1 | 6.0 | 14.9 | 6.6 | 24.4 | 5.7 | 5.7 | 21.2 | 16.0 | 23.5 |
| ផ្សេងៗ | 67.1 | 263.2 | 242.0 | 307.9 | 714.4 | 274.9 | 232.2 | 272.6 | 308.5 | 345.5 | 323.3 | 373.0 |
| ការនាំចូលសរុប | 4272.5 | 4331.5 | 5190.6 | 6375.9 | 8593.3 | 2192.1 | 2211.4 | 2059.7 | 2130.1 | 2238.2 | 2454.4 | 2794.8 |
| ក្នុងនេះ៖ | | | | | | | | | | | | |
| សាំង | 84.8 | 91.13 | 108.6 | 294.4 | 308.0 | 1225.2 | 77.2 | 71.3 | 80.5 | 77.4 | 83.2 | 80.2 |
| ម៉ាស៊ូត | 19.5 | 180.67 | 203.8 | 447 | 559.5 | 526.8 | 137.4 | 150.9 | 132.2 | 148.5 | 142.5 | 163.4 |
| សម្ភារៈសំណង់ | 56.3 | 49.74 | 57.6 | 48.1 | 66.1 | 397.5 | 17.8 | 18.0 | 17.2 | 27.8 | 29.2 | 29.0 |
| ផ្សេងៗ | 4011.8 | 4010 | 4820.6 | 5586.4 | 7659.1 | 13.0 | 1979 | 1819.4 | 1899.6 | 1984.5 | 2199.5 | 2522.2 |
| ជញ្ជីងពាណិជ្ជកម្ម | -1174.7 | -1429.9 | -1560.5 | -1446.4 | -1341.6 | -615.2 | -591.2 | -89.8 | -314.7 | -261.7 | -589.5 | -662.3 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | 7.4 | 2.8 | 24.6 | -15.0 | 9.8 | -5.8 | 17.8 |
| ការនាំចេញសរុប | - | - | - | - | - | 8.4 | 2.7 | 21.6 | -7.8 | 8.9 | -5.9 | 14.7 |
| ការនាំចូលសរុប | - | - | - | - | - | 13.1 | 0.9 | -6.9 | 3.4 | 5.1 | 9.4 | 14.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 1.6 | -14.1 | 25.7 | 32.1 | 17.7 | 14.4 | -14.6 | 18.0 | 16.9 | 19.5 | 9.6 | 3.6 |
| ការនាំចេញសរុប | 1.6 | -6.3 | 25.1 | 35.8 | 23.9 | 23.2 | -8.8 | 23.4 | 24.8 | 25.3 | 14.8 | 8.3 |
| ការនាំចូលសរុប | 13.3 | 1.4 | 19.8 | 22.8 | 16.8 | 36.2 | 17.3 | 2.2 | 9.9 | 2.1 | 10.8 | 35.7 |

* Import data include tax-exempt imports.
Sources: Department of Trade Preference Systems, MOC and Customs and Excise Department, MEF (website)

## តារាង ៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៨-១៤ (ពាន់លានរៀល)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ចំណូលសរុប | 5290.0 | 4885.2 | 5989.0 | 6251.4 | 7691.9 | 1820.2 | 2204.8 | 1868.9 | 2361.2 | 2220.5 | 2793.7 | 2580.6 |
| ចំណូលចរន្ត | 5210.7 | 4855.9 | 5859.1 | 6179.3 | 7443.8 | 1817.4 | 2241.3 | 1858.1 | 2316.3 | 2219.2 | 2765.2 | 2571.4 |
| ចំណូលពន្ធ | 4409.9 | 4268.0 | 4693.0 | 5277.5 | 6334.8 | 1577.7 | 2024.0 | 1646.0 | 1950.4 | 1988.7 | 2383.1 | 2264.6 |
| ពន្ធក្នុងស្រុក | 3248.4 | 3088.6 | 3533.6 | 4071.6 | 5002.8 | 1254.5 | 1652.9 | 1300.6 | 1520.1 | 1593.6 | 1943.2 | 1798.0 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1161.5 | 1064.7 | 1159.4 | 1205.9 | 1331.7 | 323.1 | 371.1 | 345.4 | 430.3 | 449.0 | 439.9 | 466.5 |
| ចំណូលមិនមែនពន្ធ | 800.8 | 702.1 | 1166.1 | 901.8 | 1118.2 | 239.8 | 217.4 | 212.2 | 365.9 | 176.6 | 382.1 | 306.9 |
| ចំណូលលើទ្រព្យសម្បត្តិ | 78.0 | 64.6 | 291.1 | 63.8 | 143.0 | 8.4 | 18.1 | 24.3 | 33.2 | 11.1 | 40.8 | 21.2 |
| លក់ទំនិញ និងសេវា | 424.7 | 408.0 | 460.1 | 588.7 | 667.4 | 153.3 | 173.3 | 178.8 | 245.0 | 160.3 | 197.5 | 212.9 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 298.2 | 228.2 | 408.9 | 249.3 | 298.8 | 78.1 | 25.9 | 9.0 | 87.7 | 5.2 | 143.7 | 72.7 |
| ចំណូលជាមូលធន | 79.3 | 29.3 | 129.9 | 72.1 | 247.9 | 6.2 | 11.5 | 10.7 | 45.0 | 1.3 | 28.5 | 9.2 |
| ចំណាយសរុប | 6297.8 | 7383.5 | 8784.6 | 9032.4 | 9660.9 | 2114.8 | 3181.6 | 3093.0 | 4146.4 | 2078.6 | 2371.9 | 2480.1 |
| ចំណាយជាមូលធន | 2574.4 | 2694.9 | 2853.2 | 3546.9 | 3628.3 | 1108.4 | 1273.7 | 1350.6 | 1834.8 | 646.9 | 900.5 | 570.7 |
| ចំណាយចរន្ត | 3809.0 | 4440.0 | 4773.1 | 5341.2 | 6188.4 | 1006.4 | 1907.8 | 1742.4 | 2311.6 | 1431.7 | 1471.4 | 1909.5 |
| បៀវត្សរ៍ | 1397.0 | 2012.0 | 2048.8 | 2170.6 | 2486.6 | 505.0 | 757.0 | 827.3 | 908.0 | 860.0 | 931.0 | 905.7 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 927.1 | 871.4 | 1099.4 | 1518.8 | 1586.8 | 252.0 | 652.5 | 285.0 | 373.4 | 213.1 | 259.6 | 433.7 |
| ចំណាយចរន្តផ្សេងទៀត | 1384.9 | 1556.6 | 1624.8 | 1651.8 | 2115.1 | 249.4 | 498.3 | 630.1 | 1030.2 | 358.6 | 280.8 | 570.1 |
| សមតុល្យជាទូទៅ | -1007.8 | -2498.3 | -2795.7 | -1271.4 | -1969.0 | -294.6 | -976.7 | -1224.1 | -1785.2 | 141.9 | 421.8 | 100.5 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 2055.10 | 1746.1 | 1845.2 | -2781.0 | 2457.8 | 906.0 | 1150.6 | 1032.2 | 1237.4 | 440.7 | 623.8 | 164.0 |
| ហិរញ្ញប្បទានក្នុងស្រុក | -127.00 | 474.9 | 938.6 | 2379.2 | -332.9 | -470.6 | 270.3 | 113.0 | 65.8 | 123.7 | 249.9 | 347.6 |

Source: MEF website

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៨-១៤

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| (តុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 19.7 | -0.7 | 4.1 | 5.4 | 2.3 | 1.5 | 2.3 | 3.7 | 4.7 | 4.6 | 4.8 | 4.0 |
| - ស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 33.1 | -0.3 | 4.4 | 6.5 | 2.5 | 1.6 | 3.3 | 4.8 | 5.8 | 5.7 | 5.3 | 5.1 |
| - ដឹកជញ្ជូន | 19.4 | -10.7 | 7.0 | 6.9 | 3.3 | -0.7 | -1.0 | -0.1 | -0.4 | -1.1 | 0.5 | -0.2 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4058.2 | 4140.5 | 4187.1 | 4063.6 | 4039.2 | 3995.0 | 4033.1 | 4062.0 | 4059.0 | 3993.8 | 4026.9 | 4059.5 |
| រៀលក្នុង ១ បាតថៃ | 123.5 | 121.1 | 133.1 | 133.2 | 130.0 | 134.7 | 135.74 | 131.4 | 130.7 | 123.0 | 124.8 | 127.1 |
| រៀលក្នុង ១០០ ដុងវៀតណាម | 24.8 | 23.4 | 21.72 | 19.7 | 19.4 | 19.3 | 19.34 | 19.3 | 19.4 | 19.1 | 19.2 | 19.2 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 105.9 | 113.1 | 147.5 | 184.5 | 200.9 | 197.3 | 173.4 | 161.1 | 171.8 | 156.6 | 155.9 | 155.5 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 4555.2 | 3170.9 | 3859.3 | 4761.2 | 4941.2 | 5134.4 | 4992.0 | 5022.5 | 4927.0 | 4971.2 | 5006.7 | 5047.6 |
| ថ្លៃសាំង (រៀល/លីត្រ) | 4750.8 | 3593.1 | 4368.1 | 5044.5 | 5312.7 | 5410.5 | 5274.5 | 5245.2 | 5126.7 | 5171.5 | 5200.0 | 5348.6 |

Sources: NIS, NBC and CDRI

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៨-១៤ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 10,345.0 | 14,655.0 | 16,697.9 | 17,893.9 | 18,154.5 | 19,976.7 | 21,772.9 | 18,720.7 | 21,260.1 | 23,344.4 | 26,235.8 | 26,817.8 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 15,13.3 | 1573.0 | 2778.9 | 5760.8 | 10,437.4 | 10,504.1 | 9886.1 | 10,634.8 | 11,508.3 | 11,817.4 | 12,024.4 | 13,950.5 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -2987.0 | -2252.0 | -2126.6 | -2123.1 | -2486.4 | -2991.6 | -3012.6 | -2804.4 | -2794.9 | -3349.3 | -3747.3 | -4113.0 |
| ឥណទានដល់ផ្នែកឯកជន | 9894.0 | 10,532.0 | 13,331.2 | 17,552.8 | 23,536.6 | 24,820.2 | 25,146.0 | 26,445.3 | 27,608.8 | 28,584.5 | 30,621.3 | 33,226.4 |
| រូបិយវត្ថុទូទៅ M2 | 11,858.0 | 16,228.0 | 19,476.8 | 23,654.7 | 28,591.9 | 30,480.8 | 31,659.1 | 29,355.5 | 32,768.4 | 35,161.8 | 38,259.9 | 40,768.3 |
| រូបិយវត្ថុ M1 | 2399.0 | 3120.0 | 3220.9 | 3956.2 | 4045.7 | 4500.6 | 4585.9 | 4720.8 | 4878.2 | 5376.2 | 5231.3 | 5583.1 |
| រូបិយវត្ថុផ្សេងៗ | 9459.0 | 13,108.0 | 16,255.9 | 19,698.5 | 24,546.2 | 25,980.2 | 27,073.2 | 24,634.8 | 27,890.2 | 29,785.7 | 33,028.5 | 35,185.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 4.8 | 36.9 | 20.0 | 17.8 | 20.9 | 22.6 | 18.8 | 9.3 | 14.6 | 15.4 | 20.8 | 38.9 |
| រូបិយវត្ថុ M1 | 16.9 | 30.1 | 3.2 | 16.9 | 2.3 | 12.9 | 18.4 | 23.6 | 20.6 | 19.5 | 14.1 | 18.3 |
| រូបិយវត្ថុផ្សេងៗ | 2.2 | 38.6 | 24.0 | 17.9 | 44.6 | 24.4 | 18.8 | 6.9 | 13.6 | 14.6 | 22.0 | 42.8 |

Source: National Bank of Cambodia

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2012 | 2013 | | | 2014 | | | | | 2014 | | |
| | | កុម្ភៈ | ឧសភា | សីហា | វិច្ឆកា | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | ឧសភា | សីហា | វិច្ឆិកា |
| អ្នកធាក់ស៊ីក្លូ | 10,303 | 9592 | 10,681 | 10,636 | 10,842 | 10,832 | 10,764 | 9867 | 11,634 | 0.6 | -7.2 | 7.3 |
| អ្នកលីសែង | 12,143 | 12,749 | 12,823 | 14,157 | 13,260 | 12,141 | 12,568 | 13,399 | 16,188 | -2.0 | -5.4 | 22.1 |
| អ្នកលក់បន្លែតូចតាច | 10,771 | 9953 | 11,571 | 11,490 | 12,449 | 12,294 | 13,581 | 15,372 | 17,735 | 17.4 | 33.8 | 42.5 |
| អ្នករើសអេតចាយ | 8680 | 9487 | 10,440 | 9620 | 9732 | 9593 | 9214 | 8337 | 9548 | -11.9 | -13.3 | -1.9 |
| អ្នកបម្រើតុភោជនីយដ្ឋាន* | 6111 | 6529 | 6744 | 6791 | 6723 | 7449 | 6696 | 7565 | 9435 | -0.7 | 11.4 | 40.3 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 6151 | 5811 | 6427 | 7771 | 6388 | 8932 | 5836 | 8795 | 6781 | -9.2 | 13.2 | 6.1 |
| កម្មកររោងចក្រកាត់ដេរ | 8932 | 10,004 | 9776 | 10,420 | 10,442 | 9548 | 11,412 | 11,388 | 12,092 | 16.5 | 10.6 | 15.8 |
| អ្នករត់ម៉ូតូឌុប | 12,930 | 14,433 | 12,522 | 13,656 | 13,189 | 13,227 | 13,401 | 12,656 | 14,259 | 6.8 | -7.3 | 8.1 |
| កម្មករសំណង់គ្មានជំនាញ | 11,078 | 12,554 | 13,728 | 13,023 | 13,431 | 15,162 | 15,316 | 15,401 | 15,436 | 11.6 | 18.3 | 19.9 |
| កម្មករសំណង់មានជំនាញ | 13,743 | 15,162 | 14,136 | 15,822 | 16,647 | 15,163 | 15,765 | 20,420 | 18,302 | 11.5 | 29.1 | 9.9 |

* Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the incomes of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000.
Source: CDRI

*តពីទំព័រ ២៨* **ព័ត៌មានថ្មីៗ**...

កសាងសមត្ថភាពនៅ CDRI និង MEF, និង ការចែករំលែកធនធានហិរញ្ញវត្ថុរវាងស្ថាប័នទាំងពីរ។ នៅខែមករា ២០១៥ វិទ្យាស្ថាន CDRI នឹងចុះហត្ថលេខាលើឯកសារកំណត់ភាពជាដៃគូស្រដៀងគ្នា ជាមួយវិទ្យាស្ថានជាតិសុខភាពសាធារណៈ ដើម្បីប្រមូលផ្តុំធនធាន និងសមត្ថភាពជំនាញវិជ្ជាជីវៈរបស់ស្ថាប័នទាំងពីរធ្វើការស្រាវជ្រាវរួមគ្នា ហើយជួយផ្តល់ព័ត៌មានដល់ការកសាងគោលនយោបាយ និងការអនុវត្តផ្នែកសុខាភិបាល។

នៅខែវិច្ឆិកា CDRI បានរៀបចំកិច្ចសន្ទនាផ្ទៃក្នុងជាលើកដំបូងមួយក្រោមប្រធានបទ "គោលគំនិតនៃអត្តសញ្ញាណកម្មក្រុមហ៊ុន"។ កម្រងកិច្ចសន្ទនានេះ បើកឱកាសឲ្យបញ្ញវ័ន្ត និងអ្នកអនុវត្តជាក់ស្តែង ទោះមានបទពិសោធន៍តិចឬច្រើនក្តី បានមកជួបជុំគ្នា និងចែករំលែកនូវចំណាប់អារម្មណ៍ស្រាវជ្រាវ ចំណេះដឹង និងបទពិសោធន៍ក្នុងជីវិតរបស់ពួកគេ។ យើងជឿជាក់ថាកិច្ចសន្ទនាអំពីច្រើនវិស័យ ច្រើនរឿង ច្រើនដែនភូមិសាស្ត្រ វប្បធម៌ សមត្ថភាពជំនាញ និងចម្រុះអាយុនេះ នឹងអាចបំផុសនូវការច្នៃប្រឌិត និងគំនិតបែបថ្មី ហើយជួយកែលំអជីវិតវិជ្ជាជីវៈរបស់អ្នកចូលរួមគ្រប់គ្នា។

នៅថ្ងៃទី៩-១២ ខែធ្នូ CDRI បានរៀបចំកម្មវិធីដកឃ្លាទៅលំហែ និងបូកសរុបការងារប្រចាំឆ្នាំ នៅក្រុងព្រះសីហនុ ដើម្បីវាយតម្លៃ និងអបអរសាទរលើបទពិសោធន៍ និងលទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៤, បញ្ជាក់ពីអាទិភាពសម្រាប់ឆ្នាំ២០១៥ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រឆ្នាំ២០១២-១៥ និងយុទ្ធសាស្ត្រស្រាវជ្រាវប្រទេសកម្ពុជាឆ្នាំ២០២០ របស់ខ្លួន, និង កំណត់ពីបញ្ហារចនាសម្ព័ន្ធរបស់អង្គការ ដែលត្រូវយកចិត្តទុកដាក់ជាអាទិភាពក្នុងឆ្នាំបន្ទាប់ទៀត។

សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៥ ដែលជាកិច្ចសហការជាដៃគូរវាង CDRI និងធនាគារ ANZ Royal លើប្រធានបទ "សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ និងតទៅអនាគត៖ របៀបវារៈកំណែទម្រង់" នឹងប្រារព្ធឡើងនៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥។

## ផ្នែកស្រាវជ្រាវ

### *កសិកម្ម*

ក្រុមស្រាវជ្រាវកំពុងអនុវត្តគម្រោងសិក្សាចំនួន៩ ក្នុងនោះ ៤គម្រោង ជាការងាររួមគ្នាជាមួយក្រុមស្រាវជ្រាវតាមវិស័យផ្សេងទៀត និងក្រុមការងារផ្នែកយេនឌ័រ។ របាយការណ៍ព្រាងទី៣ ស្តីពី *ផលប៉ះពាល់នៃការធ្វើកសិកម្មតាមកិច្ចសន្យាទៅលើជីវភាពរបស់ម្ចាស់ដីតូចៗ* ដែលទទួលមូលនិធិពី Sida បានចប់សព្វគ្រប់ និងបញ្ជូនចេញដើម្បីសុំមតិយោបល់។ របាយការណ៍ចុងក្រោយសម្រាប់គម្រោង *ការរចនារៀបចំក្របខ័ណ្ឌវាយតម្លៃ និងការត្រួតពិនិត្យលើអង្កេតគោល និងអង្កេតចុងបញ្ចប់សម្រាប់ការជួយទ្រទ្រង់ដល់ជីវភាព និងទ្រព្យផលិតកម្ម (PALS)* ដែលទទួលមូលនិធិពីកម្មវិធីស្បៀងអាហារពិភពលោក ក៏បានចប់សព្វគ្រប់ដែរ។ របាយការណ៍ព្រាងដំបូងសម្រាប់ *ការសិក្សាពីយន្តកម្មនៅតាមកសិដ្ឋាន និងនិន្នាការទីផ្សារពលកម្មកសិកម្ម* ជិតចប់សព្វគ្រប់ ហើយរបាយការណ៍សម្រាប់ គម្រោងស្តីពីផលប៉ះពាល់នៃគោលនយោបាយជំរុញការនាំចេញអង្ករ និងសន្តិសុខស្បៀង បានចងក្រងរួចរាល់។ ការសិក្សាទាំងពីរនេះទទួលបានហិរញ្ញប្បទានពី Sida។

ករណីសិក្សាពីរផ្តោតលើ ការវិភាគពីខ្សែចង្វាក់តម្លៃបន្ថែម និងផលិតកម្មសត្វចិញ្ចឹម និងផលប៉ះពាល់នៃសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ដែលស្ថិតក្នុងដំណាក់កាលទី២ នៃគម្រោង *គោលនយោបាយកសិកម្ម សម្រាប់ប្រព័ន្ធដាំដុះ ផ្អែកលើដំណាំស្រូវនៅតំបន់មេគង្គកណ្តាល* ដែលទទួលបានមូលនិធិពី ACIAR បានជឿនលឿនទៅមុខច្រើនហើយ។ ការចុះកិច្ចសន្យាមួយកំពុងរៀបចំឡើង សម្រាប់គម្រោងថ្មីរយៈពេលបួនឆ្នាំ (២០១៥-១៨) ស្តីពី *ការសាកល្បងគំរូបែបថ្មី នៃការផ្សព្វផ្សាយបច្ចេកទេសកសិកម្មនៅក្នុង PADEE កម្ពុជា (គម្រោងសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម និងការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ច)* ដែលជាកម្មវិធីចុងក្រោយទទួលបានមូលនិធិពី IFPRI (វិទ្យាស្ថានស្រាវជ្រាវពីគោលនយបាយស្បៀងអាហារអន្តរជាតិ)។

### *សេដ្ឋកិច្ច*

CDRI បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ (MOU) ស្តីពី ភាពជាដៃគូស្រាវជ្រាវគោលនយោបាយអភិវឌ្ឍន៍ និងការកសាងសមត្ថភាព ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) នៅថ្ងៃទី៤ វិច្ឆិកា ២០១៤។ ក្នុងសកម្មភាពទ្រទ្រង់ដល់ MOU នេះ ក្រុមស្រាវជ្រាវ នឹងធ្វើការប្រជុំពិគ្រោះយោបល់ជាមួយបុគ្គលិកបច្ចេកទេសមកពី MEF នៅខែមករា ២០១៥ ដើម្បីពិភាក្សាពីឱកាសសម្រាប់កិច្ចសហការស្រាវជ្រាវ ជាពិសេសការបង្កើតយុទ្ធសាស្ត្រ ដើម្បីភ្ជិតគម្លាតផ្នែកជំនាញឲ្យបានស្របគ្នានឹងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម សម្រាប់ឆ្នាំ២០១៥-២០២៥។

របាយការណ៍ស្តីពី ភាពគ្មានដីធ្លី និងពលកម្មកុមារ ដែលទទួលបានជំនួយទ្រទ្រង់ហិរញ្ញវត្ថុពី អង្គការទស្សនៈពិភពលោកកម្ពុជា (WVC) បានចប់សព្វគ្រប់ និងបញ្ជូនទៅឲ្យអ្នកស្រាវជ្រាវដទៃទៀតក្នុងជំនាញដូចគ្នា ជួយពិនិត្យផ្តល់យោបល់។ សម្រាប់ការសិក្សាស្តីពី *ចម្លើយតបរបស់សហគមន៍ទៅនឹងអំពើហិង្សាលើស្ត្រី* ដែលទទួលជំនួយទ្រទ្រង់ពីអង្គការវិនិយោគលើកុមារ និងសង្គមកុមារ (ICS) ក្រុមស្រាវជ្រាវបានបញ្ចប់ការប្រមូលទិន្នន័យ និងកំពុងចងក្រងរបាយការណ៍។ ការសិក្សាដល់កន្លែងបានអនុវត្តឡើងសម្រាប់គម្រោងទទួលមូលនិធិពី អង្គការដើម្បីសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) ស្តីពីទំនាក់

*ទំនងរវាងគោលនយោបាយសាធារណៈ ចំណាកស្រុក និងការអភិវឌ្ឍនៃប្រទេសជាដៃគូ៖ ករណីសិក្សា និងអនុសាសន៍គោលនយោបាយ* ហើយបច្ចុប្បន្នក្រុមស្រាវជ្រាវកំពុងចងក្រងរបាយការណ៍។ ក្រុមស្រាវជ្រាវក៏បានបញ្ចប់ និងបញ្ជូនឯកសារពិភាក្សាមួយ ស្ដីពី *ការប៉ាន់ស្មានពីឥទ្ធិពលផ្នែកសេដ្ឋកិច្ចនៃចំណាកស្រុក និងប្រាក់ផ្ញើមកផ្ទះ ទៅលើសមាជិកគ្រួសារនៅកម្ពុជា* ទៅឲ្យអង្គការភាពជាដៃគូដើម្បីគោលនយោបាយសេដ្ឋកិច្ច (PEP)។ អត្ថបទសង្ខេបគោលនយោបាយមួយពាក់ព័ន្ធនឹងការសិក្សានេះ ក៏បានបោះពុម្ពផ្សាយហើយដែរ។ ការស្រាវជ្រាវរួមគ្នាមួយជាមួយសាកលវិទ្យាល័យ Manchester នៃប្រទេសអង់គ្លេស ស្ដីពី *ដំណោះស្រាយនយោបាយ និងការអប់រំកម្រិតបឋមសិក្សានៅកម្ពុជា* កំពុងជឿនលឿនទៅមុខជាបណ្ដើរៗ ហើយបច្ចុប្បន្នកំពុងធ្វើសម្ភាសន៍អ្នកពាក់ព័ន្ធ និងការសិក្សាឯកសារនៅការិយាល័យ។

បណ្ដាញវិភាគអភិវឌ្ឍន៍មហាអនុតំបន់មេគង្គ (GMS-DAN) បានបញ្ចប់គម្រោងស្រាវជ្រាវពហុប្រទេសមួយស្ដីពី *ការអភិវឌ្ឍសម្រាប់គ្រប់គ្នាលើផ្នែកសុខភាព និងការអប់រំបឋម នៅមហាអនុតំបន់មេគង្គ*។ បណ្ដាញស្រាវជ្រាវនេះ បានបញ្ជូនសំណើគម្រោងស្ដីពី *ការលើកកម្ពស់អនាគតការងារសម្រាប់យុវជន៖ ទីផ្សារពលកម្ម, ការអភិវឌ្ឍន៍ជំនាញ និងវិស័យឯកជន ក្នុងមហាអនុតំបន់មេគង្គ* ដើម្បីបង្កើតកិច្ចសហការស្រាវជ្រាវជាមួយមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) នៃប្រទេសកាណាដា។

*អង្កេតប្រចាំត្រីមាសលើពលករងាយរងគ្រោះ, អង្កេតប្រចាំខែលើថ្លៃទំនិញតាមខេត្ត និងរបាយការណ៍ថ្មីៗ ស្ដីពីសេដ្ឋកិច្ចកម្ពុជា* បន្តមានដំណើរការល្អ។

## ***ការអប់រំ***

ដើម្បីជួយទ្រទ្រង់ដល់ផែនការសកម្មភាពជាអាទិភាព និងកំណែទម្រង់វិស័យអប់រំរបស់រាជរដ្ឋាភិបាលនោះ នៅពាក់កណ្ដាលឆ្នាំ២០១៤ ក្រុមស្រាវជ្រាវវិស័យអប់រំ បានផ្ដួចផ្ដើមបង្កើតគម្រោងសហការស្រាវជ្រាវមួយ ស្ដីពីការអភិវឌ្ឍជំនាញ និងកំណែទម្រង់វិស័យអប់រំនៅកម្ពុជា ដើម្បីបង្កើតនូវ *របាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០១៤-១៥* របស់ CDRI លើប្រធានបទ *ការពង្រឹងវិស័យអប់រំដើម្បីផ្ដល់ការងារ និងសិទ្ធិអំណាច៖ ជម្រើសគោលនយោបាយ និងអាទិភាពជាយុទ្ធសាស្ត្រសម្រាប់កម្ពុជា* ដែលត្រូវចេញផ្សាយក្នុងឆ្នាំ២០១៥។ របាយការណ៍នេះ វិភាគពីសក្ដានុពលសម្រាប់ការពង្រឹងវិស័យអប់រំនៅកម្ពុជា ដើម្បីបង្កើតការងារឲ្យយុវជន និងផ្ដល់សិទ្ធិអំណាចឲ្យប្រជាជន ព្រមទាំងស្វែងរកជម្រើសគោលនយោបាយ និងអាទិភាពជាយុទ្ធសាស្ត្រក្នុងការសម្រេចសក្ដានុពលនេះឲ្យបាន។

ការផលិត ឯកសារស្រាវជ្រាវផ្នែកគោលនយោបាយខាងលើដែលមានទាំងការពិគ្រោះយោបល់ និងកិច្ចសហការជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ បានផ្ដល់ជាគ្រឹះរឹងមាំសម្រាប់កម្មវិធីរយៈពេលវែងប្រកបដោយមហិច្ឆតាខ្ពស់ សំដៅស្វែងរក និងកសាងសមត្ថភាពជំនាញខ្ពស់ក្នុងស្ថាប័នកម្ពុជាសំខាន់ៗ ព្រមទាំងបង្កើតនូវមូលដ្ឋាន សម្រាប់កិច្ចសហការរយៈពេលវែងរវាងស្ថាប័ន។ CDRI បានបង្កើតការសិក្សាស្រាវជ្រាវខាងគោលនយោបាយអប់រំរយៈពេលប្រាំឆ្នាំ (២០១៤-១៨) មួយ ហៅថា "ការស្រាវជ្រាវ និងកម្មវិធីសន្ទនាផ្នែកគោលនយោបាយ ស្ដីពីកំណែទម្រង់វិស័យអប់រំនៅកម្ពុជា" សំដៅបង្កើតនូវផលិតផលស្រាវជ្រាវលំអិតពាក់ព័ន្ធដល់គោលនយោបាយ ព្រមទាំងចូលរួមចំណែកក្នុងកំណែទម្រង់វិស័យអប់រំ ដោយមានភស្តុតាងជាក់ស្ដែងជួយបំភ្លឺ។

## ***បរិស្ថាន***

ឯកសារពិភាក្សាស្ដីពី *ការអនុវត្តបច្ចេកទេសកសិកម្ម និងចន្លោះខ្វះខាត ក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ៖ ប្រព័ន្ធប្រពលវប្បកម្មស្រូវ (SRI)* ដែលទទួលមូលនិធិពី Sida កំពុងចងក្រងសម្រាប់ការបោះពុម្ពផ្សាយ។ គម្រោងទទួលបានមូលនិធិពីក្រុមប្រឹក្សាស្រាវជ្រាវសេដ្ឋកិច្ច និងសង្គម ស្ដីពី *ប្រទេសចិនឈានឡើងកម្រិតសកល* កំពុងស្ថិតក្នុងដំណាក់កាលវិភាគទិន្នន័យបានពីការចុះសិក្សាដល់កន្លែង ហើយលទ្ធផលរកឃើញនឹងយកទៅចុះផ្សាយក្នុងសារព័ត៌មានអន្តរជាតិមួយ បន្ទាប់ពីមានអ្នកស្រាវជ្រាវឯទៀតជួយពិនិត្យផ្ដល់មតិ និងចុះក្នុងឯកសារបោះពុម្ពផ្សាយមួយរបស់ CDRI ក្នុងឆ្នាំ២០១៥។

ក្រុមស្រាវជ្រាវកំពុងអនុវត្តការសិក្សាលើសមាសភាគ ស្ដីពីការវាយតម្លៃភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ, ការប្រើប្រាស់ព័ត៌មានបានពី ការបង្រួមទិន្នន័យនៃការប្រែប្រួលអាកាសធាតុ (climate-downscaling) សម្រាប់ការវាយតម្លៃផ្នែកធារាសាស្ត្រ, អភិបាលកិច្ចទឹក, ការកសាងសមត្ថភាព និងការផ្សព្វផ្សាយចំណេះដឹង, ដែលទទួលបានមូលនិធិពី IDRC ស្ដីពី *ការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ចទឹកនៅកម្ពុជា*។ កំពុងដំណើការទៅមុខដូចគ្នា គឺ ការវិភាគទិន្នន័យ ស្ដីពីការប៉ះពាល់ ភាពងាយរងឥទ្ធិពល និងសមត្ថភាពបន្សាំនៅកម្រិតមូលដ្ឋានក្នុងខេត្តគោលដៅ កំពង់ឆ្នាំង ពោធិ៍សាត់ និងកំពង់ធំ។ ការសិក្សាពីធារាសាស្ត្រក្នុងដែនរងទឹកភ្លៀង កំពុងអនុវត្តទៅមុខ។ របាយការណ៍ពាក់កណ្ដាលទី សម្រាប់គម្រោងថ្មីមួយទទួលមូលនិធិពី កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) នៃក្រសួងបរិស្ថាន ស្ដីពី *ការសិក្សាបន្តពីការសិក្សាទូទាំងប្រទេសឆ្នាំ២០១១ លើទម្លាប់ ឥរិយាបថ និងចំណេះដឹងពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា* ត្រូវបានបញ្ជូនទៅឲ្យម្ចាស់ជំនួយ ហើយលទ្ធផលស្រាវជ្រាវបឋមនឹងយកទៅធ្វើបទបង្ហាញនៅថ្ងៃទី១៩ កុម្ភៈ ២០១៥។ ក្រុមស្រាវជ្រាវបានចាប់ដំណើរការគម្រោងថ្មីមួយ ស្ដីពី *ផែនការគ្រប់គ្រងគ្រោះមហន្តរាយផ្អែកលើសហគមន៍នៅជនបទកម្ពុជា* ដែលទទួលបាន

ជំនួយទ្រទ្រង់ហិរញ្ញវត្ថុពី វិទ្យាស្ថានជប៉ុនផ្នែកការស្រោចស្រព និងរំដោះទឹក (JIID)។

សំណើគម្រោងស្ដីពី ចីរភាពនៃការអភិវឌ្ឍថាមពលវារីអគ្គិសនីនៅលើទន្លេ និងដៃទន្លេមេគង្គកម្ពុជា ដែលបានបញ្ជូនទៅឲ្យអង្គការផ្ដួចផ្ដើមធ្វើគោលនយោបាយសាធារណៈ សម្រាប់ទន្លេមេគង្គក្រោម (LMPPI) នោះ ក្រុមស្រាវជ្រាវកំពុងចងក្រងឲ្យរួចរាល់ ហើយសំណើគម្រោងដទៃទៀតដែលត្រូវបញ្ជូនទៅឲ្យដៃគូផ្សេងៗ កំពុងយកមកពិនិត្យឡើងវិញ។

## *អភិបាលកិច្ច*

ឯកសារពិភាក្សាពីរកំពុងបង្កើយ សម្រាប់ការបោះពុម្ពផ្សាយ គឺមានរបាយការណ៍ស្ដីពី *គណនេយ្យភាពសង្គមនៅកម្ពុជា* និង *ការអនុវត្តជាក់ស្ដែងនូវវិធីសាស្ត្រផ្អែកលើសិទ្ធិអំណាច៖ កត្តាកំណត់ និងការប្រមើលឃើញនៅកម្ពុជា*។ នាបច្ចុប្បន្នក្រុមស្រាវជ្រាវកំពុងចងក្រងរបាយការណ៍សម្រេច នៃគម្រោងរួមគ្នាមួយជាមួយក្រុមស្រាវជ្រាវផ្នែកបរិស្ថាន ស្ដីពី *ការសម្រេចចិត្ត និងការអភិវឌ្ឍសមត្ថភាព សម្រាប់ការគ្រប់គ្រងធនធានទឹក និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ*។ ការសិក្សារួមសហការទី២ គឺ *ការអប់រំនៅកម្ពុជា៖ ការងារ និងការផ្ដល់សិទ្ធិអំណាច* ដែលជាប្រធានបទនៃ *របាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០១៤-១៥* របស់ CDRI ។ ក្រុមស្រាវជ្រាវផ្នែកអភិបាលកិច្ចទទួលខុសត្រូវលើជំពូកស្ដីពី "ការដោះស្រាយតម្រូវការរៀនសូត្រជាមូលដ្ឋាន តាមរយៈការអប់រំកម្រិតបឋមសិក្សា"។ ក្រុមស្រាវជ្រាវទទួលបានគម្រោងស្រាវជ្រាវរយៈពេលបីឆ្នាំថ្មីមួយ ស្ដីពី *លទ្ធភាពសម្រាប់ធ្វើកិច្ចសន្ទនា អំពីអភិបាលកិច្ចទឹកទន្លេមេគង្គ* ដែលត្រៀមចាប់អនុវត្តពីខែមករា ២០១៥ ដល់ខែធ្នូ ២០១៧។

នៅខែធ្នូ ក្រុមស្រាវជ្រាវបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយមួយនៅខេត្តសៀមរាប។ សិក្ខាសាលានេះ មានអ្នកចូលរួមជាមន្ត្រីមូលដ្ឋានចំនួន ៣០០នាក់ រួមមាន សមាជិកក្រុមប្រឹក្សាឃុំ មន្ត្រីស្រុក និងមន្ត្រីខេត្ត មកពីខេត្តកំពង់ចាម បាត់ដំបង ក្រចេះ កំពង់ឆ្នាំង ពោធិ៍សាត់ និងសៀមរាប។

## *សុខភាព*

គម្រោងចម្បងៗបី កំពុងដំណើរការទៅមុខ។ ទី១ *គម្រោងការកសាង ប្រព័ន្ធសុខាភិបាលអំណោយផលដល់ជនក្រីក្រ ក្នុងពេលកសាងប្រទេសឡើងវិញ បន្ទាប់ពីបានបញ្ចប់ទំនាស់ (ReBUILD)* បានចូលដល់ដំណាក់កាលចុងក្រោយ ក្នុងនោះ ការវិភាគទិន្នន័យ និងរបាយការណ៍ដាច់ដោយឡែកពីគ្នាសម្រាប់ ៣អនុគម្រោង បានចប់សព្វគ្រប់។ អនុគម្រោងទី១ ពិនិត្យពីផលប៉ះពាល់ នៃយុទ្ធសាស្ត្រផ្ដល់ហិរញ្ញប្បទានសុខភាពទៅលើលទ្ធភាពប្រើប្រាស់សេវាសុខភាព។ អនុគម្រោងទី២ វាយតម្លៃអំពីគ្រឿងលើកទឹកចិត្ត ដើម្បីរក្សាបុគ្គលិកសុខាភិបាល និងលើកកម្ពស់លទ្ធផលការងារ ព្រមទាំងអំពីបញ្ហាប្រឈមចំពោះបុគ្គលិកសុខាភិបាលនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល។ អនុគម្រោងទី៣ វាយតម្លៃពីការរៀបចំកិច្ចសន្យាផ្ដល់សេវាសុខភាព។ គម្រោង ReBUILD ទទួលបានមូលនិធិពី នាយកដ្ឋានសម្រាប់ការអភិវឌ្ឍអន្តរជាតិ (DFID) នៃប្រទេសអង់គ្លេស ហើយត្រូវបានអនុវត្តរួមគ្នាជាមួយសាកលវិទ្យាល័យ Liverpool School of Tropical Medicine។ គម្រោងស្រាវជ្រាវទី២ ស្ដីពី *ការផ្ដល់សេវាសម្ភពក្នុងប្រព័ន្ធសុខាភិបាលនៅកម្ពុជា* ដែលជាគម្រោងរួមគ្នាជាមួយ មជ្ឈមណ្ឌលនូហ្វៀលសម្រាប់ការអភិវឌ្ឍ និងសុខភាពអន្តរជាតិ (Nuffield Centre for International Health and Development) និងសាកលវិទ្យាល័យ Leeds នោះ បានទទួលជំនួយទ្រទ្រង់ពី មូលនិធិ ReBUILD Responsive Fund។ ការសិក្សាដល់កន្លែងបានអនុវត្តរួចរាល់ ហើយការសំអាតទិន្នន័យ ការចម្លងបទសម្ភាសន៍ជាលាយលក្ខណ៍អក្សរ និងការបកប្រែអត្ថបទសម្ភាសន៍ កំពុងដំណើរការទៅមុខ។ គម្រោងស្រាវជ្រាវចម្បងទី៣ ផ្ដោតលើពលកម្មកុមារ។ គម្រោងនេះហៅថា *ការលុបបំបាត់ការកេងប្រវ័ញ្ចលើពលកម្មកុមារ តាមការលើកកម្ពស់ការអប់រំ និងជីវភាពរស់នៅ (EXCEL)* ដែលជាគម្រោងអនុវត្តរួមគ្នារយៈពេល៤ឆ្នាំ (២០១២-១៦) ជាមួយអង្គការទស្សនៈពិភពលោក, អង្គការវឌ្ឍនភាព, អង្គការអភិវឌ្ឍជីវភាពកសិករ និង អង្គការជួយដល់កុមារងាយរងគ្រោះ ហើយមានគោលដៅកំណត់រកកុមារងាយរងគ្រោះ ដែលបម្រើការក្នុងវិស័យផ្សេងៗ ដូចជា នេសាទ កសិកម្ម ការបម្រើតាមផ្ទះជាដើម។ មានអនុគម្រោងពីរ ស្ដីពី "កុមារបម្រើការងារតាមផ្ទះ" និង "ភាពគ្មានដីធ្លី និងពលកម្មកុមារ" បានចប់សព្វគ្រប់ ហើយរបាយការណ៍ព្រាងទី២ បានបញ្ជូនទៅឲ្យអង្គការទស្សនៈពិភពលោកនៅកម្ពុជា ជួយពិនិត្យឡើងវិញជាលើកចុងក្រោយ។

អត្ថបទសង្ខេបមួយស្ដីពី "ឥរិយាបថស្វែងរកសេវាថែទាំសុខភាពមាតា៖ វិធីសាស្ត្រផ្អែកលើប្រវត្តិជីវិត" បានចេញផ្សាយក្នុង*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ហើយរបាយការណ៍គម្រោង *ការពង្រឹងការអប់រំកម្រិតមធ្យមសិក្សា* កំពុងរង់ចាំមតិយោបល់ពីអ្នកស្រាវជ្រាវនៅខាងក្រៅ ដែលធ្វើការក្នុងវិស័យដូចគ្នា។ ក្រុមស្រាវជ្រាវផ្នែកសុខភាពបានបង្កើត និងដាក់ស្នើឡើងនូវគម្រោងស្រាវជ្រាវបី ស្ដីពី *ការស្រាវជ្រាវនាំមុខគេអំពី មតិយោបល់លើការផ្ដល់អាហារទៅឲ្យទារក និងកុមារ, ការពិនិត្យផ្ទៀងផ្ទាត់លើលទ្ធផលផ្នែកអនាម័យ* ដើម្បីវាយតម្លៃពីផលប៉ះពាល់នៃការកែលំអអនាម័យនៅទីជនបទ និង *គន្លងការងារសម្រាប់បុគ្គលិកសុខាភិបាលនៅកម្ពុជា* ដោយពិនិត្យតាមទស្សនៈផ្នែកយេនឌ័រ។

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

នៅខែធ្នូ ឆ្នាំ២០១៤ នាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI បានបន្តជំនួបជាមួយ រដ្ឋមន្ត្រី និងមន្ត្រីរដ្ឋាភិបាល, តំណាងមកពីស្ថាប័នដៃគូអភិវឌ្ឍន៍ និងអ្នកអាចក្លាយជាដៃគូរបស់ CDRI ។ រដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់នានា ដែលលោកនាយកប្រតិបត្តិបានចូលជួប ដើម្បីពិភាក្សាពីអាទិភាពស្រាវជ្រាវផ្នែកគោលនយោបាយ រួមមាន ឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា, លោកជំទាវបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី, ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល និង ឯកឧត្តមបណ្ឌិត វង្សី វិស្សុត រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

គណៈគ្រប់គ្រងជាន់ខ្ពស់របស់ CDRI ក៏បានជួបជាមួយមន្ត្រីជាន់ខ្ពស់មកពី វិទ្យាស្ថានជាតិសុខភាពសាធារណៈ ព្រមទាំងធ្វើការពិភាក្សា និងពិនិត្យរកឱកាសដើម្បីកសាងភាពជាដៃគូជាមួយ ឯកអគ្គរដ្ឋទូតនៃប្រទេសកាណាដា សហភាពអឺរ៉ុប ជប៉ុន កូរ៉េខាងត្បូង និង ស៊ុយអែត និង តំណាងនៃធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ USAID និង សហគ្រាសអាល្លឺម៉ង់សម្រាប់សហប្រតិបត្តិការអន្តរជាតិ (GIZ)។ គណៈគ្រប់គ្រងជាន់ខ្ពស់ បានជួបពិភាក្សាជាមួយតំណាងមកពីស្ថាប័នចម្បងៗក្នុងវិស័យឯកជន រួមមាន ក្រុមហ៊ុនធានារ៉ាប់រងជីវិតព្រូដិនសលកម្ពុជា សភាពាណិជ្ជកម្មអន្តរជាតិ សភាពាណិជ្ជកម្មប្រទេសអង់គ្លេស និង ក្រុមហ៊ុន Tata South East Asia Ltd ។

គណៈប្រតិភូនៃ បណ្ឌិតសភាវិទ្យាសាស្ត្រសង្គមប្រទេសចិន វិទ្យាស្ថានស៊ាងហៃសម្រាប់ការសិក្សាអន្តរជាតិ និង បណ្ឌិតសភាវិទ្យាសាស្ត្រសង្គមប្រទេសវៀតណាម បានមកធ្វើទស្សនកិច្ចនៅ CDRI ដើម្បីចែករំលែកទស្សនៈគ្នាពីការអភិវឌ្ឍនៅកម្ពុជា និង ស្រាវជ្រាវពីលទ្ធភាពធ្វើជាដៃគូជាមួយគ្នា។ គណៈគ្រប់គ្រង និង បុគ្គលិក CDRI ក៏បានចូលរួមក្នុងសន្និសីទ និងសិក្ខាសាលាជាច្រើន ទាំងនៅក្នុង និងនៅក្រៅប្រទេស ព្រមទាំងធ្វើបទបង្ហាញ និង សុន្ទរកថាជាច្រើនទៀត។

នៅខែតុលា ២០១៤ នាយកប្រតិបត្តិ CDRI បានអញ្ជើញចូលរួមក្នុង វេទិកាស្ថាប័នអាស៊ីខាងកើតលើកទី១០ ក្រោមប្រធានបទ "ខ្សែសង្វាក់តម្លៃសកល និងសមាហរណកម្មសេដ្ឋកិច្ចអាស៊ីខាងកើត" នៅក្រុងដាណាង ប្រទេសវៀតណាម ព្រមទាំងអញ្ជើញចូលរួមក្នុង មហាសន្និបាត SEAMEO ក្រោមប្រធានបទ "ការគិតគូរជាថ្មីពីវប្បធម៌ និងវិទ្យាសាស្ត្រអប់រំ ដើម្បីជំរុញសមាហរណកម្មក្នុងតំបន់" នៅទីក្រុងបាងកក ប្រទេសថៃ។ លោកនាយកប្រតិបត្តិក៏បានតំណាងឲ្យ CDRI ទៅចូលរួមក្នុងវេទិកាអភិវឌ្ឍន៍ក្រុមផ្ដល់គំនិតនៅអាស៊ីលើកទី២ របស់ធនាគារអភិវឌ្ឍន៍អាស៊ី ស្ដីពី "ការពន្លឿនការអនុវត្តបែបថ្មី និងលក្ខណៈសម្រាប់គ្រប់គ្នា ដើម្បីជំរុញជួយឲ្យតំបន់អាស៊ីមានការរីកចម្រើន" នៅឯទីក្រុងសេអ៊ូល ប្រទេសកូរ៉េខាងត្បូង កាលពីថ្ងៃទី២០-២១ វិច្ឆិកា ២០១៤។

នៅខែវិច្ឆិកា CDRI បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ (MOU) លើកដំបូងមួយ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF)។ MOU នេះ នឹងជួយសម្រួលដល់ការស្រាវជ្រាវរួមគ្នាផ្នែកគោលនយោបាយស្ដីពី បញ្ហាកំពុងផុសឡើងសំខាន់ៗ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា, ការ

*តទៅទំព័រ ២៥*

ទស្សនាវដ្ដី
អភិវឌ្ឍន៍កម្ពុជា

*ឯកសារបោះពុម្ពផ្សាយរបស់*
*វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី១៨ លេខ៤ ខែធ្នូ ឆ្នាំ២០១៤

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្ដល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្ដល់ជូននូវមូលវិចារឯករាជ្យស្ដីពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន។ លិខិត ត្រូវចុះហត្ថលេខា អាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន។ អ្នកនិពន្ធ ត្រូវទាក់ទងវិទ្យាស្ថាន CDRI មុននឹងផ្ដល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល។

**វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☛ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥ ២៣) ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣ 🖷 (៨៥៥ ២៣) ៨៨០ ៧៣៤
e-mail: cdri@cdri.org.kh
website: www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសំរួល: យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា និង ម៉េន ច័ន្ទធីតា
ជំនួយការកែសំរួល: ខេង សេង
សហគ្រាសបោះពុម្ព សាលាបច្ចេកទេសដុនបូស្កូ ភ្នំពេញ រូបភាពទំព័រមុខ: រូបភាព វបសអ

© រក្សាសិទ្ធិ ២០១៤ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វិទ្យាស្ថានCDRI ឡើយ។

ISSN 1560-7615 / ISBN 978-99950-52-06-5

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្ដល់ជូនដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.cdri.org.kh